ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


០៩-៦-២០១៣ -ព្រះរាជក្រម នស/រកម/០៦១៣/០០៨ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី សហគមន៍កសិកម្ម ៥៥៨៤


### ២~ព្រះរាជក្រឹត្យ


៣០-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៦៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ០៥ រូប ៥៥៨៤

៣០-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៧០ ស្តីពី ការតែងតាំងឯកឧត្តម ស៊ុំ គង់ទ្រឹទ ជា ឧកញ៉ា ៥៥៨៥

៣០-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៧១ ស្តីពី ការតែងតាំងឯកឧត្តម និង លោកជំទាវ ចំនួន ០២ រូប ជាទីប្រឹក្សា និងជំនួយការ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នីតិកាលទី ៣ ៥៥៨៦

៣០-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៧២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឯកឧត្តមឧកញ៉ា ឆាយ អ៊ីនន័រ ៥៥៨៧

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៧៣ ស្តីពី ការកាត់ផ្ទៃដី ទំហំ ៣១ ហិកតា ដែលកំណត់ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០០៣ ៥៥៨៨

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៧៤ ស្តីពី ការកាត់ផ្ទៃដី ទំហំ ៦៨៨ ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដែលកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ៥៥៨៩

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៧៥ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ឯក ជូនលោកឧត្តមសេនីយ៍ទោ មួន សារ៉ន នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៥៥៩០

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៧៦ ស្តីពី ការតែងតាំងឯកឧត្តម មួន សារ៉ន ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៥៥៩១

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៧៧ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក **សុខណ្ណា ធនូរាសី** នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៥៥៩២

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៧៨ ស្តីពី ការតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ **នៃ ស៊ីណារិទ្ធ** ជាទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៥៥៩៣

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៧៩ ស្តីពី ការតែងតាំងឯកឧត្តម **ម៉ុន រដ្ឋា** ជាជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៥៥៩៤

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

២៩-៥-២០១៣ -អនុក្រឹត្យលេខ ២៨០ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ១.៨៣៤,៧១១០ ហិកតា នៅស្រុកឈូក ខេត្តកំពត ចេញពី (១)គម្របព្រៃឈើ ឆ្នាំ ២០០២ (២) ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន World Trista Entertainment (CAMBODIA) Co,.Ltd ដើម្បីធ្វើ អនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦២៩ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៥៥៩៥

២៩-៥-២០១៣ -អនុក្រឹត្យលេខ ២៨១ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ២១២,៥១៨៣ ហិកតា នៅស្រុកឈូក ខេត្តកំពត ចេញពី (១)ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន Virtus Green Plantations (CAMBODIA) Pte,.Ltd (២) ដីសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុន First Bio-Tech Agricultural (CAMBODIA) Co,.Ltd ដើម្បីធ្វើ អនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១១៥ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៥៥៩៨

២៩-៥-២០១៣ -អនុក្រឹត្យលេខ ២៨២ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ១៣៣,៤០០២ ហិកតា នៅស្រុកជុំគីរី ខេត្តកំពត ចេញពីផែនទីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៤១ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៥៦០១

២៩-៥-២០១៣ -អនុក្រឹត្យលេខ ២៨៣ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៧២៥,៨៣៨៨ ហិកតា នៅស្រុកជុំគីរី ខេត្តកំពត ចេញពីផែនទីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣៨៥ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៥៦០៤

២៩-៥-២០១៣ -អនុក្រឹត្យលេខ ២៨៤ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ១០៦,៤៥៩៧ ហិកតា នៅស្រុកជុំគីរី ខេត្តកំពត ចេញពីផែនទីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៩៧ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៥៦០៧

២៩-៣-២០១៣ -អនុក្រឹត្យលេខ ៣៧៣ អនក្រ.តត ស្តីពី ការដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍ ៥៦១០

២៩-៣-២០១៣ -អនុក្រឹត្យលេខ ៣៧៤ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៥៦១២

២៩-៣-២០១៣ -អនុក្រឹត្យលេខ ៣៧៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៦១៣

២៩-៣-២០១៣ -អនុក្រឹត្យលេខ ៣៧៦ អនក្រ.តត ស្តីពី ការបំពេញបន្ថែមសមាសភាព នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ឆ្នាំ ២០១១-២០១៤ ៥៦១៥

២៩-៣-២០១៣ -អនុក្រឹត្យលេខ ៣៧៧ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៥៦១៧

## ២-សារាចរ

២៩-៥-២០១៣ -សារាចរលេខ ០៣ សរ ស្តីពី ការអនុវត្តគោលការណ៍ណែនាំអំពីនីតិវិធី និងវិធានការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ៥៦១៨

## ៣-សារាចរណែនាំ

១៧-៦-២០១៣ -សារាចរលេខ ១០ សរណន ស្តីពី ការប្រគល់ភារកិច្ចជូនអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ជួយសម្របសម្រួលការគ្រប់គ្រងរោងចក្រ សហគ្រាសដែលស្ថិតក្នុងភូមិសាស្ត្ររាជធានី ខេត្ត ៥៦៦២

# III-ភាគខាងបណ្តាក្រសួង

## ទីស្តីការក្រសួងមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៦-៥-២០១៣ -ប្រកាសលេខ ៤៣៦ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ានសេន ក្លូសស៊ីង (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៥៦៦៤

១៦-៥-២០១៣ -ប្រកាសលេខ ៤៣៧ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ខេមបូឌាន លី ហួតាង ហ្វើនីឈ័រ គ្រុប បង្កើតរោងចក្រ ផលិតគ្រឿងសង្ហារឹម ៥៦៦៨

# ព្រះរាជក្រម

នស/រកម/០៦១៣/០០៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីសហគមន៍កសិកម្ម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៣ នា សម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី៣ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL *

# ច្បាប់

# ស្តីពី

# សហគមន៍កសិកម្ម

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងលើកកម្ពស់ការចូលរួមដោយស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលមានមុខរបរចម្បងក្នុងក្របខ័ណ្ឌនៃប្រព័ន្ធផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬ សេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម ក្នុងការបង្កើតនិងការអភិវឌ្ឍសហគមន៍កសិកម្មសំដៅលើក កម្ពស់សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់សមាជិក ព្រមទាំងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅកំណត់អំពីការបង្កើត ការប្រព្រឹត្តទៅ និងការគ្រប់គ្រង ព្រមទាំងយន្ត ការគាំទ្រសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និង សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

សហគមន៍កសិកម្មជានីតិបុគ្គលឯកជនមានលក្ខណៈជាសហគ្រាសសេដ្ឋកិច្ចកសិកម្មដែល បង្កើតឡើងដោយរូបវន្តបុគ្គលមួយក្រុម តាមការស្ម័គ្រចិត្ត រួមគ្នាបង្កើតដើមទុន រួមគ្នាធ្វើម្ចាស់ និងរួម គ្នាគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យ ដើម្បីពង្រីកសមត្ថភាពផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម សំដៅលើកកម្ពស់សេដ្ឋកិច្ច សង្គម និងវប្បធម៌ របស់សមាជិក ស្របតាមគោលការណ៍គ្រឹះមានដូចខាងក្រោម ៖

- ការចូលរួមដោយស្ម័គ្រចិត្តនិងបើកចំហសមាជិកភាព
- ការគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យដោយសមាជិក
- ការចូលរួមផ្នែកសេដ្ឋកិច្ចរបស់សមាជិក
- ស្វ័យភាពនិងឯករាជ្យ
- ការអប់រំ ការបណ្តុះបណ្តាល និងការផ្តល់ព័ត៌មាន
- ការធ្វើសហប្រតិបត្តិការជាមួយសហគមន៍កសិកម្មផ្សេងទៀត
- ការគិតគូរដល់សហគមន៍ ។

**មាត្រា ៥.-**

ពាក្យគន្លឹះដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធ នៃច្បាប់នេះ ។

# ជំពូកទី ២
# យន្តការគាំទ្រសហគមន៍កសិកម្ម
## ផ្នែកទី ១
## ក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្ម

**មាត្រា ៦.-**

ត្រូវបង្កើតក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្ម ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាជិកជាតំណាងមកពីទីស្តីការគណៈរដ្ឋមន្ត្រី តំណាងក្រសួងមហាផ្ទៃ តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងក្រសួង ឬស្ថាប័នផ្សេងទៀតដែលពាក់ព័ន្ធនឹងសហគមន៍កសិកម្ម តំណាងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា តំណាងវិស័យឯកជន តំណាងសង្គមស៊ីវិលនិងប្រធានអង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្មមានលេខាធិការដ្ឋានមួយនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៧.-**

ក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្មមានមុខងារនិងភារកិច្ចដូចខាងក្រោម ៖

- សិក្សាស្រាវជ្រាវ ពិគ្រោះយោបល់ ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពពាក់ពន្ធ័នឹងការអភិវឌ្ឍសហគមន៍កសិកម្ម ដោយអនុលោមតាមលក្ខខណ្ឌសេដ្ឋកិច្ចនិងសង្គម
- លើកសំណើជូនរាជរដ្ឋាភិបាលដើម្បីសុំការសម្រេចលើគោលនយោបាយជាតិស្តីពីការអភិវឌ្ឍសហគមន៍កសិកម្ម
- តាមដានត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីការងារសម្រាប់ការអភិវឌ្ឍសហគមន៍កសិកម្ម
- កំណត់ទិសដៅក្នុងការលើកកម្ពស់និងពង្រឹងសមត្ថភាពនិងការជំរុញកិច្ចសហប្រតិបត្តិការរបស់សហគមន៍កសិកម្មជាមួយផ្នែកឯកជននិងដៃគូអភិវឌ្ឍនានា
- សម្របសម្រួលរវាងស្ថាប័នរដ្ឋពាក់ព័ន្ធ ផ្នែកឯកជន និងស្ថាប័នហិរញ្ញវត្ថុ ដើម្បីជំរុញទ្រទ្រង់ដល់ប្រតិបត្តិការរបស់សហគមន៍កសិកម្ម
- ចេញសេចក្តីសម្រេចឬសេចក្តីណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ រាជធានី ខេត្ត ក្នុងការដាក់ឲ្យអនុវត្តកម្មវិធីការងារក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដែលពាក់ព័ន្ធនឹងគោលនយោបាយ ផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពអភិវឌ្ឍសហគមន៍កសិកម្ម

- ដោះស្រាយបញ្ហាឬឧបសគ្គដែលរាំងស្ទះដល់ការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអភិវឌ្ឍសហគមន៍កសិកម្ម

- ធ្វើរបាយការណ៍ជាប្រចាំជូនរាជរដ្ឋាភិបាលអំពីលទ្ធផលនៃការអភិវឌ្ឍសហគមន៍កសិកម្ម

- បំពេញមុខងារផ្សេងទៀតដែលគាំទ្រដល់គោលនយោបាយអភិវឌ្ឍសហគមន៍កសិកម្មក្រោមវិសាលភាពនៃច្បាប់នេះ ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្មត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា ៨.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាស្ថាប័នមានសមត្ថកិច្ចក្នុងការជំរុញនិងគាំទ្រក្នុងការបង្កើត ការចុះបញ្ជី ប្រតិបត្តិការនិងការអភិវឌ្ឍរបស់សហគមន៍កសិកម្ម ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវមាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មស្ថិតនៅក្រោមអគ្គនាយកដ្ឋានកសិកម្ម ដើម្បីទទួលបន្ទុកការងារអភិវឌ្ឍន៍សហគមន៍កសិកម្មដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បំពេញសមត្ថកិច្ចក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍសហគមន៍កសិកម្ម ដោយអនុលោមតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៩.-**

ក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍសហគមន៍កសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបំពេញបេសកកម្មដូចខាងក្រោម ៖

- ជំរុញនិងគាំទ្រការប្រព្រឹត្តទៅ ការប្រតិបត្តិ និងការអភិវឌ្ឍរបស់សហគមន៍កសិកម្ម

- សិក្សា រៀបចំគោលនយោបាយ ក្របខ័ណ្ឌគតិយុត្ត ផែនការយុទ្ធសាស្ត្រ និងកម្មវិធីបណ្តុះបណ្តាលសម្រាប់ការជំរុញ ការពង្រឹងសមត្ថភាពនិងការអភិវឌ្ឍសហគមន៍កសិកម្ម

- កំណត់អង្គភាពទទួលបន្ទុកការងារចុះបញ្ជីនិងគ្រប់គ្រងទិន្នន័យសហគមន៍កសិកម្ម

- ផ្តល់សេវាកម្មបណ្តុះបណ្តាលដល់សហគមន៍កសិកម្មនិងភ្នាក់ងារអភិវឌ្ឍសហគមន៍កសិកម្ម

- អនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំ លើកកម្ពស់ការយល់ដឹងនិងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរបស់សហគមន៍កសិកម្ម

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

- កំណត់ទម្រង់បញ្ជីគណនេយ្យរបស់សហគមន៍កសិកម្ម ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សម្របសម្រួលរវាងសហគមន៍កសិកម្មជាមួយផ្នែកឯកជនឬផ្នែកពាក់ព័ន្ធផ្សេងទៀតនៅក្នុងប្រទេសឬក្រៅប្រទេស
- សិក្សានិងវាយតម្លៃស្ថានភាពសេដ្ឋកិច្ចរបស់សហគមន៍កសិកម្មដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារ ព្រមទាំងផ្តល់ព័ត៌មានទីផ្សារកសិផលដល់សហគមន៍កសិកម្ម
- ធ្វើកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិស្តីពីសហគមន៍កសិកម្ម
- ជ្រើសរើសសវនករឬអ្នកត្រួតពិនិត្យនិងអ្នកជម្រះបញ្ជីក្នុងករណីដែលសហគមន៍កសិកម្មណាមួយត្រូវបានរំលាយ
- តាមដាននិងវាយតម្លៃការប្រព្រឹត្តទៅនិងប្រតិបត្តិការរបស់សហគមន៍កសិកម្ម
- ចូលរួមដោះស្រាយរាល់ទំនាស់របស់សហគមន៍កសិកម្ម
- បំពេញភារកិច្ចផ្សេងទៀតក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍសហគមន៍កសិកម្មក្រោមវិសាលភាពនៃច្បាប់នេះ ។

**មាត្រា ១០.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍសហគមន៍កសិកម្ម ដើម្បីសិក្សាស្រាវជ្រាវនិងកសាងសមត្ថភាពបច្ចេកទេសសហគមន៍កសិកម្មក្នុងក្របខ័ណ្ឌជាតិឬអន្តរជាតិ ។

## ផ្នែកទី ៣
## មូលនិធិអភិវឌ្ឍសហគមន៍កសិកម្ម

**មាត្រា ១១.-**

ត្រូវបង្កើតមូលនិធិអភិវឌ្ឍសហគមន៍កសិកម្មដែលសរសេរជាអក្សរកាត់ថា "**ម.អ.ស.**" ដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃការគាំទ្រនិងការអភិវឌ្ឍសហគមន៍កសិកម្ម ។

មូលនិធិអភិវឌ្ឍសហគមន៍កសិកម្មត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយដែលមានរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាប្រធាន និងមានសមាជិកជាប្រធានឬតំណាងអង្គភាពពាក់ព័ន្ធចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តំណាងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា និង មានអនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មមួយរូបជាសមាជិកអចិន្ត្រៃយ៍ និងជាលេខាធិការនៃ ម.អ.ស. ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មូលនិធិអភិវឌ្ឍសហគមន៍កសិកម្មត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១២.-**

មូលនិធិអភិវឌ្ឍសហគមន៍កសិកម្មរួមមានថវិកានិងទ្រព្យសម្បត្តិដែលមានប្រភពដូចខាងក្រោម ៖

១- វិភាគទានធនពីរដ្ឋ ។

២- អំណោយសប្បុរសជនជាថវិកាឬទ្រព្យសម្បត្តិ ។

៣- ហិរញ្ញប្បទានពីរដ្ឋឬពីប្រភពផ្សេងៗទៀត ។

៤- ការលក់ទ្រព្យសម្បត្តិដែលបានមកពីចំណុច(២)និង(៣) ។

៥- ការចូលរួមវិភាគទានរបស់សហគមន៍កសិកម្មដែលទទួលបានផលប្រយោជន៍ដោយផ្ទាល់ពី **ម.អ.ស.** ។

ថវិកានិងទ្រព្យសម្បត្តិរបស់ **ម.អ.ស.** ដូចបានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះត្រូវបានរក្សាទុកក្រោមគណនីរបស់ **ម.អ.ស.** ។

## ផ្នែកទី ៤
## ស្ថាប័នពាក់ព័ន្ធចំពោះសហគមន៍កសិកម្ម

**មាត្រា ១៣.-**

ក្រសួង ស្ថាប័នរដ្ឋដែលពាក់ព័ន្ធមានភារកិច្ចជួយគាំទ្រក្នុងដែនសមត្ថកិច្ចរបស់ខ្លួនចំពោះរាល់សកម្មភាពនិងប្រតិបត្តិការរបស់សហគមន៍កសិកម្ម តាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ១៤.-**

រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ ក្រោមដែនសមត្ថកិច្ចរបស់ខ្លួនត្រូវមានភារកិច្ចជួយដល់សហគមន៍កសិកម្មដូចខាងក្រោម ៖

- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនិងបង្កលក្ខណៈងាយស្រួលដល់ការបង្កើតនិងការអភិវឌ្ឍសហគមន៍កសិកម្មនៅក្នុងមូលដ្ឋានសាមី
- បញ្ជាក់លើពាក្យស្នើសុំចុះបញ្ជីសហគមន៍កសិកម្ម
- ឧបត្ថម្ភ គាំទ្រទាំងផ្នែកស្មារតី ទាំងផ្នែកសម្ភារៈដល់ការអភិវឌ្ឍសហគមន៍កសិកម្ម
- សហការ សម្របសម្រួលជាមួយនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនិងមន្ទីរកសិកម្មក្នុង ការបង្កើតនិងការប្រព្រឹត្តទៅរបស់សហគមន៍កសិកម្ម
- ចូលរួមដោះស្រាយរាល់ទំនាស់ដែលកើតឡើងនៅក្នុងដំណើរការរបស់សហគមន៍កសិកម្ម
- ចូលរួមតាមដាននិងវាយតម្លៃលើប្រតិបត្តិការនិងការអនុវត្តច្បាប់ស្តីពីសហគមន៍កសិកម្ម ។

**មាត្រា ១៥.-**

សហគមន៍កសិកម្ម ត្រូវទទួលបានការលើកទឹកចិត្តនិងសិទ្ធិអនុគ្រោះពីរាជរដ្ឋាភិបាលដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៣
# សហគមន៍កសិកម្ម
## ផ្នែកទី ១
## ការបង្កើតនិងការចុះបញ្ជីសហគមន៍កសិកម្ម

**មាត្រា ១៦.-**

សហគមន៍កសិកម្មដែលត្រូវចុះបញ្ជីត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម ៖

១- មានសមាជិកចំនួនចាប់ពី១៥(ដប់ប្រាំ)នាក់ឡើង ដែលមានសញ្ជាតិខ្មែរនិងមានអាយុចាប់ពី១៨ឆ្នាំ ដែលរស់នៅក្នុងភូមិសាស្ត្រនៃរដ្ឋបាលភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ ជាក់លាក់នៃរាជធានី ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា និងមានមុខរបរចម្បងក្នុងក្របខ័ណ្ឌនៃប្រព័ន្ធផលិតកម្មកសិកម្ម កសិពាណិជ្ជកម្ម កសិឧស្សាហកម្ម ឬសេវាកម្មទាំងឡាយដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ។

២- មានសមាជិកចូលរួមដើមទុនដោយបង់ថ្លៃភាគហ៊ុនដែលបានទិញ ប៉ុន្តែសមាជិកម្នាក់ៗត្រូវកាន់កាប់មួយភាគហ៊ុនយ៉ាងតិច ។ ការកាន់កាប់ភាគហ៊ុនរបស់សមាជិក ត្រូវអនុលោមតាមលក្ខន្តិកៈរបស់សហគមន៍កសិកម្មសាមី ។

៣- មានប្រភេទមុខរបរសំខាន់មួយយ៉ាងតិចក្នុងក្របខ័ណ្ឌនៃប្រព័ន្ធផលិតកម្មកសិកម្ម កសិពាណិជ្ជកម្ម កសិឧស្សាហកម្ម ឬសេវាកម្មទាំងឡាយដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ។

**មាត្រា ១៧.-**

សមាជិកនៃក្រុមដែលស្នើសុំបង្កើតសហគមន៍កសិកម្មត្រូវធ្វើការជ្រើសរើស "គណៈកម្មការរៀបចំ" ក្នុង ចំណោមសមាជិកនៃក្រុម ដើម្បីសម្របសម្រួលគ្រាដំបូងក្នុងការបង្កើតសហគមន៍កសិកម្ម ព្រមទាំងរៀបចំឯកសារចាំបាច់ដើម្បីស្នើសុំចុះបញ្ជីទទួលស្គាល់សហគមន៍កសិកម្ម ។

គណៈកម្មការរៀបចំត្រូវសិក្សារៀបចំឯកសារដូចខាងក្រោម ៖

១-ប្រភេទមុខរបររបស់សហគមន៍កសិកម្មដែលត្រូវបង្កើត ។

២-ផែនការមុខជំនួញសហគមន៍កសិកម្មដែលពាក់ព័ន្ធនិងប្រភេទមុខរបរ ។

៣-បញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ ។

៤-ឈ្មោះ ស្លាកសញ្ញា និងអាសយដ្ឋានរបស់សហគមន៍កសិកម្ម ។

៥-សេចក្តីព្រាងលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍កសិកម្ម ដើម្បីដាក់ឆ្លងមហាសន្និបាតកំណើតដំបូងរបស់សហគមន៍កសិកម្ម ។

**មាត្រា ១៨.-**

គណៈកម្មការរៀបចំ ត្រូវកោះប្រជុំពេញអង្គនៃមហាសន្និបាតកំណើតដំបូង ដោយមានការចូលរួមពីសមាជិកនៃក្រុមដែលស្នើសុំបង្កើតសហគមន៍កសិកម្មដើម្បីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

ភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យសហគមន៍កសិកម្ម ព្រមទាំងអនុម័តលើសំណុំឯកសារដែលបានរៀបចំសម្រាប់ការចុះបញ្ជីសហគមន៍កសិកម្ម ។

ដំណើរការនិងលទ្ធផលនៃមហាសន្និបាតកំណើតដំបូងត្រូវកត់ត្រាជារបាយការណ៍ ដោយភ្ជាប់ជាមួយនូវបញ្ជីវត្តមាន និងហត្ថលេខាឬស្នាមមេដៃស្តាំសមាជិកចូលរួមទាំងអស់ ដែលស្នើសុំបង្កើតសហគមន៍កសិកម្ម ។

**មាត្រា ១៩.-**

ក្រោយមហាសន្និបាតកំណើតដំបូង គណៈកម្មការរៀបចំត្រូវសម្របសម្រួលជាមួយក្រុមប្រឹក្សាភិបាលជាប់ឆ្នោត ដើម្បីដាក់ពាក្យស្នើសុំការយល់ព្រមនិងចុះបញ្ជីសហគមន៍កសិកម្មនៅមន្ទីរកសិកម្មរាជធានី ខេត្តសាមីដើម្បីទទួលបាននីត្យានុកូលភាពនៃសហគមន៍កសិកម្ម ។

ពាក្យស្នើសុំចុះបញ្ជីសហគមន៍កសិកម្ម ត្រូវមានការបញ្ជាក់ត្រឹមត្រូវពីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និងអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌសាមី ព្រមទាំងភ្ជាប់ឯកសារមានដូចខាងក្រោម ៖

- របាយការណ៍មហាសន្និបាតកំណើតដំបូង
- ផែនការមុខជំនួញរបស់សហគមន៍កសិកម្មដែលស្នើសុំ
- លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍កសិកម្ម
- បញ្ជីសមាជិកក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យដោយបញ្ជាក់ពីឈ្មោះ មុខរបរ និងអាសយដ្ឋាន
- បញ្ជីសមាជិកសហគមន៍កសិកម្មនិងចំនួនភាគហ៊ុន ព្រមទាំងប្រាក់សមាជិកភាពរបស់សមាជិកម្នាក់ៗ
- គំរូហត្ថលេខាឬស្នាមមេដៃស្តាំរបស់ប្រធានក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្មឬអ្នកមានសិទ្ធិតំណាងឲ្យសហគមន៍កសិកម្ម ។

**មាត្រា ២០.-**

នៅពេលទទួលពាក្យស្នើសុំចុះបញ្ជីរបស់សហគមន៍កសិកម្ម មន្ទីរកសិកម្មរាជធានី ខេត្តសាមី ត្រូវទទួលពាក្យស្នើសុំដោយចេញបង្កាន់ដៃទទួលពាក្យស្នើសុំដោយចុះនិទ្ទេសបញ្ជាក់នូវកាលបរិច្ឆេទទទួលច្បាស់លាស់ ។

មន្ទីរកសិកម្មរាជធានី ខេត្តសាមី ត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីសហគមន៍កសិកម្មដែលបញ្ជាក់នូវការទទួលស្គាល់ជាផ្លូវការលើសំណើសុំចុះបញ្ជីសហគមន៍កសិកម្មនោះ ក្នុងរយៈពេល២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ គិតចាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំគ្រប់គ្រាន់ដោយមិនគិត កម្រៃ តែក្នុងករណីសំណុំលិខិតបទបង្កើតសហគមន៍កសិកម្មដែលស្នើសុំមានភាពសមស្របដោយ អនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ ។

ក្នុងករណីពុំមានការឆ្លើយតបក្នុងរយៈពេលកំណត់ខាងលើ សំណើសុំចុះបញ្ជីសហគមន៍កសិកម្មត្រូវចាត់ទុកថាបានយល់ព្រមជាផ្លូវការ ហើយមន្ទីរកសិកម្មរាជធានី ខេត្តសាមី ត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីឲ្យសហគមន៍កសិកម្មដោយស្វ័យប្រវត្តិ ។

**មាត្រា ២១.-**

មន្ទីរកសិកម្មរាជធានី ខេត្តសាមីមានសិទ្ធិមិនផ្តល់វិញ្ញាបនបត្រចុះបញ្ជីទទួលស្គាល់ដល់សហគមន៍កសិកម្មក្នុងករណីដែលឯកសារស្នើសុំចុះបញ្ជីមិនមានភាពសមស្រប ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ ដោយត្រូវជូនដំណឹងដល់គណៈកម្មការរៀបចំដើម្បីធ្វើការកែសម្រួលឡើងវិញក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃទទួលសេចក្តីជូនដំណឹង ។

ក្នុងករណីគណៈកម្មការរៀបចំមិនបានធ្វើការកែសម្រួលឡើងវិញក្នុងរយៈពេលកំណត់ខាងលើ មន្ទីរកសិកម្មរាជធានី ខេត្តសាមីមានសិទ្ធិបដិសេធក្នុងការចុះបញ្ជីសហគមន៍កសិកម្មនោះ ។

**មាត្រា ២២.-**

គណៈកម្មការរៀបចំមានសិទ្ធិតវ៉ាចំពោះសេចក្តីសម្រេចរបស់មន្ទីរកសិកម្មរាជធានី ខេត្តសាមីលើសំណើសុំចុះបញ្ជីសហគមន៍កសិកម្មដោយធ្វើលិខិតតវ៉ាទៅនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃជូនដំណឹងបដិសេធរបស់មន្ទីរកសិកម្មរាជធានី ខេត្តសាមី ។

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ត្រូវចេញសេចក្តីសម្រេចចុងក្រោយលើការតវ៉ារបស់គណៈកម្មការរៀបចំនៃសហគមន៍កសិកម្មដែលស្នើសុំ ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃទទួលលិខិតតវ៉ា ។

**មាត្រា ២៣.-**

គណៈកម្មការរៀបចំត្រូវរំលាយដោយស្វ័យប្រវត្តិ នៅពេលដែលសហគមន៍កសិកម្មត្រូវបានចុះបញ្ជីជាផ្លូវការ ហើយក្រុមប្រឹក្សាភិបាលនៃសហគមន៍កសិកម្មត្រូវចូលបំពេញសិទ្ធិ តួនាទី និងភារកិច្ចរបស់ខ្លួនចាប់ពីកាលបរិច្ឆេទដែលសហគមន៍កសិកម្មត្រូវបានចុះបញ្ជី ។

បុគ្គលដែលមានឈ្មោះក្នុងបញ្ជីសមាជិកសហគមន៍កសិកម្មត្រូវបំពេញតួនាទីជាសមាជិកពេញសិទ្ធិនៃសហគមន៍កសិកម្មគិតចាប់ពីកាលបរិច្ឆេទចុះបញ្ជី និងនៅពេលដែលបានបង់ប្រាក់ភាគហ៊ុននិងប្រាក់សមាជិកភាពស្របតាមកាតព្វកិច្ច ។

**មាត្រា ២៤.-**

មន្ទីរកសិកម្មរាជធានី ខេត្តសាមី ត្រូវផ្សព្វផ្សាយជាសាធារណៈចំពោះសហគមន៍កសិកម្មដែលបានចុះបញ្ជីជាផ្លូវការ ដោយត្រូវបិទផ្សាយនៅមន្ទីរកសិកម្មរាជធានី ខេត្ត ការិយាល័យកសិកម្មខណ្ឌ ក្រុង ស្រុក ព្រមទាំងសាលាខណ្ឌ ក្រុង ស្រុក និងសាលាសង្កាត់ ឃុំសាមីក្នុងរយៈពេល១៥

(ដប់ប្រាំ)ថ្ងៃគិតចាប់ពីកាលបរិច្ឆេទចុះបញ្ជីសហគមន៍កសិកម្មនិងត្រូវចម្លងជូនមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត០១(មួយ)ច្បាប់ ។

**មាត្រា ២៥.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើការផ្សព្វផ្សាយនិងជំរុញឲ្យបង្កើតសហគមន៍កសិកម្មទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញប្រកាសស្តីពីគោលការណ៍ណែនាំនីតិវិធីនៃការបង្កើតនិងការចុះបញ្ជីសហគមន៍កសិកម្ម ។

## ផ្នែកទី ២

## លក្ខន្តិកៈសហគមន៍កសិកម្ម

**មាត្រា ២៦.-**

លក្ខន្តិកៈសហគមន៍កសិកម្ម ត្រូវចែងលក្ខខណ្ឌដូចខាងក្រោម៖

- នាមករណ៍
- ស្លាកសញ្ញា ទីស្នាក់ការ និងអាសយដ្ឋាន
- ប្រភេទមុខរបរ
- ដើមទុនដែលបានមកពីភាគហ៊ុន តម្លៃភាគហ៊ុន និងលក្ខខណ្ឌនៃការបង់ភាគហ៊ុន
- លក្ខខណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុ
- លក្ខខណ្ឌនៃហិរញ្ញប្បទាននិងឥណទាន
- របៀបរបបនៃការចុះបញ្ជីគណនេយ្យនិងការគ្រប់គ្រងឯកសារនានា
- ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់សមាជិកចំពោះបំណុលរបស់សហគមន៍កសិកម្ម ។ ការទទួលខុសត្រូវនេះមិនត្រូវមានកម្រិតលើសពី៤(បួន)ដងនៃចំនួនភាគហ៊ុនដែលសមាជិកម្នាក់ៗកាន់កាប់ឡើយ
- សិទ្ធិនិងកាតព្វកិច្ចរបស់សមាជិក
- លក្ខខណ្ឌនៃការសុំចូលជាសមាជិក
- លក្ខខណ្ឌនៃការលាឈប់និងការបណ្តេញចេញពីសមាជិកភាពសហគមន៍កសិកម្ម
- ការប្រព្រឹត្តទៅរបស់មហាសន្និបាតនិងមហាសន្និបាតតំណាង
- សមាសភាពក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ
- លក្ខខណ្ឌនៃការកោះប្រជុំក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ
- តួនាទីនិងភារកិច្ចរបស់ក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ
- លក្ខខណ្ឌនៃការបញ្ចូលគ្នារបស់សហគមន៍កសិកម្ម

- លក្ខខណ្ឌនៃការរំលាយសហគមន៍កសិកម្ម
- នីតិវិធីដោះស្រាយវិវាទនៅក្នុងសហគមន៍កសិកម្ម
- នីតិវិធីនៃការកែប្រែឬវិសោធនកម្មលក្ខន្តិកៈ
- នីតិវិធីផ្សេងទៀតដែលត្រូវសម្រេចដោយមហាសន្និបាតឬមហាសន្និបាតតំណាង។

**មាត្រា ២៧.-**

ក្នុងករណីដែលសហគមន៍កសិកម្មធ្វើវិសោធនកម្មលក្ខន្តិកៈរបស់ខ្លួន សហគមន៍កសិកម្មនោះត្រូវដាក់លក្ខន្តិកៈថ្មីជូនមន្ទីរកសិកម្មរាជធានី ខេត្តសាមីជាថ្មីក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃសម្រេចរបស់មហាសន្និបាត ។ ក្នុងករណីដែលមានការប្តូរនាមករណ៍សហគមន៍កសិកម្មនោះ ត្រូវប្រគល់វិញ្ញាបនបត្រចុះបញ្ជីឲ្យមន្ទីរកសិកម្មរាជធានី ខេត្តសាមីវិញដើម្បីទទួលយកវិញ្ញាបនបត្រ ចុះបញ្ជីថ្មីដែលមាននាមករណ៍ថ្មី ។

**មាត្រា ២៨.-**

សហគមន៍កសិកម្ម ត្រូវបង្កើតបទបញ្ជាផ្ទៃក្នុងដើម្បីគ្រប់គ្រងប្រតិបត្តិការមុខរបររបស់ខ្លួន ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចេញប្រកាសស្តីពីលក្ខន្តិកៈគំរូនិងបទបញ្ជាផ្ទៃក្នុងគំរូសម្រាប់សហគមន៍កសិកម្ម ។

## ជំពូកទី ៣
## សិទ្ធិនិងភារកិច្ចរបស់សមាជិកសហគមន៍កសិកម្ម

**មាត្រា ២៩.-**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលមានអាយុ១៨ (ដប់ប្រាំបី) ឆ្នាំឡើង មានសិទ្ធិដាក់ពាក្យសុំចូលជាសមាជិកសហគមន៍កសិកម្មបានដោយស្ម័គ្រចិត្ត ដោយត្រូវមានលក្ខខណ្ឌដូចខាងក្រោម ៖

- មានមុខរបរចម្បងក្នុងក្របខ័ណ្ឌនៃប្រព័ន្ធផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម
- ទិញភាគហ៊ុន
- បង់ប្រាក់សមាជិកភាព
- គោរពបទប្បញ្ញត្តិនៃច្បាប់នេះ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចនានារបស់មហាសន្និបាតនៃសហគមន៍កសិកម្ម។

**មាត្រា ៣០.-**

សមាជិកសហគមន៍កសិកម្ម ត្រូវបង់ប្រាក់ភាគហ៊ុនដែលខ្លួនបានទិញស្របតាមលក្ខខណ្ឌដូចមានចែងក្នុងលក្ខន្តិកៈ ។ សមាជិកនីមួយៗត្រូវទទួលខុសត្រូវរៀងៗខ្លួនផងនិងរួមគ្នាផងចំពោះ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

បំណុលរបស់សហគមន៍កសិកម្មក្នុងកម្រិតដូចមានចែងក្នុងលក្ខន្តិកៈ ដែលជាការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់ខ្លួនចំពោះសហគមន៍កសិកម្ម ។

**មាត្រា ៣១.-**

សមាជិកសហគមន៍កសិកម្មមានសិទ្ធិនិងកាតព្វកិច្ចដូចខាងក្រោម ៖

- ចូលរួមមហាសន្និបាតនិងបោះឆ្នោតដោយស្មើភាពគ្នាជាមួយសមាជិកដទៃទៀតដោយពុំគិតពីកម្រិតភាគហ៊ុនដែលកាន់កាប់នៅក្នុងសហគមន៍កសិកម្មឡើយ
- អនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាត
- បោះឆ្នោតនិងឈរឈ្មោះក្នុងរចនាសម្ព័ន្ធសហគមន៍កសិកម្មដោយអនុលោមតាមបទប្បញ្ញត្តិ នៃច្បាប់នេះ
- ទទួលព័ត៌មាន អំពីស្ថានភាពហិរញ្ញវត្ថុរបស់សហគមន៍កសិកម្ម និងទីផ្សារកសិកម្មពីក្រុមប្រឹក្សាភិបាលឬគណៈកម្មាធិការត្រួតពិនិត្យ
- ស្នើសុំការកោះប្រជុំមហាសន្និបាតវិសាមញ្ញដើម្បីពិភាក្សាដោះស្រាយបញ្ហាចាំបាច់ណាមួយដោយអនុលោមតាមលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងនៃសហគមន៍កសិកម្ម ប្រសិនបើមានសមាជិកចំនួន១ភាគ៣ (មួយភាគបី) នៃសមាជិកសហគមន៍កសិកម្មទាំងអស់ឯកភាពគ្នាស្នើសុំ
- ធ្វើសំណើឲ្យដាក់ចូលក្នុងរបៀបវារៈនៃមហាសន្និបាតនូវបញ្ហាដែលមានសារៈសំខាន់សម្រាប់សហគមន៍កសិកម្ម
- ទទួលភាគចំណេញរៀងៗខ្លួន
- ជួលឬប្រើប្រាស់សេវានិងមធ្យោបាយបរិក្ខាររបស់សហគមន៍កសិកម្មដូចសមាជិកដទៃទៀត
- ចូលរួមគ្រប់សកម្មភាពរបស់សហគមន៍កសិកម្ម
- ស្នើសុំលាឈប់ពីសមាជិកភាពនៃសហគមន៍កសិកម្មបាន ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាភិបាល ដោយអនុលោមតាមការកំណត់ដាក់ស្តែងក្នុងលក្ខន្តិកៈរបស់សហគមន៍កសិកម្មសាមី
- ទទួលបាននូវភាគហ៊ុនដែលបានបង់គ្រប់ចំនួនបូកនឹងការប្រាក់ស្របតាមការកំណត់ក្នុងលក្ខន្តិកៈ នៅពេលដែលសមាជិកសុំលាឈប់ឬត្រូវបណ្តេញចេញ ។ ក្នុងករណីដែលសហគមន៍កសិកម្មមានការខាតបង់ សមាជិកដែលសុំលាឈប់ឬត្រូវបណ្តេញចេញត្រូវទទួលបន្ទុកបង់ខាតតាមសមាមាត្រនៃភាគហ៊ុនដែលខ្លួនកាន់កាប់ ដោយអនុលោមតាមការកំណត់ក្នុងលក្ខន្តិកៈ ។

**មាត្រា ៣២.-**

សមាជិកសហគមន៍កសិកម្មណាម្នាក់ដែលខកខានក្នុងការបង់គ្រប់ចំនួននូវប្រាក់ភាគហ៊ុន និងកាតព្វកិច្ចសមាជិកភាពដែលតម្រូវដោយលក្ខន្តិកៈ សមាជិកនោះពុំអាចប្រើប្រាស់សិទ្ធិនិងទទួលផលប្រយោជន៍ពីសហគមន៍កសិកម្មឡើយ ។

**មាត្រា ៣៣.-**

ក្នុងករណីមានសមាជិកសហគមន៍កសិកម្មណាម្នាក់ ធ្វើឲ្យមានការប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍សហគមន៍កសិកម្មឬសមាជិកដទៃទៀតនៃសហគមន៍កសិកម្ម សមាជិករូបនោះអាចត្រូវបានព្យួរសមាជិកភាពឬត្រូវបានបណ្តេញចេញពីសហគមន៍កសិកម្មក្រោយពីបានការពារខ្លួននៅចំពោះមុខក្រុមប្រឹក្សាភិបាល ។ ការបណ្តេញចេញពីសហគមន៍កសិកម្ម ត្រូវសម្រេចដោយមហាសន្និបាត ។ ក្នុងករណីមានការប្រញាប់ ក្រុមប្រឹក្សាភិបាលអាចប្រកាសជាបណ្តោះអាសន្ននូវការព្យួរសមាជិកភាពបាន តែត្រូវមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញជាបន្ទាន់ដើម្បីពិភាក្សា និងសម្រេចលើករណីរក្សាទុកសមាជិកភាពឬបណ្តេញចេញសមាជិករូបនោះពីសហគមន៍កសិកម្ម ។

**មាត្រា ៣៤.-**

សមាជិកភាពសហគមន៍កសិកម្មត្រូវបានបញ្ចប់ក្នុងករណីណាមួយដូចខាងក្រោម ៖

- សហគមន៍កសិកម្មត្រូវបានក្ស័យធនឬត្រូវបានរំលាយ
- សមាជិកស្លាប់ឬបាត់ខ្លួនដោយអនុលោមតាមលក្ខន្តិកៈរបស់សហគមន៍កសិកម្ម
- សមាជិកដែលផ្ទេរភាគហ៊ុនទាំងស្រុងទៅសមាជិកផ្សេងទៀត
- សមាជិកដែលត្រូវបណ្តេញចេញពីសហគមន៍កសិកម្មដោយអនុលោមតាមសេចក្តីសម្រេចរបស់មហាសន្និបាត
- ករណីផ្សេងទៀតដូចមានចែងក្នុងលក្ខន្តិកៈ ។

## ផ្នែកទី ៤
## សិទ្ធិ ភារកិច្ច និងការប្រព្រឹត្តទៅរបស់សហគមន៍កសិកម្ម
## អនុផ្នែកទី ១ ៖ សិទ្ធិនិងភារកិច្ចរបស់សហគមន៍កសិកម្ម

**មាត្រា ៣៥.-**

សហគមន៍កសិកម្មមានសិទ្ធិនិងភារកិច្ចដូចខាងក្រោម ៖

១- ធ្វើប្រតិបត្តិការលើមុខរបររបស់ខ្លួនក្នុងក្របខ័ណ្ឌផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្មឬសេវាកម្មពាក់ព័ន្ធផ្សេងទៀតដើម្បីផលចំណេញជូនសមាជិក។

២- ជាតំណាងឲ្យសមាជិកដើម្បីចុះកិច្ចសន្យានិងអនុវត្តកិច្ចសន្យាជាមួយផ្នែកឯកជនឬដៃគូអភិវឌ្ឍផ្សេងទៀត។

៣- ធានាសិទ្ធិរបស់សមាជិកក្នុងការចូលរួមបំពេញគោលដៅសេដ្ឋកិច្ច សង្គម និងវប្បធម៌ ។

៤- ផ្តល់ជំនួយបច្ចេកទេស អប់រំបណ្តុះបណ្តាល លើកកម្ពស់សមត្ថភាពរបស់សមាជិកនិងផ្តល់ព័ត៌មានទាំងឡាយដល់សមាជិក ដើម្បីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចរបស់សហគមន៍កសិកម្ម ។

៥- ស្នើសុំឬទទួលយកជំនួយបច្ចេកទេសឬជំនួយហិរញ្ញវត្ថុពីរាជរដ្ឋាភិបាល និងប្រភពជំនួយស្របច្បាប់ផ្សេងទៀត។

៦- ធ្វើការគ្រប់គ្រងហិរញ្ញកិច្ច គណនេយ្យកិច្ច ការត្រួតពិនិត្យបញ្ជី ការរក្សានិងការបង្កើនដើមទុននិងធនធានដទៃទៀតរបស់សហគមន៍កសិកម្ម អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

៧- បង់ពន្ធនិងបំពេញកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងទៀតដោយអនុលោមតាមបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់ជាធរមាន ។

៨- បំពេញកាតព្វកិច្ចផ្សេងទៀតដែលពាក់ព័ន្ធនឹងគោលដៅរបស់សហគមន៍កសិកម្ម ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចេញប្រកាសស្តីពីគោលការណ៍ណែនាំនៃកិច្ចសន្យាសម្រាប់ប្រតិបត្តិការមុខរបររបស់សហគមន៍កសិកម្ម ។

**មាត្រា ៣៦.-**

សហគមន៍កសិកម្មត្រូវរក្សាទុកឯកសារឬបញ្ជីនៅទីស្នាក់ការរបស់ខ្លួននិងនៅកន្លែងផ្សេងទៀតតាមការកំណត់របស់ច្បាប់។ ឯកសារឬបញ្ជីដែលត្រូវរក្សាទុកមានដូចខាងក្រោម ៖

១- លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍កសិកម្ម ។

២- បញ្ជីសមាជិកសហគមន៍កសិកម្មរួមមាន ៖

- ឈ្មោះនិងអាសយដ្ឋានទីស្នាក់ការរបស់សហគមន៍កសិកម្ម
- ឈ្មោះ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋានរបស់សមាជិក
- កាលបរិច្ឆេទចូលជាសមាជិកភាព ។

៣- បញ្ជីភាគហ៊ុនរបស់សមាជិករួមមាន៖

- ឈ្មោះនិងអាសយដ្ឋានទីស្នាក់ការរបស់សហគមន៍កសិកម្ម
- ឈ្មោះសមាជិកដែលកាន់កាប់ភាគហ៊ុន តម្លៃភាគហ៊ុន ចំនួនភាគហ៊ុន និងភាគហ៊ុនដែលបានបង់ ។

៤- តារាងតុល្យការប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម ។

៥- របាយការណ៍ប្រចាំឆ្នាំរបស់សហគមន៍កសិកម្មអំពីលទ្ធផលនៃប្រតិបត្តិការមុខរបររបស់ខ្លួន ។

៦- កំណត់ហេតុនៃកិច្ចប្រជុំនិងរបាយការណ៍គ្រប់ប្រភេទ ។

៧- ឯកសារផ្សេងៗទៀតរបស់សហគមន៍កសិកម្ម។

## អនុផ្នែកទី ២ ៖ មហាសន្និបាតនៃសហគមន៍កសិកម្ម

**មាត្រា ៣៧.-**

មហាសន្និបាតជាអង្គការខ្ពស់បំផុតរបស់សហគមន៍កសិកម្មដែលមានភារកិច្ចធ្វើការអនុម័តនិងធ្វើសេចក្តីសម្រេចចិត្តទាំងឡាយក្នុងដំណើរការបង្កើតនិងការប្រព្រឹត្តទៅរបស់សហគមន៍កសិកម្ម

ដែលរួមមាន មហាសន្និបាតកំណើតដំបូង មហាសន្និបាតប្រចាំឆ្នាំ មហាសន្និបាតតំណាង និងមហា-សន្និបាតវិសាមញ្ញ ។

មហាសន្និបាតសហគមន៍កសិកម្មមានភារកិច្ចដូចខាងក្រោម ៖

- អនុម័តឬធ្វើវិសោធនកម្មលើលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង

- បោះឆ្នោតជ្រើសតាំងក្នុងចំណោមសមាជិកសហគមន៍កសិកម្មនូវប្រធាននិងសមាជិកដទៃទៀតរបស់ក្រុមប្រឹក្សាភិបាល និងសមាជិកគណៈកម្មាធិការត្រួតពិនិត្យតាមការបោះឆ្នោតជាសម្ងាត់

- បោះឆ្នោតដកតំណែងពីអ្នកដែលជាប់ឆ្នោតទាំងនោះវិញនិងកំណត់លាភការជូនអ្នកទាំងនោះ ប្រសិនបើមាន

- កំណត់ភារកិច្ចក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ

- ជ្រើសរើសសវនករឬអ្នកត្រួតពិនិត្យនិងអនុម័តយល់ព្រមលើរបាយការណ៍សវនកម្មរបស់សហគមន៍កសិកម្ម

- កំណត់កម្រិតអតិបរមានៃបំណុលដែលសហគមន៍កសិកម្មអាចខ្ចីបានសម្រាប់កម្មវត្ថុ របស់ខ្លួនដោយរក្សានូវស្វ័យភាពរបស់សហគមន៍កសិកម្ម

- អនុញ្ញាតការវិនិយោគ ការចុះកិច្ចសន្យា ការចងការ និងការកៀរគរមូលនិធិសហគមន៍កសិកម្ម

- កំណត់បែបបទ ចំនួនទឹកប្រាក់ និងអត្រាការប្រាក់ដែលអនុញ្ញាតឲ្យសមាជិកខ្ចី

- អនុម័តលើប្រាក់ចំណេញសុទ្ធនៃឆ្នាំនីមួយៗ ក្រោយពេលបានដកប្រាក់ពីប្រាក់ចំណេញសរុបនៃឆ្នាំដើម្បីដាក់បញ្ចូលទៅក្នុងមូលនិធិបម្រុង មូលនិធិបណ្តុះបណ្តាល និងក្នុងមូលនិធិផ្សេងទៀត ស្របតាមលក្ខន្តិកៈរបស់សហគមន៍កសិកម្មសាមី និងទូទាត់បំណុលរបស់សហគមន៍កសិកម្មនៃឆ្នាំកន្លងមក

- កំណត់ពីការបែងចែកប្រាក់ចំណេញសុទ្ធដល់សមាជិកសហគមន៍កសិកម្ម

- ធ្វើឲ្យមានលំនឹងឡើងវិញចំពោះការបែងចែកភាគហ៊ុនទៅឲ្យសមាជិកម្នាក់ៗ ក្នុងករណីចំនួនសមាជិកប្រែប្រួល

- ពិនិត្យនិងអនុម័តលើតារាងតុល្យការនិងរបាយការណ៍ស្តីពីលទ្ធផលនៃប្រតិបត្តិការមុខរបររបស់សហគមន៍កសិកម្ម

- ពិភាក្សា អនុម័តលើរបាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មាធិការត្រួតពិនិត្យបន្ទាប់ពីបានត្រួតពិនិត្យរួច

- ផ្តល់ការយល់ព្រមលើកំណត់ហេតុអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលឬគណៈកម្មាធិការត្រួតពិនិត្យ

- អនុម័តលើរបាយការណ៍ជម្រះបញ្ជីរបស់សហគមន៍កសិកម្ម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- អនុម័តយល់ព្រមលើផែនការសកម្មភាពនិងផែនការហិរញ្ញវត្ថុរបស់សហគមន៍កសិកម្មសម្រាប់ការិយបរិច្ឆេទបន្ទាប់

- សម្រេចលើការសុំចូលជាសមាជិកថ្មី ការព្យួរនិងការបណ្តេញចេញសមាជិកនីមួយៗ

- សម្រេចលើការផ្លាស់ប្តូរនានា ដូចជាការបំបែក ការបញ្ចូលគ្នា ឬការរំលាយសហគមន៍កសិកម្ម

- ពិនិត្យអនុម័តឬសម្រេចលើការងារផ្សេងទៀតក្នុងក្របខ័ណ្ឌនៃការប្រព្រឹត្តទៅរបស់សហគមន៍កសិកម្ម ។

**មាត្រា ៣៨.-**

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍កសិកម្មមានភារកិច្ចធ្វើសេចក្តីសម្រេចលើឯកសារសំខាន់ៗនិងការតម្រូវ ដូចមានចែងនៅក្នុងមាត្រា១៧ និង១៨ នៃច្បាប់នេះ ដើម្បីស្នើសុំការចុះបញ្ជីនិងដាក់ឲ្យដំណើរការនៃការិយបរិច្ឆេទសហគមន៍កសិកម្ម ។

**មាត្រា ៣៩.-**

មហាសន្និបាតរបស់សហគមន៍កសិកម្មត្រូវរៀបចំឡើងមួយឆ្នាំម្តងនិងមានភារកិច្ចសំខាន់ៗមួយចំនួនដូចជាបូកសរុបលទ្ធផលប្រតិបត្តិការមុខរបរប្រចាំឆ្នាំ បង្ហាញពីតារាងតុល្យការ បែងចែកផលចំណេញ អនុម័តប្រតិបត្តិការមុខរបរសម្រាប់ឆ្នាំថ្មី អនុម័តលើការសុំលាឈប់របស់សមាជិកចាស់ អនុម័តការសុំចូលជាសមាជិកថ្មី ធ្វើវិសោធនកម្មលក្ខន្តិកៈ ពិនិត្យពិភាក្សានិងអនុម័តកិច្ចការផ្សេងទៀត ។

**មាត្រា ៤០.-**

ក្នុងករណីដែលសហគមន៍កសិកម្មមានសមាជិកលើសពី២០០(ពីររយ)នាក់ សហគមន៍កសិកម្មអាចជ្រើសរើសប្រតិភូតំណាងឲ្យចូលរួមមហាសន្និបាតដែលក្នុងករណីនេះហៅថាមហាសន្និបាតតំណាង ។

**មាត្រា ៤១.-**

មហាសន្និបាតវិសាមញ្ញរបស់សហគមន៍កសិកម្មមានភារកិច្ចសំខាន់សម្រាប់ដោះស្រាយបញ្ហាបន្ទាន់អ្វីមួយ ដែលអាចប្រព្រឹត្តទៅច្រើនដងក្នុងមួយឆ្នាំ អាស្រ័យតាមស្ថានភាពតម្រូវរបស់សហគមន៍កសិកម្មសាមី ។

មហាសន្និបាតវិសាមញ្ញអាចកោះប្រជុំបានដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ ។

**មាត្រា ៤២.-**

ការកោះប្រជុំមហាសន្និបាត ត្រូវធ្វើដោយប្រធានក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្មដោយត្រូវកំណត់ពីទីកន្លែង កាលបរិច្ឆេទ និងរបៀបវារៈ ហើយត្រូវជូនដំណឹងដល់គ្រប់សមាជិកឲ្យបាន

យ៉ាងតិច១០ (ដប់) ថ្ងៃមុន ។ សេចក្តីជូនដំណឹងត្រូវធ្វើតាមរបៀបផ្សព្វផ្សាយព័ត៌មានធម្មតាហើយត្រូវបិទប្រកាសនៅទីស្នាក់ការសហគមន៍កសិកម្មសាមី ។

មហាសន្និបាតអាចប្រជុំពិភាក្សា អនុម័ត និងសម្រេចបាន លុះត្រាតែមានកូរ៉ុម២ភាគ៣ (ពីរភាគបី) នៃចំនួនសមាជិកសហគមន៍កសិកម្មទាំងមូល ។ ក្នុងករណីដែលលក្ខខណ្ឌខាងលើពុំអាចបំពេញបាន ការកោះប្រជុំមហាសន្និបាតជាលើកទី២ លើរបៀបវារៈដដែលត្រូវធ្វើឡើងក្នុងរយៈពេល ១០ (ដប់) ថ្ងៃបន្ទាប់ពីថ្ងៃកំណត់នៃកិច្ចប្រជុំលើកទី១ ។ កិច្ចប្រជុំលើកទី២នេះ ពុំកំណត់ចំនួនកូរ៉ុមឡើយ ។

មហាសន្និបាតត្រូវដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល ឬដោយប្រធានអង្គប្រជុំដែលត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមសមាជិកវត្តមាន ។ មហាសន្និបាតត្រូវតែងតាំងលេខាធិការអង្គប្រជុំម្នាក់ដើម្បីធ្វើកំណត់ហេតុដោយបញ្ជាក់អំពីសេចក្តីសម្រេចរបស់មហាសន្និបាតនិងភ្ជាប់បញ្ជីវត្តមានសមាជិកចូលរួមផង ហើយលេខាធិការនិងប្រធានអង្គប្រជុំត្រូវចុះហត្ថលេខាលើកំណត់ហេតុនោះ ។

**មាត្រា ៤៣.-**

សមាជិកម្នាក់មានសំឡេងតែមួយគត់នៅក្នុងមហាសន្និបាត ហើយមិនអាចជំនួសដោយតំណាងឬសមាជិកគ្រួសារដែលគ្មានការទទួលខុសត្រូវលើសិទ្ធិសម្រេចរបស់ខ្លួនឡើយ ។

សេចក្តីសម្រេចដែលទាក់ទងនឹងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ការបំបែក ការបញ្ចូលសហគមន៍កសិកម្ម ឬការបណ្តេញចេញសមាជិកណាមួយ ត្រូវមានការយល់ព្រមតាមសំឡេង២ភាគ៣ (ពីរភាគបី) នៃសមាជិកវត្តមាន ។ សេចក្តីសម្រេចផ្សេងៗទៀតរបស់មហាសន្និបាតត្រូវយកសំឡេងភាគច្រើននៃសមាជិកវត្តមានទាំងអស់ ។

## អនុផ្នែកទី ៣ ៖ ក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្ម

**មាត្រា ៤៤.-**

ក្រុមប្រឹក្សាភិបាលជាអង្គការប្រតិបត្តិរបស់សហគមន៍កសិកម្ម ។ ប្រធាននិងសមាជិកទាំងអស់នៃក្រុមប្រឹក្សាភិបាលត្រូវបានបោះឆ្នោតជ្រើសរើសដោយមហាសន្និបាត ។ សមាសភាពនៃក្រុមប្រឹក្សាភិបាលមានចំនួនសេសចាប់ពី៣ (បី) រូបឡើងទៅ រួមទាំងប្រធានផង ដោយផ្អែកលើចំនួននៃសមាជិក និងប្រតិបត្តិការមុខរបរជាក់ស្តែងរបស់សហគមន៍កសិកម្មដែលត្រូវកំណត់នៅក្នុងលក្ខន្តិកៈ របស់សហគមន៍កសិកម្ម ។ ប្តីប្រពន្ធ ឪពុកម្តាយបង្កើត ឪពុកម្តាយក្មេក និងកូនបង្កើត ពុំអាចធ្វើជាសមាជិកក្រុមប្រឹក្សាភិបាលជាមួយគ្នាបានឡើយ ។

សមាជិកក្រុមប្រឹក្សាភិបាលត្រូវបានបោះឆ្នោតជ្រើសរើសដោយមហាសន្និបាតសម្រាប់អាណត្តិ៥ (ប្រាំ) ឆ្នាំ ។

សមាជិកក្រុមប្រឹក្សាភិបាលចាស់អាចឈរឈ្មោះឲ្យគេបោះឆ្នោតឡើងវិញបានដោយអនុលោមតាមលក្ខន្តិកៈរបស់សហគមន៍កសិកម្មសាមី ។

**មាត្រា ៤៥.-**

ក្រុមប្រឹក្សាភិបាលដែលជាប់ឆ្នោតត្រូវធ្វើការជ្រើសតាំងហេរញ្ញិកម្នាក់និងលេខាធិការម្នាក់ក្នុងចំណោមសមាជិករបស់ខ្លួន ។ ក្នុងករណីមិនអាចធ្វើការជ្រើសតាំងពីក្នុងចំណោមសមាជិករបស់ខ្លួនបាន ក្រុមប្រឹក្សាភិបាលអាចធ្វើការជ្រើសតាំង យកចេញពីសមាជិកសហគមន៍កសិកម្មបាន ។

ប្រធានក្រុមប្រឹក្សាភិបាលជាអ្នកតំណាងរបស់សហគមន៍កសិកម្មនិងមានភារកិច្ចកោះប្រជុំក្រុមប្រឹក្សាភិបាលក្នុងរយៈពេលមួយខែម្តង ឬអាចកោះប្រជុំវិសាមញ្ញតាមការចាំបាច់ ។ ក្រុមប្រឹក្សាភិបាលអាចធ្វើការប្រជុំនិងអនុម័តបញ្ហាណាមួយបាន លុះត្រាតែមានកូរ៉ុម២ភាគ៣ (ពីរភាគបី) នៃសមាជិករបស់ខ្លួន ។

សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាលទុកជាបានការ លុះត្រាតែមានការអនុម័តតាមសំឡេងភាគច្រើននៃអង្គប្រជុំ ។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានមានឧត្តមានុភាព ។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចមានការចូលរួមពីសមាជិកគណៈកម្មាធិការត្រួតពិនិត្យ ។

**មាត្រា ៤៦.-**

សមាជិកក្រុមប្រឹក្សាភិបាលត្រូវចូលរួមជាប្រចាំនៅក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាលរបស់ខ្លួន ។ ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់អវត្តមានដោយពុំមានមូលហេតុចំនួន៣ (បី) ដងជាប់ៗគ្នា សមាជិកនោះត្រូវបញ្ឈប់តួនាទីជាបណ្តោះអាសន្នពីសមាជិកក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្ម ។

មហាសន្និបាតបន្ទាប់ ត្រូវពិនិត្យសម្រេចលើសមាជិកភាពរបស់សមាជិកក្រុមប្រឹក្សាភិបាលដែលបានបញ្ឈប់តួនាទីជាបណ្តោះអាសន្ននោះ ។

**មាត្រា ៤៧.-**

ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ លក្ខន្តិកៈ និងសេចក្តីសម្រេចនានានៃមហាសន្និបាត ក្រុមប្រឹក្សាភិបាលទទួលអំណាចទូលំទូលាយក្នុងកិច្ចការដឹកនាំនិងការគ្រប់គ្រងសហគមន៍កសិកម្មនិងត្រូវបំពេញភារកិច្ចនិងកាតព្វកិច្ចដូចខាងក្រោម ៖

- ទទួលខុសត្រូវចំពោះការគ្រប់គ្រងហិរញ្ញវត្ថុស្របតាមទម្រង់គណនេយ្យសម្រាប់សហគមន៍កសិកម្ម
- រៀបចំប្រជុំមហាសន្និបាត
- ដាក់របាយការណ៍ប្រចាំឆ្នាំដែលបញ្ជាក់ដោយគណៈកម្មាធិការត្រួតពិនិត្យនិងតារាងតុល្យការជូនមហាសន្និបាត

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

- ដាក់ផែនការសកម្មភាពដែលរួមមានសកម្មភាពបណ្ដុះបណ្ដាលសមាជិកនិងបុគ្គលិក និងដាក់ផែនការហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទខាងមុខជូនមហាសន្និបាត
- រៀបចំឯកសារចាំបាច់សម្រាប់សវនកម្មដែលច្បាប់តម្រូវ ព្រមទាំងរាយការណ៍ជូនមហាសន្និបាត
- រៀបចំប្រជុំមហាសន្និបាតវិសាមញ្ញរបស់សហគមន៍កសិកម្ម ក្នុងករណីចាំបាច់
- ផ្ញើរបាយការណ៍ប្រចាំឆ្នាំនិងតារាងតុល្យការដល់អង្គភាពចុះបញ្ជីរបស់ខ្លួន
- គ្រប់គ្រងទ្រព្យសម្បត្តិរបស់សហគមន៍កសិកម្ម
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់មហាសន្និបាតសហគមន៍កសិកម្ម ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញប្រកាសស្តីពីទម្រង់បញ្ជីគណនេយ្យគំរូសម្រាប់សហគមន៍កសិកម្ម ។

**មាត្រា ៤៨.-**

ក្រុមប្រឹក្សាភិបាលអាចជ្រើសរើសនាយកប្រតិបត្តិជាប់កិច្ចសន្យាម្នាក់ដែលអាចជាសមាជិក ឬមិនមែនជាសមាជិករបស់សហគមន៍កសិកម្ម តែមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាលឬមិនមែនជាសមាជិកគណៈកម្មាធិការត្រួតពិនិត្យរបស់សហគមន៍កសិកម្មដែលមានវិជ្ជាជីវៈជំនាញដើម្បីបំពេញភារកិច្ចជាជំនួយការក្រុមប្រឹក្សាភិបាលក្នុងការគ្រប់គ្រងប្រតិបត្តិការមុខរបររបស់សហគមន៍កសិកម្ម ។

នាយកប្រតិបត្តិអាចចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ដោយមានសិទ្ធិត្រឹមតែប្រឹក្សាយោបល់ប៉ុណ្ណោះ ។

នាយកប្រតិបត្តិត្រូវទទួលប្រាក់បៀវត្សនិងត្រូវគោរពលក្ខខណ្ឌទាំងឡាយដែលមានចុះនៅក្នុងកិច្ចសន្យាជាលាយលក្ខណ៍អក្សរក្នុងការអនុវត្តភារកិច្ចដែលក្រុមប្រឹក្សាភិបាលប្រគល់ឲ្យ ព្រមទាំងត្រូវទទួលខុសត្រូវចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តនៅពេលបំពេញភារកិច្ច ។

**មាត្រា ៤៩.-**

ក្រុមប្រឹក្សាភិបាលអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាតាមការចាំបាច់ដើម្បីបម្រើការងារក្នុងប្រតិបត្តិការមុខរបររបស់សហគមន៍កសិកម្មដោយអនុលោមតាមច្បាប់ស្តីពីការងារ ។

សមាជិកក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវរៀងៗខ្លួនផង រួមគ្នាផងចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញភារកិច្ច ដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ ។

## អនុផ្នែកទី ៤ ៖ គណៈកម្មាធិការត្រួតពិនិត្យសហគមន៍កសិកម្ម

**មាត្រា ៥០.-**

គណៈកម្មាធិការត្រួតពិនិត្យជាអង្គការត្រួតពិនិត្យអចិន្ត្រៃយ៍ផ្ទៃក្នុងរបស់សហគមន៍កសិកម្ម ដែលមានភារកិច្ចត្រួតពិនិត្យសកម្មភាពរបស់ក្រុមប្រឹក្សាភិបាលនិងនាយកប្រតិបត្តិដើម្បីរក្សា គណនេយ្យ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

កាពដល់សមាជិករបស់សហគមន៍កសិកម្ម ។ គណៈកម្មាធិការត្រួតពិនិត្យត្រូវបោះឆ្នោត ជ្រើសរើសដោយមហាសន្និបាត ។ ប្រធានគណៈកម្មាធិការត្រួតពិនិត្យត្រូវបោះឆ្នោតជ្រើសរើសក្នុងចំណោមសមាជិករបស់ខ្លួន ។

គណៈកម្មាធិការត្រួតពិនិត្យមានសមាជិកពី៣ (បី) ទៅ៥ (ប្រាំ) រូប ដែលមិនមែនជាប្តីប្រពន្ធ ឪពុកម្តាយបង្កើត ឪពុកម្តាយក្មេក និងកូនបង្កើតរបស់សមាជិកណាមួយនៃក្រុមប្រឹក្សាភិបាលនិងមិនមែនជាបុគ្គលិកមានបៀវត្សរបស់សហគមន៍កសិកម្មឡើយ ។

សមាជិកគណៈកម្មាធិការត្រួតពិនិត្យត្រូវបានបោះឆ្នោតជ្រើសរើសដោយមហាសន្និបាតសម្រាប់អាណត្តិ៥ (ប្រាំ) ឆ្នាំ ។

សមាជិកគណៈកម្មាធិការត្រួតពិនិត្យចាស់មានសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតឡើងវិញបានដោយអនុលោមតាមលក្ខន្តិកៈរបស់សហគមន៍កសិកម្មសាមី ។

**មាត្រា ៥១.-**

គណៈកម្មាធិការត្រួតពិនិត្យត្រូវបើកកិច្ចប្រជុំតាមការកោះប្រជុំរបស់ប្រធានឬតាមសំណើរបស់សមាជិកយ៉ាងតិច ២ភាគ៣ (ពីរភាគបី) ។ ក្នុងករណីមានសំឡេងស្មើគ្នាក្នុងអង្គប្រជុំ សំឡេងរបស់ប្រធានមានឧត្តមានុភាព ។ សមាជិកគណៈកម្មាធិការត្រួតពិនិត្យអាចចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សា-ភិបាល ដោយមានសិទ្ធិត្រឹមតែផ្តល់យោបល់ប៉ុណ្ណោះ ។

**មាត្រា ៥២.-**

គណៈកម្មាធិការត្រួតពិនិត្យមានសិទ្ធិនិងភារកិច្ចដូចខាងក្រោម ៖

- ត្រួតពិនិត្យឬបញ្ជាឲ្យត្រួតពិនិត្យបញ្ជីគណនេយ្យរបស់សហគមន៍កសិកម្ម
- ត្រួតពិនិត្យលើបញ្ជីសារពើភណ្ឌនិងតារាងតុល្យការតាមការចាំបាច់
- ត្រូវជូនព័ត៌មានស្តីពីសភាពការណ៍ដែលខ្លួនបានកត់សម្គាល់ទៅក្រុមប្រឹក្សាភិបាល ហើយរៀបរាប់អំពីបញ្ហានេះក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនជូនមហាសន្និបាត ។

ក្នុងករណីមានបញ្ហាបន្ទាន់ជាក់លាក់ណាមួយឬសមាជិកក្រុមប្រឹក្សាភិបាលភាគច្រើនស្ថិតក្នុងស្ថានភាពអលទ្ធភាពក្នុងការបំពេញភារកិច្ចនិងភារកិច្ចរបស់ខ្លួន គណៈកម្មាធិការត្រួតពិនិត្យមានសិទ្ធិស្នើឲ្យប្រធានក្រុមប្រឹក្សាភិបាលកោះប្រជុំឬបើកមហាសន្និបាតវិសាមញ្ញដើម្បីដោះស្រាយបញ្ហានោះ ។

**មាត្រា ៥៣.-**

ក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យពុំមានប្រាក់បំណាច់ឡើយ ប៉ុន្តែមហាសន្និ-បាតអាចសម្រេចទុកនូវថវិកាសម្រាប់ទូទាត់ចំណាយលើការបំពេញការងារនិងប្រាក់ឧបត្ថម្ភជូនក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យបាន ។

## ផ្នែកទី ៥
## ដើមទុន មូលនិធិ និងទ្រព្យសម្បត្តិរបស់សហគមន៍កសិកម្ម

**មាត្រា ៥៤.-**

ប្រភពដើមទុនរបស់សហគមន៍កសិកម្មបានមកពី ៖

- ភាគហ៊ុនដែលបានទិញនិងបង់ដោយសមាជិក
- មូលនិធិបម្រុងដែលដកចេញពីប្រាក់ចំណេញសរុប
- អំណោយឬវិភាគទានដែលត្រូវបញ្ចូលក្នុងទ្រព្យសម្បត្តិរបស់សហគមន៍កសិកម្ម ហើយត្រូវរក្សាទុកក្នុងគណនីដោយឡែក
- កម្ចីពីតតិយជន
- កម្ចីពីសមាជិក ដែលមានរូបភាពជាប្រាក់តម្កល់ឬជាប្រាក់សន្សំ
- ប្រាក់ជំនួយស្របច្បាប់ផ្សេងៗ
- មូលនិធិផ្សេងៗទៀត ។

**មាត្រា ៥៥.-**

ដើមទុនរបស់សហគមន៍កសិកម្មអាចមានការកើនឡើងដែលបណ្ដាលមកពីការចូលរួមបន្ថែមរបស់សមាជិកថ្មីឬការទិញភាគហ៊ុនបន្ថែម និងអាចមានការថយចុះដែលបណ្ដាលមកពីការសងទៅវិញនៅពេលដែលមានការដកភាគហ៊ុនដោយអនុលោមតាមលក្ខន្តិកៈរបស់សហគមន៍កសិកម្ម ។

តម្លៃដំបូងរបស់ភាគហ៊ុនត្រូវបានកំណត់ដោយលក្ខន្តិកៈនិងអាចកំណត់ជាមុនអំពីពេលដែលត្រូវបង់តែមួយលើកឬច្រើនលើក ។

**មាត្រា ៥៦.-**

ភាគហ៊ុនដែលមានឈ្មោះគឺមិនអាចបំបែក និងមិនអាចលក់ទៅឲ្យអ្នកក្រៅដែលមិនមែនជាសមាជិកសហគមន៍បានឡើយ ប៉ុន្តែអាចផ្ទេរពីសមាជិកម្នាក់ទៅសមាជិកម្នាក់ទៀតរបស់សហគមន៍កសិកម្មឬទៅទាយាទ ដោយអនុលោមតាមច្បាប់ជាធរមាន ។

**មាត្រា ៥៧.-**

សហគមន៍កសិកម្ម ត្រូវបង្កើតមូលនិធិបម្រុងមួយ ដោយដកយកយ៉ាងតិច ២០ (ម្ភៃ) ភាគរយពីប្រាក់ចំណេញសរុបរហូតដល់មូលនិធិបម្រុងនេះមានចំនួន ៥ (ប្រាំ) ដងនៃចំនួនភាគហ៊ុនទាំងអស់ ។ មូលនិធិបម្រុងមិនអាចយកទៅបែងចែកដល់សមាជិកបានឡើយ ។

**មាត្រា ៥៨.-**

សហគមន៍កសិកម្ម ត្រូវបង្កើតមូលនិធិសម្រាប់បណ្ដុះបណ្ដាលសមាជិក អ្នកគ្រប់គ្រង និងបុគ្គលិក ដោយដកយកពីប្រាក់ចំណេញសរុបចំនួនយ៉ាងតិច ៣ (បី) ភាគរយក្នុងមួយឆ្នាំ ។ មូលនិធិបណ្ដុះបណ្ដាលនេះ ត្រូវប្រើប្រាស់សម្រាប់គោលបំណងដែលបានបង្កើតឡើងតែប៉ុណ្ណោះ ។

**មាត្រា ៥៩.-**

ប្រាក់ចំណេញសុទ្ធរបស់សហគមន៍កសិកម្មត្រូវបានបែងចែកតាមគោលការណ៍ដូចខាងក្រោម ៖

- រក្សាទុកសម្រាប់មូលនិធិបម្រុងនិងមូលនិធិបណ្តុះបណ្តាលឬមូលនិធិផ្សេងទៀតដែលបង្កើតឡើងដោយសហគមន៍កសិកម្ម
- បែងចែកទៅដល់សមាជិកដោយសមាមាត្រនឹងការធ្វើសកម្មភាពជំនួញរបស់សមាជិកជាមួយសហគមន៍កសិកម្ម
- បែងចែកភាគលាភទៅដល់សមាជិក ដោយអនុលោមតាមភាគហ៊ុនដែលសមាជិកកាន់កាប់ ។

**មាត្រា ៦០.-**

ទ្រព្យសម្បត្តិរបស់សហគមន៍កសិកម្មរួមមាន ថវិកា ដី អគារគ្រប់ប្រភេទ មធ្យោបាយសម្ភារៈបរិក្ខារគ្រប់ប្រភេទ វិភាគទាន អំណោយគ្រប់រូបភាព និងទ្រព្យសម្បត្តិផ្សេងទៀតដែលបង្កើតឡើងដោយសហគមន៍កសិកម្ម ។

**មាត្រា ៦១.-**

សហគមន៍កសិកម្មអាចប្រើប្រាស់មូលនិធិបម្រុងបានក្នុងការទូទាត់ការខាតបង់របស់ខ្លួន ។

## ផ្នែកទី ៦
## សវនកម្មសហគមន៍កសិកម្ម

**មាត្រា ៦២.-**

សហគមន៍កសិកម្មត្រូវធ្វើសវនកម្មជារៀងរាល់ឆ្នាំ ។ របាយការណ៍សវនកម្មត្រូវដាក់ជូនមហាសន្និបាតពិនិត្យតាមរយៈក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្ម ។ សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតស្តីពីលទ្ធផលសវនកម្មត្រូវដាក់នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ។

ការធ្វើសវនកម្មមិនត្រូវអនុវត្តចំពោះសហគមន៍កសិកម្មដែលមានដើមទុនតិចជាង ១០០ ០០០ ០០០ (មួយរយលាន) រៀល ឡើយ ។

**មាត្រា ៦៣.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចេញប្រកាសស្តីពីកម្មវត្ថុសវនកម្មសហគមន៍កសិកម្ម ។

## ផ្នែកទី ៧
## ការរំលាយសហគមន៍កសិកម្ម

**មាត្រា ៦៤.-**

សហគមន៍កសិកម្មត្រូវស្នើសុំរំលាយដោយផ្អែកតាមមូលហេតុណាមួយដូចខាងក្រោម ៖

១- ការព្រមព្រៀងរំលាយតាមរយៈសេចក្តីសម្រេចរបស់មហាសន្និបាតនៃសហគមន៍កសិកម្ម ។

២- លក្ខខណ្ឌដែលតម្រូវឲ្យរំលាយសហគមន៍កសិកម្មដូចមានចែងក្នុងលក្ខន្តិកៈ ។

៣- នៅពេលដែលមានសមាជិកសុំចេញរហូតដល់សហគមន៍នៅសល់សមាជិកចំនួនតិចជាង ៦ (ប្រាំមួយ) រូប ។

៤- នៅពេលដែលសហគមន៍កសិកម្មក្ស័យធនឬមានបំណុលត្រូវសងច្រើនជាងពាក់កណ្តាល នៃដើមទុនសរុប ។

៥- សាលក្រមឬសាលដីកាដែលបង្គាប់ឲ្យរំលាយ

៦- នៅពេលដែលមន្ទីរកសិកម្មរាជធានី ខេត្តសាមីបានដកហូតវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីរបស់សហគមន៍កសិកម្ម ដោយអនុលោមតាមមាត្រា ៦៦ នៃច្បាប់នេះ ។

**មាត្រា ៦៥.-**

សហគមន៍កសិកម្មដែលបានស្នើសុំរំលាយក្រោមបទប្បញ្ញត្តិនៃចំណុចណាមួយនៅក្នុងចំណោមចំណុច ១ ចំណុច ២ ចំណុច ៣ និងចំណុច ៤ នៃមាត្រា ៦៤ ខាងលើនេះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់មន្ទីរកសិកម្មរាជធានី ខេត្តសាមី ក្នុងរយៈពេលមិនលើសពី ៣០ (សាមសិប) ថ្ងៃក្រោយកាលបរិច្ឆេទរំលាយ ដោយត្រូវដាក់សំណើទៅមន្ទីរកសិកម្មរាជធានី ខេត្តសាមី និងចម្លងជូនសាលាឃុំ សង្កាត់និងសាលាក្រុង ស្រុក ខណ្ឌដែលសហគមន៍កសិកម្មតាំងនៅ ។

ក្នុងករណីដែលសហគមន៍កសិកម្មត្រូវរំលាយ សហគមន៍កសិកម្មនោះត្រូវធ្វើការជម្រះ បញ្ជីដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៦៦.-**

មន្ទីរកសិកម្មរាជធានី ខេត្តដែលទទួលបន្ទុកចុះបញ្ជីសហគមន៍កសិកម្ម មានសិទ្ធិដកហូតវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីរបស់សហគមន៍កសិកម្មណាមួយក្នុងករណីដូចខាងក្រោម ៖

១- សហគមន៍កសិកម្មដែលបានចុះបញ្ជីរួច មិនបានដំណើរការឬមិនបានធ្វើប្រតិបត្តិការក្នុងរយៈពេល ១៨ (ដប់ប្រាំបី) ខែ គិតចាប់ពីកាលបរិច្ឆេទចុះបញ្ជីឬសហគមន៍កសិកម្មបានផ្អាកដំណើរការរបស់ខ្លួនក្នុងរយៈពេលលើសពី ២ (ពីរ) ឆ្នាំជាប់គ្នា គិតចាប់ពីកាលបរិច្ឆេទផ្អាកដំណើរការ ។

២- សហគមន៍កសិកម្មដែលប្រព្រឹត្តអំពើបំពានធ្ងន់ធ្ងរផ្ទុយពីច្បាប់ស្តីពីសហគមន៍កសិកម្ម ឬប្រព្រឹត្តល្មើសធ្ងន់ធ្ងរនឹងច្បាប់ដែលពាក់ព័ន្ធជាធរមាន ។

**មាត្រា ៦៧.-**

សហគមន៍កសិកម្មដែលត្រូវបានដកហូតវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីដោយមន្ទីរកសិកម្មរាជធានី ខេត្ត មានសិទ្ធិធ្វើបណ្តឹងតវ៉ាទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងរយៈពេលមិនលើសពី ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃដកហូតវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីដោយមន្ទីរកសិកម្មរាជធានី ខេត្តសាមី ។

Kol

ក្នុងរយៈពេលមិនលើសពី ៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យប្តឹង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវផ្តល់សេចក្តីសម្រេចលើបណ្តឹងតវ៉ារបស់សហគមន៍កសិកម្មដែលត្រូវបានដកហូតវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីនោះ ។

ក្នុងករណីមិនសុខចិត្តលើសេចក្តីសម្រេចនោះ សហគមន៍កសិកម្មអាចធ្វើបណ្តឹងទៅក្រសួងស្ថាប័នពាក់ព័ន្ធឬទៅតុលាការក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសេចក្តីសម្រេចនោះត្រូវផ្អាកជាបណ្តោះអាសន្ន រង់ចាំសេចក្តីសម្រេចរបស់តុលាការ ។

## ផ្នែកទី ៨
## ការជម្រះបញ្ជីសហគមន៍កសិកម្ម

### មាត្រា ៦៨.-

ក្នុងករណីដែលសហគមន៍កសិកម្មត្រូវរំលាយ មហាសន្និបាតសហគមន៍កសិកម្មត្រូវជ្រើសតាំងអ្នកជម្រះបញ្ជីដែលមានសមត្ថភាពមួយរូបឬច្រើនរូបក្នុងរយៈពេលមិនលើសពី ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលសហគមន៍កសិកម្មត្រូវរំលាយឬកាលបរិច្ឆេទ ដែលនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចេញសេចក្តីសម្រេចលើបណ្តឹងតវ៉ា ។

ក្នុងករណីដែលមហាសន្និបាតមិនអាចជ្រើសតាំងអ្នកជម្រះបញ្ជីក្នុងរយៈពេលកំណត់ខាងលើ មន្ទីរកសិកម្មរាជធានី ខេត្តសាមីដែលទទួលបន្ទុកចុះបញ្ជីសហគមន៍កសិកម្មត្រូវចាត់តាំងអ្នកជម្រះបញ្ជីមួយរូបឬច្រើនរូប ដើម្បីអនុវត្តកិច្ចជម្រះបញ្ជីសហគមន៍កសិកម្មដែលត្រូវរំលាយនោះ ។

### មាត្រា ៦៩.-

សេចក្តីសម្រេចស្តីពីការចាត់តាំងអ្នកជម្រះបញ្ជីនិងការរំលាយសហគមន៍កសិកម្មត្រូវបិទផ្សព្វផ្សាយនៅទីស្នាក់ការរបស់សហគមន៍កសិកម្មសាមី នៅការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ មន្ទីរកសិកម្មរាជធានី ខេត្តសាមី និងនៅសាលាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការចាត់តាំងនោះ ។

### មាត្រា ៧០.-

នៅពេលសហគមន៍កសិកម្មត្រូវរំលាយ អ្នកជម្រះបញ្ជីត្រូវទទួលយកសិទ្ធិអំណាចទាំងអស់របស់ក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យដើម្បីអនុវត្តនៅក្នុងដំណើរការជម្រះបញ្ជី ។

ប្រធានក្រុមប្រឹក្សាភិបាលមានកាតព្វកិច្ចថែរក្សាទ្រព្យសម្បត្តិរបស់សហគមន៍កសិកម្មនៅក្នុងរយៈពេលនៃដំណើរការជម្រះបញ្ជីរហូតដល់ការជម្រះបញ្ជីត្រូវបានបញ្ចប់ ។

ROYAUME du CAMBODGE · LE MINISTRE du PALAIS ROYAL

**មាត្រា ៧១.-**

អ្នកជម្រះបញ្ជីមានសិទ្ធិដូចខាងក្រោម ៖

- តម្រូវឲ្យក្រុមប្រឹក្សាភិបាលបង្ហាញនូវទ្រព្យសម្បត្តិរួមជាមួយបញ្ជីគណនេយ្យ បញ្ជីឬឯកសារពាក់ព័ន្ធផ្សេងទៀតរបស់សហគមន៍កសិកម្មតាមការចាំបាច់
- បន្តទទួលខុសត្រូវលើការងាររបស់សហគមន៍កសិកម្មដែលរំលាយ ការពារផលប្រយោជន៍របស់សហគមន៍កសិកម្មរហូតដល់ការជម្រះបញ្ជីត្រូវបានបញ្ចប់ជាស្ថាពរ
- ស្នើកោះប្រជុំមហាសន្និបាតសហគមន៍កសិកម្មតាមការចាំបាច់
- ចាត់ចែងទ្រព្យសម្បត្តិរបស់សហគមន៍កសិកម្មដោយមានការឯកភាពពីមន្ទីរកសិកម្មរាជធានី ខេត្តសាមី
- ចាត់វិធានការទូទាត់បំណុលឬទារបំណុលដែលពាក់ព័ន្ធនឹងសហគមន៍កសិកម្ម
- ចាត់ចែងលើរាល់ដំណើរការរឿងក្តីរដ្ឋប្បវេណីនិងសម្រុះសម្រួលគ្រប់បញ្ហាជំនួសសហគមន៍កសិកម្ម
- អនុវត្តការងារផ្សេងទៀតតាមការចាំបាច់ដើម្បីបញ្ចប់ការជម្រះបញ្ជី ។

**មាត្រា ៧២.-**

អ្នកជម្រះបញ្ជីត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់បំណុលរបស់សហគមន៍កសិកម្មដែលមានឈ្មោះក្នុងបញ្ជីគណនេយ្យ ឬម្ចាស់បំណុលដែលបានស្រាវជ្រាវឃើញដើម្បីជូនព័ត៌មានស្តីពីការរំលាយសហគមន៍កសិកម្ម និងដើម្បីទាមទារការទូទាត់បំណុលក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទជ្រើសតាំងអ្នកជម្រះបញ្ជីត្រូវបានចូលជាធរមាន ។

អ្នកជម្រះបញ្ជីត្រូវធ្វើតារាងតុល្យការរបស់សហគមន៍កសិកម្មនិងដាក់ជូនសវនករឬអ្នកត្រួតពិនិត្យបញ្ជីដើម្បីសិក្សាវាយតម្លៃ ។ នៅពេលដែលតារាងតុល្យការត្រូវបានបញ្ជាក់យល់ព្រមដោយសវនករឬអ្នកត្រួតពិនិត្យបញ្ជីរួច អ្នកជម្រះបញ្ជីត្រូវដាក់តារាងតុល្យការនេះដើម្បីស្នើសុំការយល់ព្រមពីមន្ទីរកសិកម្មរាជធានី ខេត្ត សាមី ។

**មាត្រា ៧៣.-**

ម្ចាស់បំណុលរបស់សហគមន៍កសិកម្មត្រូវប្រកាសអំពីបំណុលរបស់ខ្លួនប្រាប់អ្នកជម្រះបញ្ជីនិងមានសិទ្ធិតវ៉ាទាមទារការទូទាត់បំណុលរបស់ខ្លួនក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទជូនដំណឹងផ្សព្វផ្សាយដោយអ្នកជម្រះបញ្ជី ។

នៅពេលផុតកាលបរិច្ឆេទដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ បំណុលទាំងឡាយនឹងត្រូវ[illegible]ថវិកាដែលនៅសល់ត្រូវបានចាត់ចែងដូចខាងក្រោម ៖

- ទូទាត់ចំណាយសម្រាប់ដំណើរការជម្រះបញ្ជី
- ទូទាត់ពន្ធនិងអាករដែលត្រូវបង់ជូនរដ្ឋ

- ទូទាត់បំណុលនិងប្រាក់បៀវត្សបុគ្គលិកបម្រើការងារក្នុងសហគមន៍កសិកម្ម
- សងភាគហ៊ុនដោយសមាមាត្រនឹងភាគហ៊ុនដែលសមាជិកកាន់កាប់ ។

**មាត្រា ៧៤.-**

ក្រោយការទូទាត់រាល់បំណុលរបស់សហគមន៍កសិកម្ម ប្រសិនបើមានទ្រព្យសម្បត្តិនៅសល់ មហាសន្និបាតសហគមន៍កសិកម្មសាមីមានសិទ្ធិប្រគល់ទ្រព្យសម្បត្តិនេះឲ្យទៅសហគមន៍កសិកម្មមួយ ផ្សេងទៀតនៅក្នុងសហភាពសហគមន៍កសិកម្មតែមួយ ឬប្រគល់ជូនសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាឬប្រគល់ជូនមូលនិធិអភិវឌ្ឍសហគមន៍កសិកម្ម ។

ក្នុងករណីមហាសន្និបាតមិនអាចកោះប្រជុំបាន អ្នកជម្រះបញ្ជីត្រូវស្នើសុំទៅមន្ទីរកសិកម្មរាជធានី ខេត្តនិងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សុំធ្វើការបែងចែកទ្រព្យសម្បត្តិដែលនៅសល់របស់សហគមន៍កសិកម្មនោះ ។

**មាត្រា ៧៥.-**

ក្រោយបញ្ចប់ការជម្រះបញ្ជីសហគមន៍កសិកម្ម អ្នកជម្រះបញ្ជីត្រូវរៀបចំរបាយការណ៍ស្តីពីការជម្រះបញ្ជីរួមជាមួយបញ្ជីតុល្យការនៃគណនីជម្រះបញ្ជី ដើម្បីដាក់ជូនសវនករឬអ្នកត្រួតពិនិត្យបញ្ជីសិក្សាវាយតម្លៃ។ បន្ទាប់ពីមានការយល់ព្រមរបស់សវនករឬអ្នកត្រួតពិនិត្យបញ្ជីលើលទ្ធផលជម្រះបញ្ជី អ្នកជម្រះបញ្ជីត្រូវដាក់ជូនប្រធានមន្ទីរកសិកម្មរាជធានី ខេត្តសាមី ដើម្បីផ្តល់ការយល់ព្រមលើការបិទកិច្ចជម្រះបញ្ជី ហើយសហគមន៍កសិកម្មត្រូវបានលុបចេញពីបញ្ជីដោយត្រូវធ្វើការផ្សព្វផ្សាយដូចជាការចុះបញ្ជីដែរ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចេញប្រកាសស្តីពីនីតិវិធីជម្រះបញ្ជីសហគមន៍កសិកម្ម ។

**មាត្រា ៧៦.-**

អ្នកជម្រះបញ្ជីត្រូវប្រគល់បញ្ជីគណនេយ្យនិងឯកសារជម្រះបញ្ជីជូនមន្ទីរកសិកម្មរាជធានី ខេត្តសាមី ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទកិច្ចជម្រះបញ្ជី ។

អង្គភាពទទួលបន្ទុកចុះបញ្ជីត្រូវរក្សាបញ្ជីនិងឯកសារពាក់ព័ន្ធទាំងអស់ក្នុងរយៈពេល ២ (ពីរ) ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទលុបសហគមន៍កសិកម្មចេញពីបញ្ជីដើម្បីទុកសម្រាប់ការពិនិត្យឬការធ្វើអធិការកិច្ចណាមួយរបស់សមាជិកឬអ្នកដែលពាក់ព័ន្ធផ្សេងទៀតតាមសំណើ ។

## ផ្នែកទី ៩
## ការបញ្ចូលគ្នានៃសហគមន៍កសិកម្ម

**មាត្រា ៧៧.-**

សហគមន៍កសិកម្ម ២ (ពីរ) ឬច្រើននៅក្នុងភូមិសាស្ត្រជាប់គ្នាតែមួយអាចបញ្ចូលគ្នាបាន

តាមរយៈសេចក្តីសម្រេចរបស់មហាសន្និបាតនៃសហគមន៍កសិកម្មនីមួយៗនិងត្រូវចុះបញ្ជីឡើងវិញដើម្បីបង្កើតជាសហគមន៍កសិកម្មតែមួយ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៧៨.-**

សហគមន៍កសិកម្មនីមួយៗដែលត្រូវបញ្ចូលគ្នាត្រូវទូទាត់បំណុលឲ្យម្ចាស់បំណុលទាំងឡាយដែលពាក់ព័ន្ធនៅមុនពេលការបញ្ចូលគ្នាចូលជាធរមាន ។

សហគមន៍កសិកម្មណាមួយដែលមិនបានទូទាត់បំណុលឲ្យម្ចាស់បំណុលឲ្យជ្រះស្រលះមិនអាចស្នើសុំការបញ្ចូលគ្នាបានឡើយ ។

**មាត្រា ៧៩.-**

ឯកសារស្នើសុំចុះបញ្ជីសហគមន៍កសិកម្មថ្មីដែលត្រូវបញ្ចូលគ្នា ត្រូវមានហត្ថលេខា ឬស្នាមមេដៃស្តាំរបស់តំណាងសហគមន៍កសិកម្មនីមួយៗដែលចាត់តាំងដោយក្រុមប្រឹក្សាភិបាល និងត្រូវមានបន្ថែមឯកសារដូចខាងក្រោម ៖

១- លិខិតអះអាងរបស់សហគមន៍កសិកម្មដែលត្រូវបញ្ចូលគ្នា ដែលបានទូទាត់បំណុលជ្រះស្រលះឲ្យម្ចាស់បំណុល ឬការអះអាងដែលបញ្ជាក់នូវភាពមិនពាក់ព័ន្ធនឹងបំណុល ។

២- លក្ខន្តិកៈសហគមន៍កសិកម្មថ្មីដែលត្រូវបញ្ចូលគ្នានិងត្រូវចុះបញ្ជី ។

៣- កំណត់ហេតុមហាសន្និបាតនៃភាគីសហគមន៍កសិកម្មនីមួយៗដែលសម្រេចបញ្ចូលគ្នា ។

ឯកសារទី ២ និងទី ៣ នៃកថាខណ្ឌទី ១ ខាងលើនេះត្រូវចុះហត្ថលេខាដោយតំណាងនៃសហគមន៍កសិកម្មដែលត្រូវបញ្ចូលគ្នា និងចុះបញ្ជីជាសហគមន៍កសិកម្មថ្មីដោយមានហត្ថលេខា ឬស្នាមមេដៃស្តាំយល់ព្រមពីសមាជិកទាំងអស់ ។

**មាត្រា ៨០.-**

បន្ទាប់ពីបញ្ចូលគ្នា សហគមន៍កសិកម្មថ្មីត្រូវរៀបចំមហាសន្និបាតកំណើតដំបូងដោយត្រូវបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ អនុម័តលក្ខន្តិកៈនិងបទបញ្ជាផ្សេងទៀតដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៨១.-**

សហគមន៍កសិកម្មដែលបានបញ្ចូលគ្នាត្រូវស្នើសុំចុះបញ្ជីសហគមន៍កសិកម្មថ្មីដោយភ្ជាប់សំណុំឯកសារដូចមានចែងក្នុងមាត្រា ១៩ និងឯកសារបន្ថែមដូចមានចែងក្នុងមាត្រា ៧៩ នៃច្បាប់នេះ ។

ក្រោយពេលចុះបញ្ជីសហគមន៍កសិកម្មថ្មី មន្ទីរកសិកម្មរាជធានី ខេត្តសាមីត្រូវលុបឈ្មោះសហគមន៍កសិកម្មចាស់ដែលបានបញ្ចូលគ្នាចេញពីបញ្ជីសហគមន៍កសិកម្ម និងត្រូវផ្សព្វផ្សាយជាសាធារណៈពីការចុះបញ្ជីសហគមន៍កសិកម្មថ្មីស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



ksl

**មាត្រា ៨២.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចេញប្រកាសស្តីពីនីតិវិធីនៃការបញ្ចូលគ្នារបស់សហគមន៍កសិកម្ម ។

## ផ្នែកទី ១០
## ការបំបែកសហគមន៍កសិកម្ម

**មាត្រា ៨៣.-**

សហគមន៍កសិកម្មមួយអាចធ្វើការបំបែកបាន ក្នុងករណីមានការផ្លាស់ប្តូរដែនសមត្ថកិច្ចរដ្ឋបាល និងភូមិសាស្ត្ររដ្ឋបាល ឬមានការបែងចែករចនាសម្ព័ន្ធមុខរបរនៅក្នុងសហគមន៍កសិកម្ម ដែលចាំបាច់ត្រូវធ្វើការបំបែក ។

ការស្នើសុំបំបែកសហគមន៍កសិកម្មអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការស្នើសុំពីសមាជិកចាប់ពី ១ ភាគ ២ (មួយភាគពីរ) នៃចំនួនសមាជិកសហគមន៍កសិកម្មទាំងអស់ ។

**មាត្រា ៨៤.-**

ក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្មត្រូវកោះប្រជុំមហាសន្និបាតក្នុងករណីមានសំណើសុំបំបែកសហគមន៍កសិកម្ម ។ មហាសន្និបាតត្រូវពិនិត្យលើសំណើបំបែកសហគមន៍កសិកម្ម ដោយពិចារណាលើការបែងចែកទ្រព្យសម្បត្តិនិងកាតព្វកិច្ចផ្សេងទៀតរបស់សហគមន៍កសិកម្មដែលត្រូវបំបែក ។

មហាសន្និបាតអាចសម្រេចលើការបំបែកសហគមន៍កសិកម្មបាន លុះត្រាតែមានសំឡេងគាំទ្រយ៉ាងតិច ២ ភាគ ៣ (ពីរភាគបី) នៃសមាជិក ឬប្រតិភូតំណាងដែលមានវត្តមានក្នុងអង្គមហាសន្និបាត ។

**មាត្រា ៨៥.-**

ក្រោយកាលបរិច្ឆេទសម្រេចបំបែកសហគមន៍កសិកម្ម ក្រុមប្រឹក្សាភិបាលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់បំណុលស្តីពីចំណែកនៃបំណុលដែលត្រូវបែងចែក។ ក្នុងករណីម្ចាស់បំណុលមានការជំទាស់ត្រូវជូនព័ត៌មានទៅសហគមន៍កសិកម្មក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីទទួលបានសេចក្តីជូនដំណឹង ។

**មាត្រា ៨៦.-**

សហគមន៍កសិកម្មថ្មីដែលត្រូវបង្កើតឡើងដោយសារការបំបែកសហគមន៍កសិកម្មចាស់ត្រូវចុះបញ្ជីដោយអនុលោមតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់នេះ ។

សំណើសុំចុះបញ្ជីត្រូវភ្ជាប់ឯកសារបន្ថែមដូចខាងក្រោម ៖

១- លិខិតស្នើសុំបំបែកនិងកំណត់ហេតុនៃអង្គប្រជុំមហាសន្និបាតដែលសម្រេចបំបែកសហគមន៍កសិកម្ម ។

២- លិខិតជូនព័ត៌មានដល់ម្ចាស់បំណុលពាក់ព័ន្ធនិងសក្ខីបត្រដែលបញ្ជាក់ថាបំណុលត្រូវបានដោះស្រាយរួចរាល់ ។

**មាត្រា ៨៧.-**

ទ្រព្យសម្បត្តិរបស់សហគមន៍កសិកម្មចាស់ ដែលត្រូវបែងចែកឲ្យសហគមន៍កសិកម្មថ្មីរួមជាមួយបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិនេះ ត្រូវប្រគល់ឲ្យសហគមន៍កសិកម្មថ្មីនៅពេលដែលការចុះបញ្ជីសហគមន៍កសិកម្មថ្មីចូលជាធរមាន ។

**មាត្រា ៨៨.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចេញប្រកាសស្តីពីនីតិវិធីនៃការបំបែកសហគមន៍កសិកម្ម ។

## ជំពូកទី ៤
## សហភាពសហគមន៍កសិកម្ម

**មាត្រា ៨៩.-**

សហគមន៍កសិកម្មចំនួន ២ (ពីរ) ឡើងទៅដែលមានសកម្មភាពសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា ឬមានទំនាក់ទំនងសេដ្ឋកិច្ចស្ថិតនៅក្នុងប្រព័ន្ធប្រតិបត្តិការមុខរបររួមគ្នាអាចចូលរួមគ្នាដោយស្ម័គ្រចិត្តបង្កើតជា "សហភាពសហគមន៍កសិកម្ម" ដើម្បីប្រមូលផ្តុំកម្លាំងផលិតកម្ម មធ្យោបាយផលិតកម្ម និងពង្រីកសមត្ថភាពនៅក្នុងផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធវិស័យកសិកម្ម ។

នីតិបុគ្គលឯកជនក្រៅពីសហគមន៍កសិកម្មដែលមានមុខរបរចម្បងនៅក្នុងក្របខ័ណ្ឌនៃផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធវិស័យកសិកម្មអាចដាក់ពាក្យសុំចូលជាសមាជិកសហភាពសហគមន៍កសិកម្មបានដោយស្ម័គ្រចិត្ត ។

**មាត្រា ៩០.-**

សហភាពសហគមន៍កសិកម្មត្រូវបង្កើតឡើង ដោយមិនអាស្រ័យដែនភូមិសាស្ត្ររដ្ឋបាល ដែលសហគមន៍កសិកម្មជាសមាជិកតាំងនៅឡើយ ។

សហភាពសហគមន៍កសិកម្មត្រូវបានចាត់ថ្នាក់ជា ៣ (បី) កម្រិត រួមមាន ៖

១- សហភាពសហគមន៍កសិកម្មកម្រិតជាតិដែលធ្វើសកម្មភាពសេដ្ឋកិច្ចក្នុងគ្រប់តំបន់ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

២- សហភាពសហគមន៍កសិកម្មកម្រិតភូមិភាគ ដែលធ្វើសកម្មភាពសេដ្ឋកិច្ចក្នុងក្របខ័ណ្ឌភូមិភាគណាមួយនៃព្រះរាជាណាចក្រកម្ពុជា ។

៣- សហភាពសហគមន៍កសិកម្មកម្រិតមូលដ្ឋានដែលធ្វើសកម្មភាពសេដ្ឋកិច្ចក្នុងក្របខ័ណ្ឌនៅឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្តណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ៩១.-**

សហភាពសហគមន៍កសិកម្មត្រូវបង្កើតឡើង តាមរយៈសេចក្តីសម្រេចនៃមហាសន្និបាត របស់សហគមន៍កសិកម្មនីមួយៗ ដែលចូលរួមគ្នាបង្កើតសហភាពសហគមន៍កសិកម្ម ។

ក្រុមប្រឹក្សាភិបាលនៃសហគមន៍កសិកម្មនីមួយៗត្រូវចាត់តាំងតំណាងមួយរូប ដើម្បីបង្កើតជាគណៈកម្មការរៀបចំឲ្យបំពេញភារកិច្ច ក្នុងការបង្កើតជាសហភាពសហគមន៍កសិកម្មនិងត្រូវអនុវត្តតាមនីតិវិធីដូចគ្នានៃមហាសន្និបាតកំណើតដំបូងក្នុងការបង្កើតសហគមន៍កសិកម្មដែរ ។

**មាត្រា ៩២.-**

សហភាពសហគមន៍កសិកម្មដែលបង្កើតឡើងត្រូវចុះបញ្ជីទទួលស្គាល់នីត្យានុកូលភាពនៅនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការបញ្ជាក់របស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្តសាមី លើពាក្យស្នើសុំរបស់សហភាពសហគមន៍កសិកម្ម ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចេញប្រកាសស្តីពីនីតិវិធីនៃការបង្កើតនិងចុះបញ្ជីសហភាពសហគមន៍កសិកម្ម ។

**មាត្រា ៩៣.-**

សហភាពសហគមន៍កសិកម្មបំពេញភារកិច្ចដូចខាងក្រោម ៖

១- ធ្វើសកម្មភាពសេដ្ឋកិច្ចចម្រុះរវាងសមាជិកក្នុងក្របខ័ណ្ឌផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម ។

២- បង្កើតនិងគ្រប់គ្រងមូលនិធិនានាសម្រាប់ទ្រទ្រង់ប្រតិបត្តិការមុខរបររបស់សមាជិក ។

៣- ធ្វើការងារទីផ្សារកសិកម្ម វិភាគតម្រូវការ និងធ្វើការផ្គត់ផ្គង់ធាតុចូលកសិកម្មរួមគ្នា ព្រមទាំងផ្តល់ព័ត៌មានទាំងឡាយដែលបម្រើឲ្យផលិតកម្មនិងប្រតិបត្តិការមុខរបររបស់សមាជិក ។

៤- ទ្រទ្រង់និងលើកកម្ពស់បច្ចេកទេសឬវិជ្ជាជីវៈដល់សមាជិក ។

៥- ទទួលខុសត្រូវនិងការពារផលប្រយោជន៍របស់សមាជិកចំពោះមុខអាជ្ញាធរសាធារណៈ និង ដៃគូឯកជន ។

៦- ជួយសម្រុះសម្រួលវិវាទដែលអាចកើតមានរវាងសមាជិកនិងសមាជិករបស់ខ្លួនឬវិវាទជាមួយតតិយជន ។

៧- ផ្តល់ដំបូន្មាននិងតម្រង់ទិសដល់ប្រតិបត្តិការមុខរបររបស់សមាជិកដើម្បីពង្រីកសកម្មភាពសេដ្ឋកិច្ចរបស់សហភាពសហគមន៍កសិកម្ម ។

៨- បំពេញភារកិច្ចដទៃទៀតដែលបម្រើឲ្យប្រតិបត្តិការមុខរបរនិងផលប្រយោជន៍របស់សមាជិកក្រោមវិសាលភាពនៃច្បាប់នេះ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

Kol

**មាត្រា ៩៤.-**

នៅក្នុងមហាសន្និបាតនៃសហភាពសហគមន៍កសិកម្ម ត្រូវមានវត្តមានប្រតិភូតំណាងឲ្យសហគមន៍កសិកម្មដែលជាសមាជិករបស់សហភាពសហគមន៍កសិកម្មនោះ ដោយអនុលោមតាមលក្ខន្តិកៈរបស់សហភាពសហគមន៍កសិកម្មសាមី ។

នីតិបុគ្គលឯកជនក្រៅពីសហគមន៍កសិកម្មដែលជាសមាជិកសហភាពសហគមន៍កសិកម្ម មានសំឡេងឆ្នោតតែ១(មួយ)គត់នៅក្នុងមហាសន្និបាតនៃសហភាពសហគមន៍កសិកម្ម ។

**មាត្រា ៩៥.-**

នីតិវិធីនៃការបង្កើតនិងការប្រព្រឹត្តទៅរបស់សហភាពសហគមន៍កសិកម្មត្រូវអនុវត្តដូចគ្នាចំពោះនីតិវិធីសម្រាប់សហគមន៍កសិកម្មដូចមានចែងក្នុងផ្នែកទី ១ រហូតដល់ផ្នែកទី ១០ ជំពូកទី ៣ នៃច្បាប់នេះ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចេញប្រកាសស្តីពីលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងគំរូរបស់សហភាពសហគមន៍កសិកម្ម ។

## ជំពូកទី ៥
## សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា

**មាត្រា ៩៦.-**

សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ជារចនាសម្ព័ន្ធចាត់តាំងកំពូលរបស់សហគមន៍កសិកម្មដែលត្រូវបង្កើតឡើងតាមរយៈមហាសន្និបាតតំណាងរបស់សហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្មក្រោមការសម្របសម្រួលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ ។

បណ្តាសហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាជាសមាជិកស្វ័យប្រវត្តិរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ។

**មាត្រា ៩៧.-**

សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាបំពេញភារកិច្ចដូចខាងក្រោម ៖

១- ធ្វើជាតំណាងស្របច្បាប់របស់សហគមន៍កសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារសិទ្ធិនិងផលប្រយោជន៍របស់សមាជិក ។

២- ផ្តល់ប្រឹក្សាបច្ចេកទេសដល់សហគមន៍កសិកម្មនិងសម្របសម្រួលទំនាក់ទំនងរវាងសមាជិករបស់ខ្លួនជាមួយស្ថាប័នរាជរដ្ឋាភិបាលឬផ្នែកឯកជន ឬដៃគូអភិវឌ្ឍ ។

៣- ផ្តល់សេវាបណ្តុះបណ្តាលពីបច្ចេកទេសដែលពាក់ព័ន្ធនឹងការងារសហគមន៍កសិកម្ម ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ព្រះបរមរាជវាំង

Kol

៤- ផ្តល់សេវាសវនកម្មដល់សមាជិកក្នុងគោលបំណងផ្តល់ដំបូន្មាននិងជួយតម្រង់ទិសសម្រាប់អភិវឌ្ឍប្រតិបត្តិការមុខរបរ ។

៥- លើកកម្ពស់ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរវាងបណ្តាសហគមន៍កសិកម្មនៅក្នុងប្រទេសនិងក្រៅប្រទេស ឬជាមួយសម្ព័ន្ធសហគមន៍កសិកម្មក្រៅប្រទេស ឬអង្គការអន្តរជាតិផ្សេងទៀតដែលមានគោលដៅសកម្មភាពដូចគ្នា ។

៦- ជួយដល់សមាជិកក្នុងការដោះស្រាយបញ្ហានិងឧបសគ្គដែលពាក់ព័ន្ធនឹងការងារសហគមន៍កសិកម្ម ។

៧- ធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ននៅក្នុងការលើកកម្ពស់ផលប្រយោជន៍ពិតរបស់សហគមន៍កសិកម្មស្របតាមគោលនយោបាយជាតិស្តីពីការអភិវឌ្ឍសហគមន៍កសិកម្ម ។

៨- បំពេញភារកិច្ចផ្សេងទៀតដែលមានគោលដៅបម្រើផលប្រយោជន៍របស់សមាជិក ។

**មាត្រា ៩៨.-**

សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាអាចបង្កើតមូលនិធិដែលមានប្រភពដូចខាងក្រោម ៖

- ប្រាក់សមាជិកភាពរបស់បណ្តាសហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្ម
- ការជួយឧបត្ថម្ភជាថវិការបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ
- អំណោយជាប្រាក់ឬទ្រព្យសម្បត្តិរបស់សប្បុរសជន
- សំណល់ជាប្រាក់ឬទ្រព្យសម្បត្តិរបស់សហគមន៍កសិកម្មឬសហភាពសហគមន៍កសិកម្មដែលត្រូវរំលាយស្របតាមច្បាប់នេះ
- ចំណូលបានពីការធ្វើសេវាកម្មផ្សេងៗរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- ចំណូលឬទ្រព្យសម្បត្តិផ្សេងទៀតរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ។

**មាត្រា ៩៩.-**

សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលដែលមានសមាជិកមិនលើសពី ១៥ (ដប់ប្រាំ) រូប ចេញពីប្រតិភូតំណាងនៃបណ្តាសហគមន៍កសិកម្ម ឬសហភាពសហគមន៍កសិកម្មជាសមាជិកដែលត្រូវសម្រេចដោយមហាសន្និបាតនៃសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ។

សមាជិកក្រុមប្រឹក្សាភិបាលរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាមានអាណត្តិរយៈពេល ៥ (ប្រាំ) ឆ្នាំ ។

សមាជិកក្រុមប្រឹក្សាភិបាលចាស់អាចឈរឈ្មោះឲ្យគេបោះឆ្នោតឡើងវិញបានដោយអនុលោមតាមលក្ខន្តិកៈរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ១០០.-**

ក្រុមប្រឹក្សាភិបាលនៃសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវចាត់តាំងនាយកប្រតិបត្តិ ១ (មួយ) រូបដើម្បីបំពេញតួនាទីជាលេខាធិការនៃក្រុមប្រឹក្សាភិបាល ។

នាយកប្រតិបត្តិនៃសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាមានភារកិច្ចគ្រប់គ្រងរាល់ការងាររបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ដោយអនុលោមតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សម្ព័ន្ធសហគមន៍កម្ពុជា ។

**មាត្រា ១០១.-**

សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវចុះបញ្ជីទទួលស្គាល់នីត្យានុកូលភាពនៅនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

នីតិវិធីនៃការបង្កើតនិងការប្រព្រឹត្តទៅរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវអនុវត្តដូចគ្នាចំពោះនីតិវិធីសម្រាប់សហគមន៍កសិកម្មដូចមានចែងក្នុងផ្នែកទី១ រហូតដល់ផ្នែកទី ១០ ជំពូកទី ៣ នៃច្បាប់នេះ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចេញប្រកាសស្តីពីលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងគំរូរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ។

## ជំពូកទី ៦
## ការតាមដាននិងការដោះស្រាយវិវាទ

**មាត្រា ១០២.-**

អង្គភាពចុះបញ្ជីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសមត្ថកិច្ចក្នុងការតាមដានលើរាល់ដំណើរការប្រតិបត្តិការមុខរបរនិងការប្រព្រឹត្តទៅរបស់សហគមន៍កសិកម្ម សហភាព សហគមន៍កសិកម្ម សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ក្នុងគោលបំណងជំរុញនិងតម្រង់ទិស ក្នុងការអភិវឌ្ឍសហគមន៍កសិកម្ម ។

**មាត្រា ១០៣.-**

វិវាទទាំងឡាយដែលកើតចេញពីសមាជិកនិងសមាជិកសហគមន៍កសិកម្ម រវាងសមាជិកនិងសហគមន៍កសិកម្ម ត្រូវដោះស្រាយដោយមហាសន្និបាតប្រចាំឆ្នាំឬមហាសន្និបាតវិសាមញ្ញរបស់សហគមន៍កសិកម្មសាមីនោះ ។

ក្នុងករណីមហាសន្និបាតមិនអាចដោះស្រាយវិវាទបាន ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈអភិបាលក្រុង ស្រុក ខណ្ឌសាមីត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ ។

ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈអភិបាលក្រុង ស្រុក ខណ្ឌសាមីមិនអាចដោះស្រាយវិវាទនោះ មន្ទីរកសិកម្មរាជធានី ខេត្ត និងគណៈអភិបាលរាជធានីខេត្តសាមី ត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ ។

ក្នុងករណីវិវាទនៅតែមិនអាចដោះស្រាយបាន នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើអន្តរាគមន៍ សម្របសម្រួលដោះស្រាយ ។

**មាត្រា ១០៤.-**

វិវាទទាំងឡាយដែលកើតរវាងសហគមន៍កសិកម្មនិងសហគមន៍កសិកម្ម មន្ទីរកសិកម្មរាជធានីខេត្ត និងគណៈអភិបាលរាជធានីខេត្តសាមីត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ ។

ក្នុងករណីវិវាទនៅតែមិនអាចដោះស្រាយបាន នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើអន្តរាគមន៍ សម្របសម្រួលដោះស្រាយ ។

**មាត្រា ១០៥.-**

វិវាទទាំងឡាយដែលកើតចេញពីសហគមន៍កសិកម្មជាសមាជិកនិងសហភាពសហគមន៍កសិកម្ម ឬសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ត្រូវដោះស្រាយដោយមហាសន្និបាតប្រចាំឆ្នាំ ឬមហាសន្និបាតវិសាមញ្ញនៃសហភាពសហគមន៍កសិកម្មសាមី ឬសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ។

ក្នុងករណីមហាសន្និបាតនៅមិនអាចដោះស្រាយបាន គណៈអភិបាលរាជធានី ខេត្តសាមីនិងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ ។

**មាត្រា ១០៦.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយរាល់វិវាទទាំងឡាយដែលមិនអាចបញ្ចប់បានរវាង៖

ក- សមាជិកនិងសមាជិកសហគមន៍កសិកម្ម

ខ- សមាជិកនិងសហគមន៍កសិកម្ម

គ- សហគមន៍កសិកម្មនិងសហគមន៍កសិកម្ម

ឃ- សហគមន៍កសិកម្មជាមួយសហភាពសហគមន៍កសិកម្ម

ង- សហគមន៍កសិកម្មឬសហភាពសហគមន៍កសិកម្មជាមួយសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាឬអង្គភាពក្រៅណាមួយជាមួយសហគមន៍កសិកម្ម ។

ក្នុងករណីភាគីពាក់ព័ន្ធដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិធ្វើបណ្តឹងទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ឬតុលាការរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលដំណឹងពីសេចក្តីសម្រេច ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ១០៧.-**

ទោសទណ្ឌកម្មនៅក្នុងច្បាប់នេះ រួមមានការព្រមានជាលាយលក្ខណ៍អក្សរ ការដកហូតវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជី និងទោសព្រហ្មទណ្ឌ ។

ការព្រមានជាលាយលក្ខណ៍អក្សរ និងការដកហូតវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីចំពោះសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា គឺជាសមត្ថកិច្ចអង្គភាពទទួលបន្ទុកចុះបញ្ជីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ១០៨.-**

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរចំពោះរូបវន្តបុគ្គលដែលទទួលខុសត្រូវលើសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាដែលបានប្រព្រឹត្តកំហុសណាមួយដូចខាងក្រោម ៖

១- មិនបានតម្កល់ទុកឯកសារឬបញ្ជីដូចមានបញ្ជាក់នៅក្នុងមាត្រា៣៦នៃច្បាប់នេះ ។

២- ខកខានមិនបានធ្វើមហាសន្និបាតប្រចាំឆ្នាំរបស់ខ្លួន ។

៣- ខកខានមិនបានផ្តល់របាយការណ៍ប្រចាំឆ្នាំនិងតារាងតុល្យការជូនអង្គភាពចុះបញ្ជីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដែលតម្រូវដោយច្បាប់នេះ ។

៤- ខកខានមិនបានធ្វើសវនកម្មឬត្រួតពិនិត្យបញ្ជីអនុលោមតាមមាត្រា ៦២ នៃច្បាប់នេះ ។

៥- ខកខានមិនបានរក្សាទុកមូលនិធិបម្រុងនិងមូលនិធិបណ្តុះបណ្តាលអនុលោមតាមមាត្រា ៥៧ និងមាត្រា ៥៨ នៃច្បាប់នេះ ។

៦- បង្កឧបសគ្គ ឬមិនព្រមផ្តល់ចម្លើយ ឬធ្វើឲ្យរាំងស្ទះ ចំពោះគណៈកម្មាធិការត្រួតពិនិត្យ អ្នកជម្រះបញ្ជី សវនករ ឬមន្ត្រីមានសមត្ថកិច្ចរបស់អង្គភាពចុះបញ្ជីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលអនុវត្តការងាររបស់ខ្លួន ។

**មាត្រា ១០៩.-**

ត្រូវទទួលរងការដកហូតវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជី ចំពោះសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្មនិងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាណាដែលប្រព្រឹត្តកំហុសណាមួយដូចខាងក្រោម ៖

១- មិនព្រមធ្វើមហាសន្និបាតប្រចាំឆ្នាំរយៈពេលពីរឆ្នាំជាប់ៗគ្នា ដោយគ្មានមូលហេតុសមស្រប ។

២- មិនព្រមកែតម្រូវចំពោះកំហុសណាមួយរបស់ខ្លួននៅក្នុងមាត្រា ១០៨ ស្របតាមការណែនាំរបស់អង្គភាពចុះបញ្ជីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ១១០.-**

ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ចំពោះអំពើ ៖

១- បន្លំប្រើប្រាស់ឈ្មោះ ឬស្លាកសញ្ញាឈ្មោះ ឬផ្នែកណាមួយនៃ "សហគមន៍កសិកម្ម ឬសហភាពសហគមន៍កសិកម្ម ឬសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា" ដើម្បីធ្វើសកម្មភាពសេដ្ឋកិច្ចឬធ្វើប្រតិបត្តិការមុខរបរក្នុងគោលបំណងបម្រើផលប្រយោជន៍របស់ខ្លួន ។

២- ក្លែងឯកសារចុះបញ្ជី ក្លែងស្លាកសម្គាល់ផលិតផល ក្លែងសំបកសម្រាប់វេចខ្ចប់ផលិតផល ឬក្លែងឯកសារផ្សេងទៀតរបស់សហគមន៍កសិកម្មឬសហភាពសហគមន៍កសិកម្មនៅក្នុងប្រតិបត្តិការមុខរបររបស់ខ្លួន ។

**មាត្រា ១១១.-**

មន្ត្រីទទួលបន្ទុកការចុះបញ្ជីសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ដែលរំលោភលើតួនាទីរបស់ខ្លួនក្នុងការចុះបញ្ជីដែលផ្ទុយនឹងបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលតាមច្បាប់ជាធរមាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**មាត្រា ១១២.-**

នៅក្រោយពេលដែលច្បាប់នេះចូលជាធរមាន លិខិតបទដ្ឋានដែលមានស្រាប់ ហើយដែលមិនខ្ទាស់នឹងច្បាប់នេះ ត្រូវបន្តអនុវត្តរហូតដល់មានលិខិតបទដ្ឋានថ្មីមកជំនួស ហើយរាល់កម្មវិធីនិងសកម្មភាពដែលទាក់ទងនឹងការងារសហគមន៍កសិកម្ម ត្រូវមានសុពលភាពរហូតថ្ងៃផុតកំណត់នៃកម្មវិធីនិងសកម្មភាពនោះ ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ១១៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនិងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១៤.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣

នស/រកម/០៦១៣/០០៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ

ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ហត្ថលេខា

ច័ន្ទ សារុន

លេខ ... ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មិថុនា ឆ្នាំ២០១៣

អគ្គលេខាធិការរង [illegible] រដ្ឋាភិបាល

ស៊យ សុខា

# ឧបសម្ព័ន្ធនៃច្បាប់ស្តីពីសហគមន៍កសិកម្ម

# សទ្ទានុក្រម

១- **ការជម្រះបញ្ជីសហគមន៍កសិកម្ម** សំដៅដល់ដំណើរការជម្រះទ្រព្យសម្បត្តិទាំងអស់របស់សហគមន៍កសិកម្មដែលត្រូវបានរំលាយដើម្បីសងទៅម្ចាស់បំណុលរបស់សហគមន៍កសិកម្ម សងដើមទុនរបស់សមាជិកសហគមន៍កសិកម្ម និងបែងចែងទ្រព្យសម្បត្តិដែលនៅសល់អនុលោមតាមច្បាប់ឬលក្ខន្តិកៈរបស់សហគមន៍កសិកម្ម ។

២- **កសិពាណិជ្ជកម្ម** សំដៅដល់សកម្មភាពប្រតិបត្តិការមុខរបរដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ដូចជាការផ្គត់ផ្គង់សម្ភារៈកសិកម្ម(ពូជ ជី ថ្នាំកសិកម្ម) ការផ្គត់ផ្គង់គ្រឿងយន្តនិងឧបករណ៍កសិកម្មការលក់ដុំ ការលក់រាយ ការបង្កើតទីផ្សារ និងការជេញថ្លៃលក់កសិផល ។ល។

៣- **កសិឧស្សាហកម្ម** សំដៅដល់គ្រប់សកម្មភាពមុននិងក្រោយពេលប្រមូលផលកសិផលដូចជាការធ្វើចំណាត់ថ្នាក់ ការវេចខ្ចប់ ការដឹកជញ្ជូន ការទុកដាក់ ការកែច្នៃវត្ថុធាតុដើមនៃផលិតផលកសិកម្មទាំងអស់ដើម្បីបង្កើនគុណភាពនិងតម្លៃសម្រាប់បម្រើទីផ្សារក្នុងប្រទេសនិងការនាំចេញ ។

៤- **តារាងតុល្យការសហគមន៍កសិកម្ម** សំដៅដល់តារាងរបាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញពីស្ថានភាពនៃទ្រព្យសកម្មនិងទ្រព្យអកម្មរបស់សហគមន៍កសិកម្ម ។

៥- **ប្រាក់ចំណេញសរុបសហគមន៍កសិកម្ម** សំដៅដល់លទ្ធផលសេដ្ឋកិច្ចសរុបនៅចុងការិយបរិច្ឆេទដែលបានមកពីការធ្វើប្រតិបត្តិការមុខរបររបស់សហគមន៍កសិកម្ម ។

៦- **ប្រាក់ចំណេញសុទ្ធសហគមន៍កសិកម្ម** សំដៅដល់ប្រាក់នៅសល់នៅចុងការិយបរិច្ឆេទដែលបានមកពីប្រាក់ចំណេញសរុប ដកមូលនិធិបម្រុង មូលនិធិបណ្តុះបណ្តាល និងមូលនិធិផ្សេងទៀតដែលត្រូវបង្កើតឡើងដោយសហគមន៍កសិកម្ម ។

៧- **ប្រព័ន្ធផលិតកម្មកសិកម្ម** សំដៅការងារផលិតកម្មកសិកម្មដែលរួមមានការដាំដំណាំគ្រប់ប្រភេទ ការចិញ្ចឹមសត្វ វារីវប្បកម្ម រុក្ខវប្បកម្ម និងវប្បកម្មផ្សេងទៀតដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃវិស័យកសិកម្ម ។

៨- **ភាគហ៊ុនសហគមន៍កសិកម្ម** សំដៅដល់ទុនមួយផ្នែកនៃដើមទុនរបស់សហគមន៍កសិកម្មដែលសមាជិកសហគមន៍កសិកម្មម្នាក់ៗបានទិញនិងបង់នៅក្នុងសហគមន៍កសិកម្ម សម្រាប់ធ្វើប្រតិបត្តិការមុខរបររួមគ្នា ។

៩- **សហគ្រាសសេដ្ឋកិច្ចកសិកម្ម** សំដៅដល់សហគ្រាសកសិកម្មដែលធ្វើសកម្មភាពសេដ្ឋកិច្ចក្នុងក្របខ័ណ្ឌនៃប្រព័ន្ធផលិតកម្មកសិកម្ម កសិពាណិជ្ជកម្ម កសិឧស្សាហកម្ម ឬសេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ក្រសួងព្រះបរមរាជវាំង

១០- **សេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម** សំដៅដល់សេវាកម្មនានាដែលគាំទ្រដល់ការលើកកម្ពស់ផលិតកម្មកសិកម្ម ដូចជាសេវាកម្មឥណទាន សន្សំ បញ្ញើ ដឹកជញ្ជូនកសិផល ផ្សព្វផ្សាយឬបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម សេវាកម្មផ្គត់ផ្គង់សម្ភារៈ កសិកម្ម សេវារៀបចំដី សេវាកម្មផ្គត់ផ្គង់ប្រេងឥន្ធនៈ សេវាកម្មកម្ចាត់សមាសភាពចង្រៃ និងសេវាកម្មផ្សេងទៀតដែលអនុវត្តនៅក្នុងប្រព័ន្ធផលិតកម្មកសិកម្ម ។

១១- **សវនកម្មសហគមន៍កសិកម្ម** សំដៅដល់ការត្រួតពិនិត្យនិងការណែនាំសហគមន៍កសិកម្ម ផ្តោតលើសកម្មភាពសេដ្ឋកិច្ច បញ្ជីគណនេយ្យ និងសកម្មភាពជំនួញរបស់សហគមន៍កសិកម្ម

១២- **អង្គភាពចុះបញ្ជី** សំដៅដល់មន្ទីរកសិកម្មរាជធានី ខេត្ត និងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មដែលមានភារកិច្ចចុះបញ្ជីសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្មនិង សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ។

**គោលការណ៍គ្រឹះសហគមន៍កសិកម្ម ៖**

**គោលការណ៍ទី១ ការចូលរួមដោយស្ម័គ្រចិត្តនិងបើកចំហសមាជិកភាព**

សហគមន៍កសិកម្មត្រូវបានបង្កើតឡើងតាមលក្ខណៈស្ម័គ្រចិត្ត បើកចំហចំពោះមនុស្សទាំងអស់ដើម្បីប្រើប្រាស់សេវាកម្មនិងសុខចិត្តទទួលខុសត្រូវចំពោះសមាជិកភាពដោយមិនរើសអើងចំពោះយេនឌ័រ សង្គម ពូជសាសន៍ នយោបាយ និងសាសនាឡើយ ។

**គោលការណ៍ទី២ ការគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យដោយសមាជិក**

សហគមន៍កសិកម្មត្រូវដឹកនាំនិងគ្រប់គ្រងតាមបែបប្រជាធិបតេយ្យដោយសមាជិកដែលបានចូលរួមក្នុងការកំណត់គោលនយោបាយនិងក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា ។ បុរស និងស្ត្រីដែលត្រូវបានបោះឆ្នោតជាប់ក្នុងរចនាសម្ព័ន្ធដឹកនាំត្រូវតែមានគណនេយ្យភាពចំពោះសមាជិក ។ សមាជិករបស់សហគមន៍កសិកម្មមានសិទ្ធិបោះឆ្នោត ស្មើភាពគ្នា គឺសមាជិកម្នាក់មានសំឡេងឆ្នោតមួយ ។

**គោលការណ៍ទី៣ ការចូលរួមផ្នែកសេដ្ឋកិច្ចរបស់សមាជិក**

សមាជិកទាំងអស់ត្រូវចូលរួមដើមទុនដល់សហគមន៍ដោយលក្ខណៈសមភាពនិងត្រូវ គ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យ ។ មួយចំណែកនៃដើមទុនរបស់សមាជិកត្រូវក្លាយជាទ្រព្យសម្បត្តិរួមរបស់សហគមន៍កសិកម្ម។ សមាជិកសហគមន៍កសិកម្មត្រូវបែងចែកប្រាក់ចំណេញខ្លះឬទាំងអស់ដើម្បី (ក) អភិវឌ្ឍសហគមន៍កសិកម្មនិងត្រូវបង្កើតមូលនិធិបម្រុង (ខ) បែងចែកដល់សមាជិកសហគមន៍កសិកម្មដោយផ្អែកតាមសមាមាត្រសកម្មភាព ធ្វើជំនួញរបស់គេជាមួយសហគមន៍កសិកម្មនិង (គ) គាំទ្រសកម្មភាពផ្សេងៗទៀតដែលត្រូវសម្រេចដោយសមាជិកសហគមន៍កសិកម្ម ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

**គោលការណ៍ទី៤ ស្វ័យភាពនិងឯករាជ្យ**

សហគមន៍កសិកម្មត្រូវមានលក្ខណៈស្វយ័ត ជួយខ្លួនឯង និងគ្រប់គ្រងដោយសមាជិក ។ ប្រសិនបើសហគមន៍កសិកម្មមានកិច្ចព្រមព្រៀងឬកិច្ចសន្យាណាមួយជាមួយស្ថាប័នពាក់ព័ន្ធរួមមានរាជរដ្ឋាភិបាល ឬការទទួលបានហិរញ្ញវត្ថុពីប្រភពខាងក្រៅ សហគមន៍កសិកម្មអាចធ្វើបាននៅក្នុងលក្ខខណ្ឌដែលអាចធានាបាននូវការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យដោយសមាជិក និងរក្សាបាននូវស្វ័យភាពរបស់ខ្លួន ។

**គោលការណ៍ទី៥ ការអប់រំ ការបណ្តុះបណ្តាល និងការផ្តល់ព័ត៌មាន**

សហគមន៍កសិកម្មត្រូវផ្តល់ការអប់រំនិងការបណ្តុះបណ្តាលទៅដល់សមាជិករបស់ខ្លួនដល់អ្នកតំណាងដែលបានជាប់ឆ្នោតនិងបុគ្គលិក ដើម្បីធ្វើឲ្យគេអាចចូលរួមយ៉ាងសកម្មនិងមានប្រសិទ្ធភាពក្នុងការអភិវឌ្ឍសហគមន៍កសិកម្មរបស់ខ្លួន និងធ្វើឲ្យពួកគេអាចផ្សព្វផ្សាយជាសាធារណៈ ជាពិសេសដល់ក្រុមយុវជននិងអ្នកមានគំនិតជាអ្នកដឹកនាំអំពីកម្មវត្ថុនិងផលប្រយោជន៍របស់សហគមន៍កសិកម្ម។

**គោលការណ៍ទី៦ ការធ្វើកិច្ចសហប្រតិបត្តិការជាមួយសហគមន៍កសិកម្មផ្សេងទៀត**

សហគមន៍កសិកម្មត្រូវបម្រើសមាជិករបស់ខ្លួនឲ្យមានប្រសិទ្ធភាពខ្ពស់និងត្រូវពង្រឹងតាមរយៈការធ្វើការរួមគ្នាជារចនាសម្ព័ន្ធនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ។

**គោលការណ៍ទី៧ ការគិតគូរដល់សហគមន៍**

សហគមន៍កសិកម្មត្រូវគិតគូរដល់ប្រយោជន៍រួម ធ្វើយ៉ាងណាឲ្យមានការអភិវឌ្ឍសហគមន៍ប្រកបដោយចីរភាពស្របតាមគោលបំណងនិងទិសដៅរបស់សមាជិកសហគមន៍កសិកម្ម ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៥៦៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០៥រូប ដែលបាន បរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធាន ចូលរួមជួយកសាងព្រះវិហារ និងសមិទ្ធផលនានា នៅវត្តជួស ស្ថិតនៅក្នុងឃុំជីខ្មា ស្រុកទ្រាំង ខេត្តតាកែវ សម្រេចបានលទ្ធផលល្អប្រសើរ

នូវ

ក-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

- ឧបាសិកា ព្រុំម សុខុម

ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

១- ឯកឧត្តម អ៊ុំម កុច

២- ឯកឧត្តម ប្រាក់ ផន

៣- ឯកឧត្តម មាស សុខុម

៤- លោក លី ផល្លី

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចនស. ១៣០៥.៥៧៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣

លេខ: ៥៤៧ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១៣
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល
សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៥៤០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

តែងតាំង :

លោក ស៊ូ គង់ទ្រឹប

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១៤. ១៣០៥. ៥៤៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣

លេខ: ៤៥៩ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១៣
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៥៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង :

១- លោកជំទាវ **សុខ មុយ** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី៣ មានឋានៈស្មើ **រដ្ឋលេខាធិការ**

២- ឯកឧត្តម **ហង្ស វណ្ណៈ** ជាជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី៣ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣នស.១៣០៥.៥៧៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣

លេខ: ៦៣៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៥៧២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា**
**សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឯកឧត្តមឧកញ៉ា ឆាយ អ៊ីនធ័រ

ដែលមានស្នាដៃល្អ និងមានគុណបំណាច់យ៉ាងធំធេង
ក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣ខល. ១៣០៥. ៥៧៧

*ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣*

លេខៈ ៦៣៨ ស.ណ
**សំណៅចំលងចេញពីច្បាប់ដើម**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**សូយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៧៣

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** កាត់ផ្ទៃដីទំហំ ៣១ ហិកតា ដែលកំណត់ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣ ។

**មាត្រា ២.-** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរស. ១៣០៦.៥៥០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១៣

លេខៈ ៥៦៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១៣
អគ្គលេខាធិការរង អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៧៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** កាត់ផ្ទៃដីទំហំ ៦៨៨ ហិកតា ពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដែលកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ។

**មាត្រា ២.-** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៥៦៤ ស.ណ
**សំណៅចម្លងចែកជូន**
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**សាយ សុខា**

៣៣៧.១៣០៦.៥៥១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១៣

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៧៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោកឧត្តមសេនីយ៍ទោ **មួន សារ៉ែន** អត្តលេខ ០៧៧២ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស. ១៣០៦.៥៥២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៣

លេខៈ ៥៦៣ ស.ណ
**សំណៅចម្លងមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៧៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **មួន សារ៉ែន** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.១៣០៦.៥៥៣

ធ្វើនៅព្រះបរមរាជវាំង , ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១៣

លេខ: ៥៦៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៧៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនលោកវរសេនីយ៍ឯក **សុខណ្ណា ធនុរាសី** អត្តលេខ ០៦០០៨ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការស. ១៣០៦.៥៥៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៣

លេខៈ ៥៧៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការ... រាជរដ្ឋាភិបាល**

**ស៊ុម សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៧៤

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : តែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ **នៃ ស៊ីណារិទ្ធ** អត្តលេខ ០២៣៣ ជាទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើអគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនឯកឧត្តមឧត្តមសេនីយ៍ទោ **នៃ ស៊ីណារិទ្ធ** អត្តលេខ ០២៣៣ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារ. ១៣០៦.៥៤៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៣

លេខ ៥៧១ ស.ណ
**សំណៅដែលមានចម្លងជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រីរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៧៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: តែងតាំងឯកឧត្តម **ម៉ិន រដ្ឋា** ជាជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២**: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤**: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចានស. ១៣០៦.៥៨៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១៣

លេខ: ៥៥៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**សយ សុខា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៨០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ១.៨៣៤,៧១១០ ហិកតា នៅស្រុកឈូក ខេត្តកំពត ចេញពី (១)គម្របព្រៃឈើ ឆ្នាំ ២០០២ (២) ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន World Trista Entertainment (CAMBODIA) Co,.Ltd ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ៦២៩ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ២០៨លស ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ១.៨៣៤,៧១១០ ហិកតា ក្នុងនោះ (១) ទំហំ ១៤៩៤,៣១៤៧ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និង (២) ទំហំ ៣៤០,៣៩៦៣ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន World Trista Entertainment (CAMBODIA) Co,.Ltd និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ១៥២២,៧៨៥៦ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ៣១១,៩២៥៤ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិព្រៃពាយ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៦២៩គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិព្រៃពាយ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ២៨១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី

## ការកាត់ដីទំហំ ២១២,៥១៨៣ ហិកតា នៅស្រុកឈូក ខេត្តកំពត ចេញពី (១) ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន Virtus Green Plantations (CAMBODIA) Pte,.Ltd (២) ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន First Bio-Tech Agricultural (CAMBODIA) Co,.Ltd ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ១១៥ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ២១៩លស ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

## មាត្រា ១.-

ត្រូវបានកាត់ដីសរុបទំហំ ២១២,៥១៨៣ ហិកតា ក្នុងនោះ (១) ទំហំ ១០៥,៣៦៩៦ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន Virtus Green Plantations (CAMBODIA) Pte,.Ltd និង (២) ទំហំ ១០៧,១៤៨៧ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន First Bio-Tech Agricultural (CAMBODIA) Co,. Ltd និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ១៩៧,៦០០២ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្តែង និងដីទំហំ ១៤,៩១៨១ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅភូមិតេជោពង្រក ឃុំតេជោអភិវឌ្ឍន៍ ស្រុកឈូក ខេត្តកំពត តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

## មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១១៥គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្តែង នៅភូមិភូមិតេជោពង្រក ឃុំតេជោអភិវឌ្ឍន៍ ស្រុកឈូក ខេត្តកំពត ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២៧៤២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ១៣៣,៤០០២ ហិកតា នៅស្រុកជុំគីរី ខេត្តកំពត ចេញពីផែនទីគម្រប ព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៤១គ្រួសារ និងរក្សាទុកមួយចំណែកជាដី សាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ១៨៧ល.ស ចុះថ្ងៃទី២៦ខែ មេសា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.**

ត្រូវបានកាត់ដីសរុបទំហំ ១៣៣,៨០០២ ហិកតា ចេញពីផែនទីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មទំហំ ១២៥,៦៨៨៣ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ ៨,៧១១៩ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅភូមិស្រែសំរោង ឃុំស្រែសំរោង ស្រុកជុំគីរី ខេត្តកំពត តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២.**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១៥១ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិស្រែសំរោង ឃុំស្រែសំរោង ស្រុកជុំគីរី ខេត្តកំពត ។

**មាត្រា ៣..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៨៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៧២៥,៨៣៨៤ ហិកតា នៅស្រុកជុំគីរី ខេត្តកំពត ចេញពីផែនទីគម្រប ព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣៤៥គ្រួសារ និងរក្សាទុកមួយចំណែក ជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ១៨៦ល.ស ចុះថ្ងៃទី២៦ខែ មេសា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ៧២៥,៨៣៨៨ ហិកតា ចេញពីផែនទីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មទំហំ ៧០៧,៧៥៦៦ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ ១៨,០៨២២ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅភូមិមនោរម្យ ឃុំជំពូវន្ត ស្រុកជុំគីរី ខេត្តកំពត តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៣៩៥គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិមនោរម្យ ឃុំជំពូវន្ត ស្រុកជុំគីរី ខេត្តកំពត ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ១០៦,៤៥៥៧ ហិកតា នៅស្រុកជុំគិរី ខេត្តកំពត ចេញពីផែនទីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៩៧គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ១៨៥ល.ស ចុះថ្ងៃទី២៦ខែ មេសា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ១០៦,៤៥៥៧ ហិកតា ចេញពីផែនទីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មទំហំ ១០១,១០២៣ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ ៥,៣៥៣៤ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅភូមិពោធិ ឃុំស្រែសំរោង ស្រុកជុំគីរី ខេត្តកំពត តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៩៧គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិពោធិ ឃុំស្រែសំរោង ស្រុកជុំគីរី ខេត្តកំពត

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ [illegible]

## អនុក្រឹត្យ

### ស្តីពី

### ការដាក់ឲ្យមន្ត្រីរាជការចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងក ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិក មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីក បង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងដំណើរការ នៃការដាក់ម រាជការស៊ីវិលឲ្យចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធព័ត៌មានវិទ្យា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** : ដាក់ឲ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ មន្ត្រីរាជការចំនួន ០៧ នាក់ ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាមនិងនាម | ភេទ | ឆ្នាំកំណើត | ឋានន្តរស័ក្តិ | មុខតំណែង | ថ្ងៃចូលនិវត្តន៍ |
|---|---|---|---|---|---|---|
| 1 | **មាស សារ៉េត** | ប | 13-03-1953 | វរមន្ត្រីថ្នាក់លេខ ៣ | មន្ត្រីគ្រប់គ្រងរដ្ឋបាលសាលាខេត្តកំពង់ចាម | 01-04-2013 |
| 2 | **អ៊ាន យុន** | ប | 10-12-1953 | វរមន្ត្រីថ្នាក់លេខ ៤ | អភិបាលស្រុកក្រឡាញ់ ខេត្តសៀមរាប | 01-01-2014 |
| 3 | **ស សំអុល** | ប | 15-05-1953 | វរមន្ត្រីថ្នាក់លេខ ៧ | អភិបាលរង នៃគណៈអភិបាលខេត្តព្រះវិហារ | 01-06-2013 |
| 4 | **ញ៉ែម គមសាច** | ប | 01-01-1953 | វរមន្ត្រីថ្នាក់លេខ ៧ | អភិបាលស្រុកកញ្ជ្រៀច ខេត្តព្រៃវែង | 01-02-2013 |
| 5 | **គម ជួន** | ប | 15-05-1953 | វរមន្ត្រីថ្នាក់លេខ ៧ | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធនាគារ | 01-06-2013 |
| 6 | **អ៊ីុច ស៊ីគេក** | ប | 10-12-1953 | វរមន្ត្រីថ្នាក់លេខ ៨ | មន្ត្រីគ្រប់គ្រងរដ្ឋបាលនាយកដ្ឋានរដ្ឋបាលទូទៅ | 01-01-2013 |
| 7 | **គង់ ប៊ុនថន** | ប | 13-08-1953 | វរមន្ត្រីថ្នាក់លេខ ៩ | មន្ត្រីគ្រប់គ្រងរដ្ឋបាលសាលាខេត្តស្វាយរៀង | 01-09-2013 |

**មាត្រា ២** : កែសម្រួលថ្នាក់ក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ មន្ត្រីរាជការចំនួន ០៦ នាក់ និងដាក់ឲ្យចូលនិវត្តន៍ ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាមនិងនាម | ភេទ | ឆ្នាំកំណើត | ឋានន្តរស័ក្តិ | មុខតំណែង | ថ្ងៃចូលនិវត្តន៍ |
|---|---|---|---|---|---|---|
| 1 | ឆេព មាន | ប | 15-09-1953 | ពីវរមន្ត្រីថ្នាក់លេខ ៤ ទៅវរមន្ត្រីថ្នាក់លេខ ១ | អភិបាលស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ | 01-10-2013 |
| 2 | ហែន សុផល | ប | 30-12-1953 | ពីវរមន្ត្រីថ្នាក់លេខ ៥ ទៅវរមន្ត្រីថ្នាក់លេខ ១ | អភិបាលស្រុកសំឡូត ខេត្តបាត់ដំបង | 01-01-2014 |
| 3 | ពូល ទៅ | ប | 05-10-1953 | ពីវរមន្ត្រីថ្នាក់លេខ ៦ ទៅវរមន្ត្រីថ្នាក់លេខ ២ | អភិបាលស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ | 01-11-2013 |
| 4 | អ៊ិត យុត | ស | 01-04-1953 | ពីវរមន្ត្រីថ្នាក់លេខ ៧ ទៅវរមន្ត្រីថ្នាក់លេខ ៣ | អភិបាលរង នៃគណៈអភិបាលខេត្តប៉ៃលិន | 01-05-2013 |
| 5 | ឈួន អាន | ប | 20-08-1953 | ពីវរមន្ត្រីថ្នាក់លេខ ៧ ទៅវរមន្ត្រីថ្នាក់លេខ ៣ | អភិបាលរង នៃគណៈអភិបាលខេត្តឧត្តរមានជ័យ | 01-09-2013 |
| 6 | ឡុ យុយ | ប | 10-10-1953 | ពីវរមន្ត្រីថ្នាក់លេខ ៩ ទៅវរមន្ត្រីថ្នាក់លេខ ៦ | អភិបាលខណ្ឌចំការមន រាជធានីភ្នំពេញ | 01-11-2013 |

**មាត្រា ៣** : ដំឡើងទៅក្នុងឋានន្តរស័ក្តិជាវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ មន្ត្រីរាជការចំនួន ០៧ រូប និងដាក់ឲ្យចូលនិវត្តន៍ ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាមនិងនាម | ភេទ | ឆ្នាំកំណើត | ឋានន្តរស័ក្តិ | មុខតំណែង | ថ្ងៃចូលនិវត្តន៍ |
|---|---|---|---|---|---|---|
| 1 | ហុង ហ៊ាង | ប | 15-09-1953 | ពីអនុមន្ត្រីថ្នាក់លេខ ២ ទៅវរមន្ត្រីថ្នាក់លេខ ៥ | អភិបាលស្រុកកងមាស ខេត្តកំពង់ចាម | 01-10-2013 |
| 2 | ស្រី សារឿន | ប | 30-12-1953 | ពីអនុមន្ត្រីថ្នាក់លេខ ៣ ទៅវរមន្ត្រីថ្នាក់លេខ ៦ | អភិបាលស្រុកព្រៃឈរ ខេត្តកំពង់ចាម | 01-01-2014 |
| 3 | ធុច ថាត | ប | 23-03-1953 | ពីអនុមន្ត្រីថ្នាក់លេខ ៣ ទៅវរមន្ត្រីថ្នាក់លេខ ៦ | អភិបាលក្រុងកំពង់ចាម ខេត្តកំពង់ចាម | 01-04-2013 |
| 4 | ស៊ិន គឿន | ប | 01-04-1953 | ពីអនុមន្ត្រីថ្នាក់លេខ ៤ ទៅវរមន្ត្រីថ្នាក់លេខ ៦ | អភិបាលស្រុកមណ្ឌលសីមា ខេត្តកោះកុង | 01-05-2013 |
| 5 | ទុច សំបូរ | ប | 23-03-1953 | ពីអនុមន្ត្រីថ្នាក់លេខ ៥ ទៅវរមន្ត្រីថ្នាក់លេខ ៦ | អភិបាលស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ | 01-04-2013 |
| 6 | បូរ កែវសុវណ្ណ | ប | 03-02-1953 | ពីអនុមន្ត្រីថ្នាក់លេខ ៦ ទៅវរមន្ត្រីថ្នាក់លេខ ៧ | អភិបាលស្រុកសេសាន ខេត្តស្ទឹងត្រែង | 01-03-2013 |
| 7 | ស៊ឹម វណ្ណា | ប | 26-06-1953 | ពីអនុមន្ត្រីថ្នាក់លេខ ៦ ទៅវរមន្ត្រីថ្នាក់លេខ ៧ | អភិបាលស្រុកសណ្ដាន់ ខេត្តកំពង់ធំ | 01-07-2013 |

**មាត្រា ៤** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥** : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ មាត្រា ២ និងមាត្រា ៣ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិជូនលោក **មួន សុភាព** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១០ ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១០ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ២*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល

-បានឃើញអនុក្រឹត្យលេខ ១៣៦ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១២ ស្តីពីការកែសម្រួលគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាក្ងដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

**មាត្រា ១ :** តែងតាំងមន្ត្រីរាជការចំនួន ០៤រូប នៃអគ្គលេខាធិការដ្ឋាន គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា ដូចខាងក្រោម ៖

-លោក **ឈិន ចំន្ទពិបុល** ឲ្យបំពេញមុខងារ ជាប្រធានផ្នែកអន្តរាគមន៍ និងដោះស្រាយ ឋានៈស្មើ ប្រធាននាយកដ្ឋាន

-លោកស្រី **អ៊ុំ សោភ័ណ** ឲ្យបំពេញមុខងារ ជាប្រធានផ្នែកសុខុដុមនីយកម្មសង្គម និងទំនាក់ទំនងវិជ្ជាជីវៈ ឋានៈស្មើ ប្រធាននាយកដ្ឋាន

-លោក **សោម និស្ស័យ** ឲ្យបំពេញមុខងារ ជាប្រធានផ្នែកស្រាវជ្រាវព័ត៌មាន បណ្តុះបណ្តាល និងចលនាមហាជន ឋានៈស្មើ ប្រធាននាយកដ្ឋាន

-លោក **ឡូ សុភារិទ្ធ** ឲ្យបំពេញមុខងារ ជាប្រធានផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងបូកសរុប ឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ មិថុ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៣០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបំពេញបន្ថែមសមាសភាព នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ឆ្នាំ២០១១-២០១៤

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- បានឃើញអនុក្រឹត្យ លេខ ២១៥.អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិឆ្នាំ២០១១-២០១៤
- ផ្អែកតាមផែនការអន្តរស្ថាប័ន លេខ ០១៤ ផ.ក/១១ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១១ ស្តីពីកិច្ចការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សម្រាប់ដំណើរការរៀបចំការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ឆ្នាំ២០១១-២០១៤
- យោងតាមការចាំបាច់ ។

## ស ម្រេ ច

**មាត្រា ១.-** ត្រូវបានបន្ថែមសមាសភាពឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអគ្គលេខាធិការ ជាសមាជិកនៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ឆ្នាំ២០១១ ២០១៤ អក្សរកាត់ " គ.ស.អ " ដែលមានសមាសភាព ដូចតទៅ ៖

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **ចម ប្រសិទ្ធ** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២- | ឯកឧត្តម | **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៣- | ឯកឧត្តម | **វង សូត** | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៤- | ឯកឧត្តម | **សុខ ចិន្តា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានលេខាធិការដ្ឋាននៃ គ.ស.អ ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ៦ ឆ្នាំ ២០១៣**

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋាន គ.ជ.ប
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត
- អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានក្រសួងពាណិជ្ជកម្ម
- អគ្គលេខាធិការដ្ឋានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- អគ្គលេខាធិការដ្ឋានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សាលារាជធានី ខេត្ត ទាំង ២៤
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៣៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ផ្តល់ជូនសប្បុរសជន ០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង នៅ**វត្តសាគរខ្ចៅ** ស្ថិតនៅក្នុងឃុំខ្ចៅ ស្រុកកងមាស ខេត្តកំពង់ចាម ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

១-លោកជំទាវ **ខួត ស៊ីដ្ឋា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៣៦.០០០ ដុល្លារ

២-លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត **ហាចឿ ចំនួទរៈ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៣៦.០០០ ដុល្លារ

**មាត្រា ២.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តកំពង់ចាម និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...០៣...សរ

# សារាចរ

## ស្តីពី

## ការអនុវត្តគោលការណ៍ណែនាំអំពីនីតិវិធីនិងវិធាននៃការតាក់តែង សេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត

កន្លងមករាជរដ្ឋាភិបាលបានសង្កេតឃើញថា ក្រសួង ស្ថាប័នទាំងអស់បានខិតខំរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលទាក់ទងនឹងជំនាញរបស់ខ្លួន ហើយផ្ញើមកទីស្តីការគណៈរដ្ឋមន្ត្រី សុំឆ្លងអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យជាចុងក្រោយ និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដើម្បីសុំការយល់ព្រមនិងបញ្ជូនទៅសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិឬស្នើសុំព្រះរាជតម្រិះពីព្រះមហាក្សត្រឬការសម្រេចពីនាយករដ្ឋមន្ត្រី ក្នុងគោលបំណងចូលរួមពង្រឹងនីតិរដ្ឋឱ្យកាន់តែប្រសើរថែមទៀត។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានសង្កេតឃើញដែរថា ការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតរបស់ក្រសួង ស្ថាប័ននៅពុំទាន់មានឯកភាពស៊ីចង្វាក់គ្នាបានល្អនិងរលូននៅឡើយ។ ដើម្បីឱ្យការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតមានឯកភាព រាជរដ្ឋាភិបាលដាក់ចេញនូវនីតិវិធីនិងវិធាននៃការតាក់តែងលិខិតបទដ្ឋានគតិយុត្តទាំងនោះនិងធ្វើការណែនាំដូចតទៅៈ

១- គ្រប់ក្រសួង ស្ថាប័នត្រូវពង្រឹងនិងជំរុញអង្គភាពនីតិកម្មក្រោមឱវាទឱ្យដំណើរការបានសកម្មក្នុងការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដោយសហការជាមួយនាយកដ្ឋានជំនាញរបស់ក្រសួង ស្ថាប័នរៀងៗខ្លួន។

២- នៅដើមត្រីមាសទី៤នៃឆ្នាំនីមួយៗ គ្រប់ក្រសួង ស្ថាប័នត្រូវធ្វើការត្រួតពិនិត្យលទ្ធផលនៃការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលទទួលបានកន្លងមក និងត្រូវធ្វើគម្រោងកម្មវិធីនៃតម្រូវការសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលក្រសួង ស្ថាប័ននីមួយៗត្រូវការរៀបចំ ដើម្បីបំពេញការអនុវត្តច្បាប់ឬតម្រូវការសម្រាប់ដំណើរការការងាររបស់

ខ្លួនឱ្យមានប្រសិទ្ធភាពសម្រាប់ឆ្នាំខាងមុខ។ គម្រោងកម្មវិធីនេះត្រូវផ្ញើមកទីស្តីការគណៈរដ្ឋមន្ត្រីយ៉ាងយូរនៅដំណាច់ខែវិច្ឆិកានៃឆ្នាំនីមួយៗ។

៣- ផ្អែកលើគម្រោងកម្មវិធីនៃតម្រូវការសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតរបស់ក្រសួង ស្ថាប័ន នៅដំណាច់ឆ្នាំនីមួយៗដោយមានកំណត់កាលបរិច្ឆេទនៃការប្រគល់មកទីស្តីការគណៈរដ្ឋមន្ត្រីនូវសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងនោះ ទីស្តីការគណៈរដ្ឋមន្ត្រីត្រូវរៀបចំដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យនិងសម្រេចនូវបញ្ជីស្តីពីកម្មវិធីនៃការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល ដោយអនុលោមទៅតាមកាតព្វកិច្ចដែលត្រូវបំពេញតាមរដ្ឋធម្មនុញ្ញឬកាតព្វកិច្ចដែលត្រូវបំពេញដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌនៃអង្គការអន្តរជាតិនានាដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិក។

៤- បន្ទាប់ពីទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីលើកម្មវិធីនៃការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត គ្រប់ក្រសួង ស្ថាប័នត្រូវរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងនោះ ដោយអនុវត្តតាមគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដូចមានជាប់មកជាមួយ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នត្រូវផ្សព្វផ្សាយនិងអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# មាតិកា

**សេចក្តីផ្តើម**

**១- ដំណើរការនៃការរៀបចំសេចក្តីព្រាងដើមនៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត** ១

១.១- សេចក្តីព្រាងដើមដំណាក់កាលទី១ ១

១.២- សេចក្តីព្រាងដើមដំណាក់កាលទី២ ១

**២- ការរៀបចំសេចក្តីថ្លែងហេតុឬកំណត់មូលហេតុសង្ខេប** ២

២.១- សេចក្តីថ្លែងហេតុ ២

២.២- កំណត់មូលហេតុសង្ខេប ៣

**៣- វិធាននៃការតែងសេចក្តីនិងទម្រង់នៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត** ៣

៣.១- វិធាននៃការតែងសេចក្តី ៣

៣.២- ទម្រង់ ៥

៣.២.១- ទម្រង់នៃសេចក្តីព្រាងច្បាប់ ៥

៣.២.២- ទម្រង់នៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ១២

៣.២.៣- ទម្រង់នៃអនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់ ១៨

៣.២.៤- ទម្រង់នៃព្រះរាជក្រម ២៣

៣.២.៥- ទម្រង់នៃព្រះរាជក្រឹត្យ ៣១

៣.២.៦- ទម្រង់នៃព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យ ៦៣

៣.២.៧- ទម្រង់នៃអនុក្រឹត្យ អនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យ សេចក្តីសម្រេច និងសារាចររបស់រាជរដ្ឋាភិបាល ៦៩

៣.២.៧.១- ទម្រង់នៃអនុក្រឹត្យ ៦៩

៣.២.៧.២- ទម្រង់នៃអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យ ៨៧

៣.២.៧.៣- ទម្រង់នៃសេចក្តីសម្រេច ៩៣

៣.២.៧.៤- ទម្រង់នៃសារាចរ ៩៩

៣.២.៨- ទម្រង់នៃប្រកាស ប្រកាសអន្តរក្រសួង សេចក្តីសម្រេច សារាចរ និងសារាចរអន្តរក្រសួងរបស់ក្រសួង ស្ថាប័ន ១០១

៣.២.៨.១- ទម្រង់នៃប្រកាស ១០១

៣.២.៨.២- ទម្រង់នៃប្រកាសអន្តរក្រសួង ១១៣

៣.២.៨.៣- ទម្រង់នៃសេចក្តីសម្រេច ១១៧

៣.២.៨.៤- ទម្រង់នៃសារាចរ ១២១

៣.២.៨.៥- ទម្រង់នៃសារាចរអន្តរក្រសួង ១២៣

**៤- ការបញ្ជូនសំណុំឯកសារទៅទីស្តីការគណៈរដ្ឋមន្ត្រី** ១២៥
៤.១- សេចក្តីស្នើច្បាប់ដែលស្នើសុំឱ្យរាជរដ្ឋាភិបាលផ្តល់អនុសាសន៍ ១២៥
៤.២- សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ ១២៥
៤.៣- សេចក្តីព្រាងច្បាប់ដែលពាក់ព័ន្ធនឹងវិស័យតុលាការ ១២៥
**៥- ការពិនិត្យសំណុំឯកសារនៅទីស្តីការគណៈរដ្ឋមន្ត្រី** ១២៥
៥.១- ការពិនិត្យដោយអង្គប្រជុំជំនាញបច្ចេកទេស ១២៦
៥.២- ការពិនិត្យដោយអង្គប្រជុំអន្តរក្រសួង ១២៦
៥.៣- ការពិនិត្យដោយអង្គប្រជុំត្រួតពិនិត្យជាចុងក្រោយ ១២៦
៥.៤- ការពិនិត្យដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ១២៦
៥.៥- ការពិនិត្យនិងការផ្តល់អនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់ ១២៦
**៦- ការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតក្រោយការប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងការចុះហត្ថលេខាអម** ១២៧
៦.១- សេចក្តីព្រាងច្បាប់ ១២៧
៦.២- ព្រះរាជក្រឹត្យ ១២៧
៦.៣- អនុក្រឹត្យ ១២៨
**៧- ការបញ្ជូនសំណុំឯកសារទៅរដ្ឋសភា** ១២៨
**៨- ការប្រគល់ភារកិច្ចឱ្យទៅការពារសេចក្តីព្រាងច្បាប់នៅរដ្ឋសភានិងព្រឹទ្ធសភា** ១២៩
**៩- នីតិវិធីនិងវិធាននៃការសុំធ្វើវិសោធនកម្មច្បាប់និងសេចក្តីព្រាងច្បាប់** ១២៩
៩.១- ការធ្វើវិសោធនកម្មច្បាប់ជាធរមាន ១២៩
៩.២- ការធ្វើវិសោធនកម្មសេចក្តីព្រាងច្បាប់ដែលគណៈរដ្ឋមន្ត្រីបានឯកភាព ហើយដែលស្ថិតនៅក្នុងរបៀបវារៈរបស់អង្គប្រជុំរដ្ឋសភា ១២៩
៩.៣- ការធ្វើវិសោធនកម្មសេចក្តីព្រាងច្បាប់ដែលគណៈរដ្ឋមន្ត្រីបានឯកភាព ហើយដែលស្ថិតនៅក្នុងគណៈកម្មការនៃរដ្ឋសភា ១២៩
**១០- ការចូលជាធរមាននៃច្បាប់ក្រោយពីការអនុម័តនិងការយល់ព្រមរបស់ស្ថាប័ននីតិប្បញ្ញត្តិ និងការចុះក្នុងរាជកិច្ច** ១៣០

# អារម្ភកថា

គោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ត្រូវបានរៀបចំឡើងដោយផ្អែកលើតម្រូវការនៃការអភិវឌ្ឍសង្គមនិងគោលនយោបាយកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាល ក្រោមយុទ្ធសាស្ត្រស្តីពីការធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់ ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាពការងារ និងធានាបាននូវឯកភាពក្នុងការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

គោលការណ៍ណែនាំនេះត្រូវបានរៀបចំតាក់តែងឡើង ដោយក្រុមការងារជំនាញទីស្តីការគណៈរដ្ឋមន្ត្រីដោយមានការចូលរួមផ្តល់យោបល់ពីអ្នកឯកទេសនៃក្រសួង ស្ថាប័ន និងអង្គភាពជំនាញ មានជាអាទិ៍ អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល ក្រុមប្រឹក្សាអ្នកច្បាប់ ក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងគណៈកម្មការភាសាវិទ្យាខ្មែរ។

គោលការណ៍ណែនាំនេះ ត្រូវបានក្រុមការងារពិនិត្យ ពិភាក្សានិងកែសម្រួល ព្រមទាំងបានឆ្លងអង្គប្រជុំ លើកទី១(បច្ចុប្បន្នហៅថាអង្គប្រជុំជំនាញបច្ចេកទេស)អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យជាចុងក្រោយនិងបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣។

ខ្ញុំជឿជាក់ថា គោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលប្រមូលផ្តុំនូវចំណុចសំខាន់ៗឈានទៅរកឯកភាពលើនីតិវិធីនិងវិធានក្នុងការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត នឹងបានជាមគ្គុទ្ទេសក៍ដ៏សំខាន់សម្រាប់ក្រសួង ស្ថាប័នទាំងអស់ ក្នុងការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងនោះ ដើម្បីធានាបាននូវឯកភាពផ្នែករដ្ឋបាលដែលជាកត្តាមួយយ៉ាងសំខាន់នៃឯកភាពជាតិ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

# សេចក្តីផ្តើម

គោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ត្រូវបានរៀបចំនិងតាក់តែងក្នុងគោលបំណងលើកកម្ពស់គុណភាពនិងប្រសិទ្ធភាព បង្កលក្ខណៈងាយស្រួល និងធានាឱ្យមានឯកភាពក្នុងការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតនៅព្រះរាជាណាចក្រកម្ពុជា។

គោលការណ៍ណែនាំនេះត្រូវបានបែងចែកជាផ្នែកទៅតាមខ្លឹមសារសំខាន់ៗដែលមានសេចក្តីណែនាំលម្អិតក្នុងការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដើម្បីជៀសវាងភាពមិនស៊ីចង្វាក់គ្នាដែលមានកន្លងមក។

ខ្លឹមសារបឋមឆ្លុះបញ្ចាំងនូវដំណាក់កាលនីមួយៗនៃការផ្តួចផ្តើមគំនិតជាសារវន្តរបស់ក្រសួង ស្ថាប័នដែលរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដោយមានការចូលរួមពីសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន ស្របតាមសភាពការណ៍ជាក់ស្តែងនៃសេដ្ឋកិច្ច សង្គម និងវប្បធម៌ ព្រមទាំងសេចក្តីថ្លែងហេតុនិងកំណត់មូលហេតុសង្ខេបដែលជាឯកសារអម។

ខ្លឹមសារបន្ទាប់ដែលជាផ្នែកសំខាន់និងជាកម្មវត្ថុចម្បងនៃការដាក់ចេញនូវគោលការណ៍ណែនាំនេះ អត្ថាធិប្បាយពីវិធាននៃការតែងសេចក្តីនិងទម្រង់នៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដោយមានភ្ជាប់ជាមួយនូវគំរូទម្រង់ដែលជាគោលគំនិតទូទៅសម្រាប់យកទៅអនុវត្តជាក់ស្តែង។

ខ្លឹមសារចុងក្រោយរៀបរាប់ជាអាទិ៍ពីដំណើរការនៃការពិនិត្យសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតនៅទីស្តីការគណៈរដ្ឋមន្ត្រី ការរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោយការប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ការបញ្ជូនសំណុំឯកសារទៅរដ្ឋសភា ការការពារសេចក្តីព្រាងច្បាប់ចំពោះមុខអង្គនីតិប្បញ្ញត្តិ និងការចូលជាធរមាននៃច្បាប់។

គោលការណ៍ណែនាំនេះត្រូវបានចាត់ទុកជាត្រីវិស័យសម្រាប់តម្រង់ទិសក្រុមការងារ ក្រុមជំនាញរបស់ក្រសួង ស្ថាប័នឱ្យមានស្មារតីទទួលខុសត្រូវ ស្គាល់ភារកិច្ចរបស់ខ្លួន ចំណេញពេលវេលា និងធានាឱ្យមានឯកភាពក្នុងការរៀបចំនិងតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ដើម្បីឱ្យការរៀបចំនិងការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតមានឯកភាព នៅទូទាំងព្រះរាជាណាចក្រកម្ពុជា គោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ត្រូវបានកំណត់ដូចតទៅ៖

**១- ដំណើរការនៃការរៀបចំសេចក្តីព្រាងដើមនៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត**

ជាទូទៅ សេចក្តីព្រាងដើមនៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលត្រូវឆ្លងទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវបានក្រសួង ស្ថាប័នទទួលបន្ទុក ប្រគល់ភារកិច្ចឱ្យអង្គភាពនីតិកម្មរបស់ក្រសួង ស្ថាប័ន សហការជាមួយនាយកដ្ឋានជំនាញរៀបចំជា២ដំណាក់កាល៖

**១.១- សេចក្តីព្រាងដើមដំណាក់កាលទី១**

សេចក្តីព្រាងដើមដំណាក់កាលទី១ត្រូវសរសេរលើក្រដាសពណ៌សដែលមានក្បាលលិខិតរបស់ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំ ដោយកត់ត្រាទុកឱ្យបានច្បាស់លាស់នូវ៖

- ឈ្មោះរបស់អង្គភាពទទួលភារកិច្ចរៀបចំសេចក្តីព្រាងនិងអង្គភាពពាក់ព័ន្ធរបស់ក្រសួង ស្ថាប័នដែលបានចូលរួម
- ឈ្មោះរបស់រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬអគ្គនាយកដែលទទួលបន្ទុកតាមដានកិច្ចការរៀបចំសេចក្តីព្រាង
- ឈ្មោះរបស់អ្នកជំនាញការនិងចំណេះដឹងអត្ថបទជាភាសាបារាំងនិងឬ/អង់គ្លេសដែលជាមូលដ្ឋានបង្អែក ប្រសិនបើមាន
- ឈ្មោះរបស់អ្នកច្បាប់ដែលជួយរៀបចំសេចក្តីព្រាង
- លេខទូរស័ព្ទ លេខទូរសារ និងឬ/អាសយដ្ឋានអ៊ីម៉ែលរបស់អង្គភាពនិងអ្នកដែលទទួលបន្ទុករៀបចំខាងលើ។

ចំពោះការរៀបចំសេចក្តីព្រាងដើមដំណាក់កាលទី១ ក្រសួង ស្ថាប័នសាមីត្រូវធ្វើការពិគ្រោះយោបល់ក្នុងករណីចាំបាច់ ជាមួយសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន ដោយយោងទៅលើវិសាលភាពដែលទាក់ទងនឹងបញ្ហាសង្គម បញ្ហាសេដ្ឋកិច្ច និងបញ្ហាថវិកា និងត្រូវសុំយោបល់ពីក្រសួង ស្ថាប័ន រាជធានី ខេត្តដែលពាក់ព័ន្ធ ហើយត្រូវធ្វើការកែសម្រួលសេចក្តីព្រាងដើមដំណាក់កាលទី១ ឱ្យបានសព្វគ្រប់សម្រាប់ការពិនិត្យពិភាក្សានៅដំណាក់កាលទី២។

**១.២- សេចក្តីព្រាងដើមដំណាក់កាលទី២**

ក្រសួង ស្ថាប័នសាមីត្រូវសុំយោបល់ឡើងវិញពីក្រសួង ស្ថាប័ន រាជធានី ខេត្តដែលពាក់ព័ន្ធដោយផ្ទាល់ឬដោយប្រយោលលើសេចក្តីព្រាងដើមដំណាក់កាលទី១ និងធ្វើការពិគ្រោះយោបល់ឡើងវិញក្នុងករណីចាំបាច់ ជាមួយសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជនឱ្យបានគ្រប់ជ្រុងជ្រោយលើទិដ្ឋភាពបច្ចេកទេស សង្គម វប្បធម៌ និងនយោបាយ ដើម្បីស្រង់មតិឬប្រតិកម្មរបស់មជ្ឈដ្ឋានទាំងនោះ តាមលិខិតឬតាមអង្គប្រជុំ ហើយត្រូវធ្វើរបាយការណ៍ពីលទ្ធផល ដូចជា៖

- មតិរបស់បណ្តាក្រសួង ស្ថាប័ន រាជធានី ខេត្តដែលពាក់ព័ន្ធនិងមជ្ឈដ្ឋានដែលបានពិគ្រោះយោបល់
- មតិរបស់ក្រុមការងារ ដោយគូសបញ្ជាក់នូវ៖
    - រាល់ចំណុចខ្វែងគំនិតគ្នា

• យោបល់សម្របសម្រួលនិងការធ្វើសម្បទានរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងយោបល់របស់មជ្ឈដ្ឋានដែលបានពិគ្រោះ ព្រមទាំងជំហររបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលមិនព្រមធ្វើការកែប្រែតាម

- យោបល់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះការងារពាក់ព័ន្ធនឹងការចំណាយថវិការដ្ឋ។

ក្រោយពីការសុំនិងពិគ្រោះយោបល់ខាងលើ ក្រសួង ស្ថាប័នសាមីត្រូវពិនិត្យកែសម្រួលសេចក្តីព្រាងដើមដំណាក់កាលទី១ ឱ្យទៅជាសេចក្តីព្រាងដើមដំណាក់កាលទី២ ព្រមទាំងកែសម្រួលសេចក្តីថ្លែងហេតុឬកំណត់មូលហេតុសង្ខេបឡើងវិញ រួចធ្វើរបាយការណ៍ភ្ជាប់ជាមួយសំណុំឯកសារបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី។

សំណុំឯកសារដែលត្រូវបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី មាន៖

- សេចក្តីព្រាងអត្ថបទ

- សេចក្តីថ្លែងហេតុចំពោះសេចក្តីព្រាងអត្ថបទដែលត្រូវសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ ឬកំណត់មូលហេតុសង្ខេបចំពោះសេចក្តីព្រាងអត្ថបទដែលត្រូវសុំព្រះរាជតម្រិះពីព្រះមហាក្សត្រឬសុំការសម្រេចពីប្រមុខរដ្ឋស្តីទីឬពីប្រមុខរាជរដ្ឋាភិបាល។

សំណុំឯកសារនេះត្រូវបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីតាមលិខិតបញ្ជូនដែលប្រធានស្ថាប័នចុះហត្ថលេខា។

## ២- ការរៀបចំសេចក្តីថ្លែងហេតុឬកំណត់មូលហេតុសង្ខេប

### ២.១- សេចក្តីថ្លែងហេតុ

សេចក្តីថ្លែងហេតុជាអត្ថបទដែលត្រូវភ្ជាប់ជាមួយសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលត្រូវសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា៩០ថ្មីនៃរដ្ឋធម្មនុញ្ញ។

សេចក្តីថ្លែងហេតុត្រូវសរសេរឱ្យមានន័យច្បាស់លាស់ ចំបញ្ហា ខ្លី ហើយងាយយល់ ដោយមានការលើកឡើងអំពី៖

- គោលបំណងនិងស្មារតីរបស់សេចក្តីព្រាងអត្ថបទ ដោយពន្យល់ឱ្យបានច្បាស់លាស់អំពីខ្លឹមសារជាសារវន្តព្រមទាំងផលប្រយោជន៍ដែលទទួលបានពីការដាក់ចេញនូវសេចក្តីព្រាងទាំងនោះឬមូលហេតុដែលនាំឱ្យមានការកែប្រែច្បាប់ឬបទប្បញ្ញត្តិជាធរមាន

- ហេតុផលនិងការវាយតម្លៃលើផលវិបាកដែលមាន

- វិភាគទានរបស់សេចក្តីព្រាងអត្ថបទចំពោះសមិទ្ធកម្មនៃរដ្ឋធម្មនុញ្ញ ច្បាប់ជាធរមាននានា ផែនការសកម្មភាព និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងស្ថានភាពជាក់ស្តែងរបស់ប្រទេសជាតិ

- ខ្លឹមសារសង្ខេបអំពីជំពូកសំខាន់ៗ ជាពិសេសទោសប្បញ្ញត្តិ ចំពោះសេចក្តីព្រាងច្បាប់។

សេចក្តីថ្លែងហេតុដែលត្រូវភ្ជាប់ជាមួយសេចក្តីព្រាងអត្ថបទដែលត្រូវបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់ដាក់សុំឆ្លងអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យជាចុងក្រោយ និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ត្រូវសរសេរក្នុងនាមប្រធានស្ថាប័នសាមី ដោយមានលិខិតស្នើរបស់ប្រធានស្ថាប័ននោះ ផ្ញើជូនប្រមុខរាជរដ្ឋាភិបាល។ បន្ទាប់ពីបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រសួង ស្ថាប័នសាមីត្រូវកែសម្រួលសេចក្តីថ្លែងហេតុ ដោយសរសេរក្នុងនាមប្រមុខរាជរដ្ឋាភិបាលនិងបញ្ជាក់ពីកាលបរិច្ឆេទដែលសេចក្តីព្រាងអត្ថបទត្រូវបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី រួចធ្វើលិខិតស្នើដាក់សុំហត្ថលេខាប្រមុខរាជរដ្ឋាភិបាលផ្ញើជូនប្រធានរដ្ឋសភា។

ចំណងជើងនៃសេចក្តីថ្លែងហេតុ ត្រូវសរសេរដូចខាងក្រោម៖

**សេចក្តីថ្លែងហេតុ**

**អំពី**

**សេចក្តីព្រាង...ស្តីពី...**

**២.២- កំណត់មូលហេតុសង្ខេប**

កំណត់មូលហេតុសង្ខេបជាអត្ថបទដែលត្រូវភ្ជាប់ជាមួយសេចក្តីព្រាងព្រះរាជក្រឹត្យដែលត្រូវសុំព្រះរាជតម្រិះពីព្រះមហាក្សត្រ និងជាមួយសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលត្រូវសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល។

កំណត់មូលហេតុសង្ខេបត្រូវសរសេរឱ្យមានន័យច្បាស់លាស់ ចំបញ្ហា ខ្លី ហើយងាយយល់ ដោយមានការលើកឡើងអំពី៖

- មូលហេតុដែលនាំឱ្យមានការរៀបចំអត្ថបទនេះឬការកែប្រែបទប្បញ្ញត្តិដែលនៅជាធរមាននិងផលប៉ះពាល់វិជ្ជមាននិងអវិជ្ជមានដល់បញ្ហាសេដ្ឋកិច្ច សង្គមកិច្ច
- ខ្លឹមសារសំខាន់ៗនៃអត្ថបទ។

កំណត់មូលហេតុសង្ខេបដែលត្រូវភ្ជាប់ជាមួយសេចក្តីព្រាងព្រះរាជក្រឹត្យ ត្រូវចុះហត្ថលេខាដោយប្រមុខរាជរដ្ឋាភិបាលសម្រាប់ដាក់ថ្វាយព្រះមហាក្សត្រឬជូនប្រមុខរដ្ឋស្តីទី មានទម្រង់ជាលិខិតស្នើរបស់រាជរដ្ឋាភិបាលដែលសរសេរជាអក្សរកាត់ថា ល.ស.។ កំណត់មូលហេតុសង្ខេបដែលត្រូវភ្ជាប់ជាមួយលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតត្រូវចុះហត្ថលេខាដោយប្រធានស្ថាប័នសាមី សម្រាប់ដាក់ជូនប្រមុខរាជរដ្ឋាភិបាល។

ចំពោះកំណត់មូលហេតុសង្ខេបស្តីពីការតែងតាំង ត្រូវបញ្ជាក់ពីមូលហេតុខ្លីៗពីកម្មវត្ថុដែលតម្រូវឱ្យមានការតែងតាំងនិងមានភ្ជាប់សំណុំឯកសារចាំបាច់មួយចំនួន មានជាអាទិ៍៖

- សំណើរបស់ក្រសួង ស្ថាប័នសាមី ដែលមានការបញ្ជាក់ពីតម្រូវការនៃការតែងតាំង ស្ថានភាពទំនេរនៃមុខតំណែង សមត្ថភាព បទពិសោធ និងគុណសម្បត្តិនៃមន្ត្រីរាជការដែលត្រូវតែងតាំង
- សំណុំលិខិតស្នើតែងតាំងដែលត្រូវមានភ្ជាប់តារាងបញ្ជាក់ពីឈ្មោះ ថ្ងៃខែឆ្នាំកំណើត កម្រិតវប្បធម៌ កម្រិតជំនាញ អត្តលេខ(បើមាន) ឋានន្តរសក្តិ ថ្នាក់ ក្របខ័ណ្ឌ មុខងារបច្ចុប្បន្ន និងមុខងារស្នើតែងតាំង ព្រមទាំងជីវប្រវត្តិរបស់សាមីជននិងសញ្ញាបត្រដែលមាន
- លិខិតបញ្ជាក់ដែលជាទិដ្ឋាការរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

ប្រសិនបើការតែងតាំងជាក្រុម ដូចជាអាជ្ញាធរ ក្រុមប្រឹក្សាជាដើម ត្រូវភ្ជាប់បន្ថែមនូវបញ្ជីឈ្មោះរបស់អ្នកដែលត្រូវតែងតាំងនិងអត្ថបទជាមូលដ្ឋានដែលនាំឱ្យមានការតែងតាំងនោះ។

ចំណងជើងនៃកំណត់មូលហេតុសង្ខេប ត្រូវសរសេរដូចខាងក្រោម៖

**កំណត់មូលហេតុសង្ខេប**

**អំពី**

**សេចក្តីព្រាង...ស្តីពី...**

**៣- វិធាននៃការតែងសេចក្តីនិងទម្រង់នៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត**

**៣.១- វិធាននៃការតែងសេចក្តី**

ការតែងសេចក្តីនៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ត្រូវអនុវត្តដូចតទៅ៖

៣.១.១- ក្បាលលិខិត

ក្បាលលិខិតត្រូវដាក់ចំណងជើងនៃសេចក្ដីព្រាងអត្ថបទឱ្យបានច្បាស់លាស់និងគ្រប់គ្រាន់ ហើយបើជាអត្ថបទដែលត្រូវធ្វើវិសោធនកម្ម ត្រូវបញ្ជាក់នៅក្នុងចំណងជើងស្ដីពីវិសោធនកម្ម។

៣.១.២- មូលបទ

មូលបទត្រូវ៖

- ចែងលេខ ថ្ងៃខែឆ្នាំ និងចំណងជើងនៃលិខិតបទដ្ឋានគតិយុត្តដែលត្រូវយោងឱ្យបានពេញលេញ ហើយមិនត្រូវប្រើសញ្ញាខណ្ឌនៅចុងឃ្លានៃគំនូសចុងក្រោយទេ

ឧទាហរណ៍ : - បានឃើញអនុក្រឹត្យលេខ... ចុះថ្ងៃទី...(លេខ) ខែ...(អក្សរ) ឆ្នាំ...(លេខ) ស្ដីពី...(ចំណងជើងនៃអនុក្រឹត្យដែលយោងទាំងស្រុង)

- បានឃើញសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ... ចុះថ្ងៃទី... (លេខ) ខែ...(អក្សរ) ឆ្នាំ...(លេខ) ស្ដីពី...(ចំណងជើងនៃសេចក្ដីសម្រេចដែលយោងទាំងស្រុង)

- យោងតែលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដោយផ្ទាល់ ដែលមិនមានឋានានុក្រមទាបជាង។

៣.១.៣- ខ្លឹមសារនៃអត្ថបទ

ខ្លឹមសារនៃអត្ថបទត្រូវ៖

- ចែងខ្លឹមសារឱ្យបានច្បាស់លាស់ ហើយត្រូវខិតខំប្រើពាក្យដែលមាននិយមន័យច្បាប់ចំៗ ច្បាស់លាស់ និងពាក្យដែលមិននាំឱ្យមានការបកស្រាយខុសពីស្មារតីដើមដែលចង់បាន ក្នុងនោះត្រូវ៖
  - ប្រើពាក្យបច្ចេកទេសដែលមាននៅក្នុងច្បាប់និងមានក្នុងសៀវភៅបោះពុម្ពដោយវិស័យអប់រំ ឬពាក្យបច្ចេកទេសដែលគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ឬក្រុមប្រឹក្សាជាតិភាសាខ្មែរបានអនុម័ត និងដែលរាជរដ្ឋាភិបាលបានប្រកាសឱ្យប្រើ ហើយក្នុងការសរសេរត្រូវផ្អែកលើសទ្ទានុក្រមរបស់គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ឬវចនានុក្រមខ្មែរបោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យគ្រាទី៥
  - ចៀសវាងការប្រើពាក្យបាលីសំស្ក្រឹតឬពាក្យបរទេសឱ្យអស់លទ្ធភាព
  - មិនអនុញ្ញាតឱ្យប្រើពាក្យ នឹង នៅមុខកិរិយាសព្ទទេ
  - មិនអនុញ្ញាតឱ្យដាក់លេខយោងទៅបកស្រាយនៅរឹមខាងក្រោមនៃទំព័រទេ។
- តែងឈ្មោះខ្លីៗតែមានន័យគ្រប់គ្រាន់ ដោយមានការដកឃ្លានិងការដាក់សញ្ញាខណ្ឌឱ្យបានត្រឹមត្រូវ
- ប្រើពាក្យ " មានជាអាទិ៍ " ក្នុងការរៀបរាប់មិនអស់ មិនត្រូវប្រើពាក្យ " ។ល។ " ទេ
- ចៀសវាងការគូសបន្ទាត់នៅក្រោមចំណងជើងជំពូក ផ្នែក អនុផ្នែកឬកថាភាគ មាត្រា និងប្រការក៏ដូចជាក្នុងខ្លឹមសារច្បាប់ទាំងមូល តែប្រើអក្សរមូលដិតខ្មៅចំពោះឈ្មោះឬអក្សរកាត់នៃឈ្មោះគ្រឹះស្ថានសាធារណៈ ឈ្មោះទិវាជាតិនានាជាដើម
- សរសេរចំណងជើងនៃសេចក្ដីព្រាងអត្ថបទឱ្យធំជាងចំណងជើងជំពូក ចំណងជើងជំពូកឱ្យធំជាងចំណងជើងផ្នែក ហើយចំណងជើងផ្នែកឱ្យធំជាងចំណងជើងអនុផ្នែកឬកថាភាគ ចំណែកឯចំណងជើងច្បាប់ ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច ប្រកាស សារាចរ និងគន្លឹះ ជំពូក ផ្នែក អនុផ្នែកឬកថាភាគ មាត្រា និងប្រការ ត្រូវប្រើអក្សរមូលដិតខ្មៅ

- សរសេរជាលេខខ្មែរមុន រួចទើបសរសេរជាអក្សរក្នុងវង់ក្រចកចំពោះចំនួនក្នុងខ្លឹមសារនៃអត្ថបទ លើកលែងតែលេខរបស់គន្លី ជំពូក ផ្នែក អនុផ្នែកឬកថាភាគ មាត្រា ប្រការ កថាខណ្ឌ ដែលត្រូវសរសេរជាលេខដិតខ្មៅ
- ចៀសវាងការដាក់ឈ្មោះរបស់សាមីជនក្នុងព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរក្រុមប្រឹក្សាជាតិឬក្នុងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិនានា តែត្រូវដាក់មុខតំណែងឬមុខងារ និងតួនាទីនៃតំណាងក្រសួង ស្ថាប័នសាមីវិញ ចំណែកឯការតែងតាំងសាមីជនត្រូវធ្វើដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លើកលែងតែករណីដែលមានការកំណត់ឱ្យតែងតាំងសាមីជនដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ
- បញ្ជាក់ពីឈ្មោះ អត្តលេខ(បើមាន) ឋានន្តរសក្តិ ថ្នាក់ ក្របខ័ណ្ឌ មុខងាររបស់សាមីជន ដោយសរសេរឈ្មោះជាអក្សរខ្មែរឱ្យបានត្រឹមត្រូវ ចំពោះការតែងតាំងមន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ចំណែកឯការតែងតាំងជំនួសមន្ត្រីដែលត្រូវបានបញ្ចប់ភារកិច្ច ត្រូវចែងបន្ថែមថា "ជំនួសឯកឧត្តម...(ឈ្មោះ) ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត) " និងត្រូវចែងអំពីការរក្សាឬការបញ្ចប់ភារកិច្ចបច្ចុប្បន្នរបស់សាមីជនដែលទទួលការតែងតាំងឱ្យកាន់តំណែងថ្មីក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ឬប្រកាសរបស់ក្រសួងស្តីពីការតែងតាំង ការផ្លាស់ប្តូរ ឬការបញ្ចប់ភារកិច្ច
- ប្រើពាក្យ មាត្រា សម្រាប់តែក្នុងក្រម ច្បាប់ ព្រះរាជក្រឹត្យ និងអនុក្រឹត្យ ចំណែកពាក្យ ប្រការ វិញ ប្រើសម្រាប់តែក្នុងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ប្រកាស និងសេចក្តីសម្រេចរបស់ក្រសួង
- ចែងល្បះក្នុងឧបសម្ព័ន្ធថា ឧបសម្ព័ន្ធទី...នៃព្រះរាជក្រឹត្យលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី(ចំណងជើង) ឬ នៃអនុក្រឹត្យលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី(ចំណងជើង) ក្នុងករណីដែលលិខិតបទដ្ឋានគតិយុត្តនោះមានឧបសម្ព័ន្ធភ្ជាប់។

### ៣.២- ទម្រង់

ទម្រង់នៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ត្រូវអនុលោមតាមប្រភេទដូចខាងក្រោម៖

#### ៣.២.១- ទម្រង់នៃសេចក្តីព្រាងច្បាប់

ក- ក្របសន្លឹកទំព័រដំបូង

ក.១- ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ដែលត្រូវដាក់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យជាចុងក្រោយ និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រសួង ស្ថាប័នសាមី ត្រូវប្រើក្រដាសក្បាលលិខិតរបស់ក្រសួង ស្ថាប័ន ហើយនៅចំកណ្តាលសន្លឹកទំព័រនេះ ត្រូវដាក់ពាក្យ **សេចក្តីព្រាង** ក្រោមពាក្យសេចក្តីព្រាង ចំកណ្តាលដាក់ពាក្យ **ច្បាប់** ក្រោមពាក្យច្បាប់ ចំកណ្តាលដាក់ពាក្យ **ស្តីពី** ក្រោមពាក្យស្តីពី ដាក់ចំណងជើងនៃសេចក្តីព្រាងច្បាប់។ នៅប៉ែកខាងក្រោមនៃទំព័រ ត្រូវដាក់កាលបរិច្ឆេទក្រោយបង្អស់ដែលក្រសួង ស្ថាប័ន បានរៀបចំសេចក្តីព្រាងអត្ថបទនោះផ្ញើទៅទីស្តីការគណៈរដ្ឋមន្ត្រី។

សូមមើលគំរូទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ដែលត្រូវដាក់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យជាចុងក្រោយ និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទំព័រទី០៩។

ក.២- ចំពោះក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ក្រោយឆ្លងអង្គប្រជុំគណៈរដ្ឋមន្ត្រីរួចហើយ ដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ ក្រសួង ស្ថាប័នសាមី ត្រូវប្រើក្រដាសក្បាលលិខិតរបស់រាជរដ្ឋាភិបាល ហើយ

នៅចំកណ្តាលសន្លឹកទំព័រនេះ ត្រូវដាក់ពាក្យ **សេចក្តីព្រាង** ក្រោមពាក្យសេចក្តីព្រាង ចំកណ្តាលដាក់ពាក្យ **ច្បាប់** ក្រោមពាក្យច្បាប់ ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យស្តីពី ដាក់ចំណងជើងនៃសេចក្តីព្រាងច្បាប់។ នៅប៉ែកខាងក្រោមនៃទំព័រ ត្រូវដាក់ថា " **បានឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី... ខែ... ឆ្នាំ...**"។

សូមមើលគំរូទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ក្រោយឆ្លងអង្គប្រជុំតាមនីតិវិធី ដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ នៅទំព័រទី១០។

ខ- សន្លឹកទំព័របន្តបន្ទាប់

ជាទូទៅ ក្រសួង ស្ថាប័នសាមីត្រូវតែងសេចក្តីដោយរៀបចំចែកអត្ថបទជាជំពូក ផ្នែក អនុផ្នែក ឬកថាភាគ និងសរសេរបទប្បញ្ញត្តិជា មាត្រា។ ក្នុងករណីដែលអត្ថបទនៃសេចក្តីព្រាងច្បាប់នេះវែង ហើយមានបទប្បញ្ញត្តិច្រើនដែលត្រូវចែង អាចចែកជាគន្ថី មាតិកា ជំពូក ផ្នែក អនុផ្នែកឬកថាភាគ និងសរសេរបទប្បញ្ញត្តិជា មាត្រា។ ពាក្យគន្ថី មាតិកា ជំពូក ផ្នែក និងអនុផ្នែកឬកថាភាគ ត្រូវដាក់នៅចំកណ្តាលទំព័រនិងមានដាក់ចំណងជើងនៅចំកណ្តាល ក្រោមពាក្យគន្ថី មាតិកា ជំពូក ផ្នែក និងអនុផ្នែកឬកថាភាគដែរ។ ចំណែកនៅតាមមាត្រានីមួយៗ ជាទូទៅមិនត្រូវមានចំណងជើងទេ តែក្នុងករណីចាំបាច់ អាចអនុញ្ញាតបានចំពោះតែកម្រងច្បាប់ធំៗ ដូចជាក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌជាដើម។ គន្ថី មាតិកា ជំពូក ផ្នែក និងអនុផ្នែកឬកថាភាគ ត្រូវដាក់លេខរៀងតាមលំដាប់លំដោយ ហើយត្រូវមានដាក់ពាក្យ ទី នៅចន្លោះពាក្យគន្ថី មាតិកា ជំពូក ផ្នែក អនុផ្នែកឬកថាភាគ និងលេខ។

ឧទាហរណ៍ : **គន្ថីទី១ មាតិកាទី១ ជំពូកទី១ ផ្នែកទី១ អនុផ្នែកទី១**។

ចំពោះមាត្រា ត្រូវចាប់ផ្តើមសរសេរឃ្លាតពីរឹមទំព័រខាងឆ្វេង ដោយដាក់លេខនៅក្រោយពាក្យមាត្រា ហើយមិនត្រូវប្រើពាក្យ ទី នៅចន្លោះមាត្រានិងលេខឡើយ។

ឧទាហរណ៍ : **មាត្រា១ .-**។

ខ.១- ជំពូក

**ជំពូកទី១** ចែង **បទប្បញ្ញត្តិទូទៅ**

នៅក្នុងជំពូកនេះ ត្រូវចែងពីគោលបំណង គោលដៅ និងវិសាលភាពនៃច្បាប់និងបទប្បញ្ញត្តិដែលមានអានុភាពប្រើរួមសម្រាប់ច្បាប់ទាំងមូល ហើយអាចមាននិយមន័យផងដែរ។ គោលបំណង គោលដៅ និងវិសាលភាពនៃច្បាប់ ត្រូវចែងជាបន្តបន្ទាប់នៅក្នុងមាត្រា១ មាត្រា២ និងមាត្រា៣។ ប្រសិនបើមាននិយមន័យនៃបច្ចេកសព្ទឬវាក្យសព្ទសំខាន់ៗ និយមន័យនោះត្រូវចែងនៅក្នុងមាត្រា៤ឬនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់។

**ជំពូកទី២** (ចំណងជើង) និង **ជំពូក** បន្តបន្ទាប់

ជំពូកទី២និងជំពូកបន្តបន្ទាប់អាចចែកជាផ្នែក ហើយត្រូវចែងពីខ្លឹមសារពិស្តារទាំងឡាយ ដែលមានគោលដៅដាក់ជាបញ្ញត្តិដើម្បីឱ្យអនុវត្ត ហើយត្រូវចែងលម្អិតតាមផ្នែកដោយឡែកៗ ដែលច្បាប់ត្រូវបញ្ញត្ត។

**ជំពូកទី...** ចែង **ទោសប្បញ្ញត្តិ**

នៅក្នុងជំពូកនេះ ត្រូវចែងពីទោស ស្ថានទម្ងន់ទោស ស្ថានសម្រាលទោស និងការដាក់ពិន័យទាំងឡាយ ចំពោះអំពើប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិដែលបានដាក់នៅក្នុងច្បាប់។ ការចែងពីទោសប្បញ្ញត្តិដែលពាក់ព័ន្ធនឹងមាត្រាណាមួយ ត្រូវយោងទៅលេខមាត្រានោះឱ្យច្បាស់ចំៗតែម្តង។

**ជំពូកទី...** ចែង **អន្តរប្បញ្ញត្តិ** (ប្រសិនបើមាន)

ជំពូកនេះអាចចែងបានតែចំពោះករណីដែលកំណត់រយៈពេលមួយជាកំណត់សម្រាប់ផ្តល់លទ្ធភាពឱ្យបំពេញបែបបទអន្តរកាល ដើម្បីសម្រួលការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ថ្មីដែលចូលជាធរមានជំនួសច្បាប់ឬបទប្បញ្ញត្តិនៃច្បាប់ចាស់ដែលពាក់ព័ន្ធ។ ប្រសិនបើមានបដិប្បញ្ញត្តិ ត្រូវរៀបចំចែងក្នុងជំពូកនេះដែរ។

**ជំពូកទី...** ចែង **អវសានប្បញ្ញត្តិ**

ជំពូកនេះមានតែ១ឬ២មាត្រាយ៉ាងច្រើន ដែលក្នុងនោះអាចមានមាត្រាមួយដែលចែងថា " បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ " និងអាចមានមាត្រាមួយទៀតដែលចែងថា " ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ " ចំពោះតែករណីច្បាប់ណាដែលត្រូវអនុវត្តជាប្រញាប់តែប៉ុណ្ណោះ។

ត្រង់ប៉ែកខាងស្តាំ១ភាគ៣នៃទំព័រចុងក្រោយបង្អស់នៃអត្ថបទ ត្រូវសរសេរដូចខាងក្រោម៖

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំរដ្ឋសភា
លើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី...។
រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**ប្រធានរដ្ឋសភា**

ខ.២- មាត្រា

មាត្រាត្រូវដាក់លេខរៀងតាមលំដាប់លំដោយ ដោយចាប់ផ្តើមពីមាត្រា១នៃសេចក្តីព្រាងច្បាប់នោះ។ នៅក្រោយលេខមាត្រា ត្រូវចុចរូចគូសគំនូសដូចក្នុងវង់ក្រចកនេះ(**មាត្រា១ .-**) មិនត្រូវប្រើសញ្ញាចំណុចពីរ (:)ទេ។

ការតែងសេចក្តីនៅតាមមាត្រានីមួយៗត្រូវផ្តើមឈ្មោះដោយចុះបន្ទាត់មកក្រោមលេខមាត្រា ហើយសរសេរស្មើនឹងដើមលេខនៃមាត្រានោះ។ ពេលសរសេរមិនអស់ចូលដល់បន្ទាត់ទី២ ត្រូវចាប់ផ្តើមសរសេរឈ្មោះបន្តស្មើនឹងដើមពាក្យមាត្រា។

ឧទាហរណ៍ :

(ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម)

**មាត្រា១ .-**

ច្បាប់នេះមានគោលបំណងកាត់បន្ថយហានិភ័យដែលបង្កដោយការប្រើប្រាស់ថ្នាំកសិកម្មនិងជីកសិកម្ម ដើម្បីផលប្រយោជន៍របស់កសិករនិងប្រជាពលរដ្ឋទូទាំងប្រទេស ដោយធានាបាននូវសន្តិសុខស្បៀង សុវត្ថិភាពស្បៀង សុខភាពសាធារណៈ និងនិរន្តរភាពនៃបរិស្ថាន។

មាត្រានីមួយៗអាចចែកជាកថាខណ្ឌ ហើយកថាខណ្ឌអាចចែកជាវាក្យខណ្ឌ។ ក៏ប៉ុន្តែក្នុងមាត្រានីមួយៗ គួរចែងបទប្បញ្ញត្តិតែមួយ ហើយមិនត្រូវផ្តើមមាត្រាដោយដាក់លេខកថាខណ្ឌតែម្តងទេ ត្រូវតែមានឈ្មោះផ្តើមដើម្បីអត្ថាធិប្បាយអំពីកថាខណ្ឌដែលត្រូវដាក់លេខរៀង។ ក្នុងករណីមានខ្លឹមសារដោយឡែកពីគ្នា ត្រូវតែមានសញ្ញាខណ្ឌនៅចុងឈ្មោះគ្រប់លេខរៀងទាំងអស់ តែក្នុងករណីដែលការរៀបរាប់ទាំងនោះជាកន្សោមនៃលក្ខខណ្ឌដែលច្បាប់នោះបញ្ញត្តឱ្យមានរួមគ្នាទាំងអស់ ត្រូវដាក់គំនូស ហើយមិនដាក់សញ្ញាខណ្ឌនៅចុងវាក្យខណ្ឌនីមួយៗនោះទេគឺដាក់សញ្ញាខណ្ឌនៅខាងចុងវាក្យខណ្ឌក្រោយបង្អស់តែប៉ុណ្ណោះ។ នៅខាងចុងឈ្មោះផ្តើមរបស់មាត្រានីមួយៗ ត្រូវប្រើសញ្ញាដំពីរ(៖) មិនត្រូវប្រើសញ្ញាចំណុចពីរ(:)ឡើយ។

ឧទាហរណ៍ក្នុងករណីដាក់លេខរៀង៖

(ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ)

**មាត្រា៥ ._**

នៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យជាប្រាក់ផង តុលាការអាចប្រកាស៖

១- ទោសជាប់ពន្ធនាគារនិងទោសពិន័យគ្រួតគ្នា។

២- ទោសដាក់ពន្ធនាគារតែមួយប៉ុណ្ណោះ។

៣- ឬក៏ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ។

ឧទាហរណ៍ក្នុងករណីដាក់គំនូស៖

(ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា)

**មាត្រា២៣ ._**

ក្រសួងធនធានទឹកនិងឧតុនិយមអាចប្រកាសទុកជាតំបន់អាសន្នឬជាតំបន់ហាមឃាត់ការប្រើប្រាស់ទឹក ក្នុងករណីដែល៖

- ទឹកលើដីឬទឹកក្រោមដីត្រូវបានប៉ះពាល់ផ្នែកបរិមាណ គុណភាព ឬតុល្យភាពអេកូឡូស៊ី
- ទឹកលើទីជម្រាលដែលកំពុងរងការគំរាមកំហែងដោយសកម្មភាពមនុស្សឬធម្មជាតិ
- ទឹកដែលបណ្តាលឱ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ។

សូមមើលគំរូទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់ នៅទំព័រទី១១។

គំរូទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ដែលត្រូវដាក់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេស
អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យជាចុងក្រោយ និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

(សញ្ញាក្រសួង ស្ថាប័ន)
**ក្រសួង**... (ឈ្មោះក្រសួង ស្ថាប័ន)

**សេចក្តីព្រាង**
**ច្បាប់**
**ស្តីពី**
(ចំណងជើងនៃសេចក្តីព្រាងច្បាប់ជាអក្សរមូល)

**ថ្ងៃ... ខែ... ឆ្នាំ...**
(កាលបរិច្ឆេទក្រោយបង្អស់នៃអត្ថបទដែលក្រសួង ស្ថាប័នសាមីបានរៀបចំ)

គំរូទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ក្រោយឆ្លងអង្គប្រជុំតាមនីតិវិធី
ដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ



(សញ្ញាជាតិដូចក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានបោះពុម្ពលើកទី១)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**សេចក្តីព្រាង**

**ច្បាប់**

**ស្តីពី**

(ចំណងជើងនៃសេចក្តីព្រាងច្បាប់ជាអក្សរមូល)

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី... ខែ... ឆ្នាំ...**

គំរូទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

........................................................................................................។

## ជំពូកទី២ និង ជំពូកបន្តបន្ទាប់
(ចំណងជើង)

**មាត្រា... .-**

........................................................................................................។

## ជំពូកទី...
## ទោសប្បញ្ញត្តិ

**មាត្រា... .-**

........................................................................................................។

## ជំពូកទី...
## អន្តរប្បញ្ញត្តិ (ប្រសិនបើមាន)

**មាត្រា... .-**

........................................................................................................។

## ជំពូកទី...
## អវសានប្បញ្ញត្តិ

**មាត្រា... .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា... .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់(ក្នុងករណីដែលច្បាប់ត្រូវអនុវត្តជាប្រញាប់)។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំរដ្ឋសភា
លើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី...។
រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**ប្រធានរដ្ឋសភា**

**៣.២.២- ទម្រង់នៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់**

ក- ក្របសន្លឹកទំព័រដំបូង

ក.១- ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ដែលត្រូវដាក់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យជាចុងក្រោយ និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រសួង ស្ថាប័នសាមីត្រូវប្រើក្រដាសក្បាលលិខិតរបស់ក្រសួង ស្ថាប័ន ហើយនៅចំកណ្តាលសន្លឹកទំព័រនេះ ត្រូវដាក់ពាក្យ **សេចក្តីព្រាង** ក្រោមពាក្យសេចក្តីព្រាង ចំកណ្តាលដាក់ពាក្យ **ច្បាប់** ក្រោមពាក្យច្បាប់ ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យស្តីពី ដាក់ **វិសោធនកម្មមាត្រា...នៃច្បាប់ស្តីពី** ក្រោមពាក្យវិសោធនកម្មមាត្រា...នៃច្បាប់ស្តីពី ដាក់ចំណងជើងនៃច្បាប់ដែលត្រូវធ្វើវិសោធនកម្ម ព្រមទាំងបញ្ជាក់ពីព្រះរាជក្រមដែលបានប្រកាសឱ្យប្រើផង។ នៅប៉ែកខាងក្រោមនៃទំព័រ ត្រូវដាក់កាលបរិច្ឆេទក្រោយបង្អស់ដែលក្រសួង ស្ថាប័នបានរៀបចំ។

សូមមើលគំរូទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ដែលត្រូវដាក់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យជាចុងក្រោយ និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទំព័រទី១៤។

ក.២- ចំពោះក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ក្រោយឆ្លងអង្គប្រជុំតាមនីតិវិធីរួចហើយ ដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ ក្រសួង ស្ថាប័នសាមី ត្រូវប្រើក្រដាសក្បាលលិខិតរបស់រាជរដ្ឋាភិបាល។ នៅប៉ែកខាងក្រោមនៃទំព័រ ត្រូវដាក់ថា" **បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី... ខែ... ឆ្នាំ...**"។

សូមមើលគំរូទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ក្រោយឆ្លងអង្គប្រជុំតាមនីតិវិធី នៅទំព័រទី១៥។

ខ- សន្លឹកទំព័របន្តបន្ទាប់

ជាទូទៅសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ អាចមានរូបភាព២៖

ខ.១- វិសោធនកម្មច្បាប់ដែលត្រូវប្រកាសជាការប្រញាប់ ក្រសួង ស្ថាប័នសាមី ត្រូវរៀបចំចំណងជើង ដោយដាក់ថា " **សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា...នៃច្បាប់ស្តីពី** (ចំណងជើងនៃច្បាប់)" ហើយនៅក្រោមចំណងជើងច្បាប់ រំលង១បន្ទាត់ ត្រូវសរសេរ **មាត្រាមួយ** ក្នុងនោះ ត្រូវចែងមាត្រាថ្មីដែលកែប្រែខ្លឹមសារមាត្រាចាស់ ដោយដាក់ស្មើនឹងមាត្រាមួយដែរ។ សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មនេះមានតែ២មាត្រាប៉ុណ្ណោះ។

សូមមើលគំរូទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ដែលត្រូវប្រកាសជាការប្រញាប់ នៅទំព័រទី១៦។

ខ.២- ចំពោះវិសោធនកម្មច្បាប់ដែលមិនត្រូវប្រកាសជាការប្រញាប់ មានតែមួយមាត្រាដែលដាក់ថា " **មាត្រាតែមួយ ._** (ចែងអំពីមាត្រាដែលត្រូវធ្វើវិសោធនកម្ម)"។

ក្នុងករណីមានការកែប្រែខ្លឹមសារផង និងមានការប្តូរលេខរៀងរបស់មាត្រាផង ត្រូវរៀបចំ៖

- មាត្រាថ្មីដែលមានការកែប្រែឬការបញ្ចូលបន្ថែមខ្លឹមសារ ត្រូវដាក់ថា" មាត្រា...(លេខរបស់មាត្រា) ._ថ្មី"
- មាត្រាថ្មីដែលបានយកមាត្រាចាស់មកប្តូរលេខរៀងនិងមានការកែប្រែឬការបញ្ចូលបន្ថែមខ្លឹមសារ ត្រូវដាក់ថា " មាត្រា...(លេខរបស់មាត្រា) ._ ថ្មី (មាត្រា...(លេខរបស់មាត្រា) ចាស់កែប្រែ)"

- មាត្រាថ្មីដែលគ្រាន់តែយកមាត្រាចាស់មកប្តូរលេខរៀង ត្រូវដាក់ថា " មាត្រា...(លេខរបស់មាត្រា) .-- ថ្មី (មាត្រា...(លេខរបស់មាត្រា)ចាស់ ) "

សូមមើលគំរូទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ដែលមិនត្រូវប្រកាសជាការប្រញាប់ នៅទំព័រទី១៧។

ខ.៣- ចំពោះវិសោធនកម្មមាត្រាណាមួយចំនួនពីរលើក ត្រូវដាក់ថា " មាត្រា...(លេខរបស់មាត្រា) .-- ថ្មី(ពីរ) "។

គំរូទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ដែលត្រូវដាក់ឆ្លង
អង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យជាចុងក្រោយ
និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

(សញ្ញាក្រសួង ស្ថាប័ន)
**ក្រសួង**... (ឈ្មោះក្រសួង ស្ថាប័ន)

**សេចក្តីព្រាង**
**ច្បាប់**
**ស្តីពី**
**វិសោធនកម្មមាត្រា... ... ...នៃច្បាប់ស្តីពី**
(ចំណងជើងនៃច្បាប់ដែលត្រូវធ្វើវិសោធនកម្ម)
ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ...

**ថ្ងៃ... ខែ... ឆ្នាំ...**
(កាលបរិច្ឆេទក្រោយបង្អស់នៃអត្ថបទដែលក្រសួង ស្ថាប័នសាមីបានរៀបចំ)

គំរូទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ក្រោយឆ្លង
អង្គប្រជុំតាមនីតិវិធី

(សញ្ញាជាតិដូចក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានបោះពុម្ពលើកទី១)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**សេចក្តីព្រាង**

**ច្បាប់**

**ស្តីពី**

**វិសោធនកម្មមាត្រា... ... ...នៃច្បាប់ស្តីពី**

(ចំណងជើងនៃច្បាប់ដែលត្រូវធ្វើវិសោធនកម្ម)

ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ...

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី... ខែ... ឆ្នាំ...**

## គំរូទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ដែលត្រូវ ប្រកាសជាការប្រញាប់

**មាត្រាមួយ .-**

មាត្រា...(លេខមាត្រាដែលត្រូវធ្វើវិសោធនកម្ម)នៃច្បាប់ស្តីពី...(ចំណងជើងនៃច្បាប់)ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/.../... ចុះថ្ងៃទី... ខែ... ឆ្នាំ... ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

**មាត្រា**...(លេខមាត្រាដែលត្រូវធ្វើវិសោធនកម្ម) **.- ថ្មី**

..........................................................................................................................................................................................................................................................................................។

..........................................................................................................................................................................................................................................................................................។

**មាត្រាពីរ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំរដ្ឋសភា
លើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី...។
រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...
**ប្រធានរដ្ឋសភា**

គំរូទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់
ដែលមិនត្រូវប្រកាសជាការប្រញាប់

**មាត្រាតែមួយ .–**

មាត្រា...(លេខមាត្រាដែលត្រូវធ្វើវិសោធនកម្ម)នៃច្បាប់ស្តីពី... (ចំណងជើងនៃច្បាប់) ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/... /... ចុះថ្ងៃទី... ខែ... ឆ្នាំ... ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

**មាត្រា**...(លេខមាត្រាដែលត្រូវធ្វើវិសោធនកម្ម) **.– ថ្មី**

.............................................................................................................................................
.............................................................................................................................................។
.............................................................................................................................................
.............................................................................................................................................។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំរដ្ឋសភា
លើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី...។
រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...
**ប្រធានរដ្ឋសភា**

### ៣.២.៣- ទម្រង់នៃអនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់

ក្នុងករណីមានសំណើពីរដ្ឋសភាឬព្រឹទ្ធសភាសុំឱ្យរាជរដ្ឋាភិបាលផ្តល់អនុសាសន៍លើសេចក្តីស្នើច្បាប់ ការផ្តល់អនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់ត្រូវធ្វើតាមចំណុចនីមួយៗលើចំណងជើងច្បាប់ ចំណងជើងជំពូក ចំណងជើងផ្នែក ចំណងជើងអនុផ្នែកឬកថាភាគ និងលើខ្លឹមសារតាមមាត្រា ដោយត្រូវចម្លងខ្លឹមសារដើម ហើយនៅខាងក្រោមដាក់អនុសាសន៍របស់រាជរដ្ឋាភិបាល។

ការផ្តល់អនុសាសន៍ត្រូវអនុវត្តតាមលំដាប់ដូចតទៅ៖

- ការផ្តល់អនុសាសន៍របស់ក្រសួង ស្ថាប័នជំនាញ
- ការពិនិត្យរបស់អង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យជាចុងក្រោយ និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើការផ្តល់អនុសាសន៍របស់ក្រសួង ស្ថាប័នជំនាញ
- ការផ្តល់អនុសាសន៍ក្នុងនាមរាជរដ្ឋាភិបាល បន្ទាប់ពីការពិនិត្យរបស់អង្គប្រជុំតាមនីតិវិធី។

#### ក- ទម្រង់នៃអនុសាសន៍របស់ក្រសួង ស្ថាប័នជំនាញទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់

ក្រសួង ស្ថាប័នជំនាញទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់ ក្រោយពីបានពិនិត្យនិងសិក្សាលើសេចក្តីស្នើច្បាប់រួចហើយ ត្រូវបញ្ជូនមតិយោបល់របស់ខ្លួនជូនប្រមុខរាជរដ្ឋាភិបាល ដោយត្រូវមានលិខិតបញ្ជូនអត្ថបទនៃការផ្តល់អនុសាសន៍លើសេចក្តីស្នើច្បាប់ ដែលចុះហត្ថលេខាដោយប្រធានស្ថាប័នទៅទីស្តីការគណៈរដ្ឋមន្ត្រី។ អត្ថបទផ្តល់អនុសាសន៍របស់ក្រសួង ស្ថាប័នជំនាញ ត្រូវសរសេរជាអក្សរទ្រេត។

សូមមើលគំរូទម្រង់ក្របសន្លឹកទំព័រដំបូងនៃអនុសាសន៍របស់ក្រសួង ស្ថាប័នលើសេចក្តីស្នើច្បាប់នៅទំព័រទី១៩ និងសន្លឹកទំព័របន្តបន្ទាប់នៃអនុសាសន៍របស់ក្រសួង ស្ថាប័នលើសេចក្តីស្នើច្បាប់នៅទំព័រទី២០។

#### ខ- ទម្រង់នៃការផ្តល់អនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់ ក្រោយការរួមយោបល់របស់អង្គប្រជុំតាមនីតិវិធីដែលទីស្តីការគណៈរដ្ឋមន្ត្រីត្រូវរៀបចំបញ្ជូនទៅស្ថាប័ននីតិប្បញ្ញត្តិ

ក្រោយពីបានទទួលសេចក្តីព្រាងអនុសាសន៍របស់ក្រសួង ស្ថាប័នជំនាញ ដែលផ្ញើទៅទីស្តីការគណៈរដ្ឋមន្ត្រី អគ្គលេខាធិការរាជរដ្ឋាភិបាលត្រូវរៀបចំដាក់សេចក្តីព្រាងអនុសាសន៍នេះជូនអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង និងអង្គប្រជុំត្រួតពិនិត្យជាចុងក្រោយពិនិត្យនិងផ្តល់យោបល់ និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីពិនិត្យសម្រេច។ ឯទម្រង់នៃសេចក្តីព្រាងអត្ថបទស្តីពីការផ្តល់អនុសាសន៍ដើម្បីដាក់ជូនប្រមុខរាជរដ្ឋាភិបាលសម្រេចនិងផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ ក៏ត្រូវបានកែសម្រួលឡើងវិញដែរ។ អត្ថបទផ្តល់អនុសាសន៍របស់រាជរដ្ឋាភិបាលត្រូវសរសេរជាអក្សរទ្រេត។

សូមមើលគំរូទម្រង់ក្របសន្លឹកទំព័រដំបូងនៃអនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់ នៅទំព័រទី២១និងសន្លឹកទំព័របន្តបន្ទាប់នៃអនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់ នៅទំព័រទី២២។

គំរូទម្រង់ក្របសន្លឹកទំព័រដំបូងនៃអនុសាសន៍របស់ក្រសួង ស្ថាប័នលើសេចក្តីស្នើច្បាប់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

(សញ្ញាក្រសួង ស្ថាប័ន)

**ក្រសួង**... (ឈ្មោះក្រសួង ស្ថាប័ន)

**អនុសាសន៍លើសេចក្តីស្នើ**
**ច្បាប់**
**ស្តីពី**
( ចំណងជើងនៃសេចក្តីស្នើច្បាប់ជាអក្សរមូល)
**ដែលរៀបចំដោយគណៈកម្មការទី...នៃរដ្ឋសភាឬព្រឹទ្ធសភា**

***អនុសាសន៍លើចំណងជើងនៃសេចក្តីស្នើច្បាប់***
( ចំណងជើងដែលក្រសួង ស្ថាប័នផ្តល់អនុសាសន៍កែសម្រួលជាអក្សរមូលទ្រេត)

គំរូទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃអនុសាសន៍របស់ក្រសួង ស្ថាប័នលើសេចក្តីស្នើច្បាប់

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១ .-**

..............................................ខ្លឹមសារដើមរបស់សេចក្តីស្នើច្បាប់.......................................។

*អនុសាសន៍របស់...(ឈ្មោះក្រសួង ស្ថាប័ន)*

ខ្លឹមសារទាំងស្រុងដែលក្រសួង ស្ថាប័នផ្តល់អនុសាសន៍លើចំណងជើងជំពូក ផ្នែក អនុផ្នែកឬកថាភាគ និងតាមមាត្រានីមួយៗ ត្រូវសរសេរជាអក្សរទ្រេត។

**ជំពូកទី២** និង **ជំពូក**បន្តបន្ទាប់

(ចំណងជើង)

**មាត្រា... .-**

.......................................ខ្លឹមសារដើមរបស់សេចក្តីស្នើច្បាប់...........................................។

*អនុសាសន៍របស់...(ឈ្មោះក្រសួង ស្ថាប័ន)*

ខ្លឹមសារទាំងស្រុងដែលក្រសួង ស្ថាប័នផ្តល់អនុសាសន៍លើចំណងជើងជំពូក ផ្នែក អនុផ្នែកឬកថាភាគ និងតាមមាត្រានីមួយៗ ត្រូវសរសេរជាអក្សរទ្រេត។

**ជំពូកទី...**

**អន្តរប្បញ្ញត្តិ** (ប្រសិនបើមាន)

**មាត្រា... .-**

........................................ខ្លឹមសារដើមរបស់សេចក្តីស្នើច្បាប់..............................................។

*អនុសាសន៍របស់...(ឈ្មោះក្រសួង ស្ថាប័ន)*

ខ្លឹមសារទាំងស្រុងដែលក្រសួង ស្ថាប័នផ្តល់អនុសាសន៍លើចំណងជើងជំពូក ផ្នែក អនុផ្នែកឬកថាភាគ និងតាមមាត្រានីមួយៗ ត្រូវសរសេរជាអក្សរទ្រេត។

**ជំពូកទី...**

**អវសានប្បញ្ញត្តិ**

**មាត្រា... .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា... .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។ (ក្នុងករណីដែលច្បាប់ត្រូវអនុវត្តជាប្រញាប់)

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំរដ្ឋសភា
លើកទី...(ឬជាវិសាមញ្ញ) នីតិកាលទី...។
រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**ប្រធានរដ្ឋសភា**

គំរូទម្រង់ក្របសន្លឹកទំព័រដំបូងនៃអនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់

(សញ្ញាជាតិដូចក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានបោះពុម្ពលើកទី១ )

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**អនុសាសន៍លើសេចក្តីស្នើ**

**ច្បាប់**

**ស្តីពី**

(ចំណងជើងនៃសេចក្តីស្នើច្បាប់ជាអក្សរមូល)

**ដែលរៀបចំដោយគណៈកម្មការទី...នៃរដ្ឋសភាឬព្រឹទ្ធសភា**

***អនុសាសន៍របស់រាជរដ្ឋាភិបាលលើចំណងជើងនៃសេចក្តីស្នើច្បាប់***

(ចំណងជើងដែលប្រមុខរាជរដ្ឋាភិបាលឯកភាពផ្តល់អនុសាសន៍កែសម្រួលជាអក្សរមូលទ្រេត)

គំរូទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃអនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

.............................................ខ្លឹមសារដើមរបស់សេចក្តីស្នើច្បាប់........................................។

*អនុសាសន៍របស់រាជរដ្ឋាភិបាល*

ខ្លឹមសារទាំងស្រុងដែលប្រមុខរាជរដ្ឋាភិបាលឯកភាព តាមការផ្តល់អនុសាសន៍របស់អង្គប្រជុំតាមនីតិវិធីលើចំណងជើងជំពូក ផ្នែក អនុផ្នែកឬកថាភាគ និងតាមមាត្រានីមួយៗ ត្រូវសរសេរជាអក្សរទ្រេត។

**ជំពូកទី២** និង **ជំពូក**បន្តបន្ទាប់

(ចំណងជើង)

**មាត្រា... .-**

.............................................ខ្លឹមសារដើមរបស់សេចក្តីស្នើច្បាប់........................................។

*អនុសាសន៍របស់រាជរដ្ឋាភិបាល*

ខ្លឹមសារទាំងស្រុងដែលប្រមុខរាជរដ្ឋាភិបាលឯកភាព តាមការផ្តល់អនុសាសន៍របស់អង្គប្រជុំតាមនីតិវិធីលើចំណងជើងជំពូក ផ្នែក អនុផ្នែកឬកថាភាគ និងតាមមាត្រានីមួយៗ ត្រូវសរសេរជាអក្សរទ្រេត។

**ជំពូកទី...**

**អន្តរប្បញ្ញត្តិ** (ប្រសិនបើមាន)

**មាត្រា... .-**

.............................................ខ្លឹមសារដើមរបស់សេចក្តីស្នើច្បាប់........................................។

*អនុសាសន៍របស់រាជរដ្ឋាភិបាល*

ខ្លឹមសារទាំងស្រុងដែលប្រមុខរាជរដ្ឋាភិបាលឯកភាព តាមការផ្តល់អនុសាសន៍របស់អង្គប្រជុំតាមនីតិវិធីលើចំណងជើងជំពូក ផ្នែក អនុផ្នែកឬកថាភាគ និងតាមមាត្រានីមួយៗ ត្រូវសរសេរជាអក្សរទ្រេត។

**ជំពូកទី...**

## អវសានប្បញ្ញត្តិ

**មាត្រា... .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា... .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។ (ក្នុងករណីដែលច្បាប់ត្រូវអនុវត្តជាប្រញាប់)

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំរដ្ឋសភា
លើកទី...(ឬជាវិសាមញ្ញ) នីតិកាលទី...។
រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...
**ប្រធានរដ្ឋសភា**

**៣.២.៤- ទម្រង់នៃព្រះរាជក្រម**

ព្រះរាជក្រមជាលិខិតបទដ្ឋានគតិយុត្តដែលឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ ដើម្បីប្រកាសឱ្យប្រើច្បាប់។

ច្បាប់ទាំងឡាយដែលត្រូវបានរដ្ឋសភាអនុម័តនិងព្រឹទ្ធសភាពិនិត្យចប់សព្វគ្រប់រួចហើយ ត្រូវបានរដ្ឋសភាបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីវិញ ដើម្បីចាត់ចែងរៀបចំបែបបទទូលថ្វាយព្រះមហាក្សត្រស្នើសុំឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ស្របតាមមាត្រា២៨ថ្មីនៃរដ្ឋធម្មនុញ្ញ។

ទម្រង់នៃព្រះរាជក្រមចែកចេញជា៤ផ្នែក មានក្បាលលិខិត មូលបទ ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- **ក្បាលលិខិត** នៅផ្នែកនេះ ត្រូវទុកកន្លែងសម្រាប់បញ្ចូលព្រះរាជសង្ហាររបស់ព្រះមហាក្សត្រ ដែលមិនដូចសញ្ញាជាតិក្នុងរដ្ឋធម្មនុញ្ញទេ។ នៅចំកណ្តាលទំព័រក្រោមព្រះរាជសង្ហារ រំលង១បន្ទាត់ ត្រូវដាក់ពាក្យ **ព្រះរាជក្រម** ក្រោមពាក្យព្រះរាជក្រម ចំកណ្តាល ដាក់ពាក្យ **យើង** ក្រោមពាក្យយើង សរសេរព្រះគោរមងាររបស់ព្រះមហាក្សត្រ។

ខ- **មូលបទ** ត្រូវយោងជាចាំបាច់នូវរដ្ឋធម្មនុញ្ញ ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី និងព្រះរាជក្រមទាំងឡាយដែលពាក់ព័ន្ធ ដោយដាក់លេខនិងដាក់សញ្ញាគំនូសទ្រេត(/)ឱ្យបានត្រឹមត្រូវ និងចុងក្រោយនៃមូលបទមានដាក់សេចក្តីថា៖

- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

បន្ទាប់ពីនេះ នៅខាងក្រោម ចំកណ្តាលទំព័រ ត្រូវប្រើពាក្យនិងឃ្លារូបមន្តផ្តើម ដូចខាងក្រោម៖

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពី(ចំណងជើងនៃច្បាប់) ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំរដ្ឋសភា លើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី... ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំពេញអង្គលើកទី...(ឬជាវិសាមញ្ញ) នីតិកាលទី... (ក្នុងករណីដែលច្បាប់ណាត្រូវបានឆ្លងការពិនិត្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវចែងបន្ថែមថា " ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... " ) ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

គ- **ខ្លឹមសារនៃអត្ថបទ** ត្រូវបញ្ចូលអត្ថបទច្បាប់ទាំងស្រុងដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យ។

ឃ- **រូបមន្តបញ្ចប់** ព្រះរាជក្រមត្រូវបានឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រឬចុះហត្ថលេខាដោយប្រមុខរដ្ឋស្តីទី នៅពេលដែលព្រះមហាក្សត្រទ្រង់អវត្តមាន។ នាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីដែលជាអ្នកទទួលបន្ទុករៀបចំសេចក្តីព្រាងច្បាប់ ត្រូវចុះហត្ថលេខាអមផងដែរ។

ការដាក់ថ្វាយព្រះមហាក្សត្រឡាយព្រះហស្តលេខានិងការដាក់ជូននាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីចុះហត្ថលេខា ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម៖

- នៅមួយភាគបីខាងស្តាំនៃទំព័រចុងក្រោយរបស់ច្បាប់ ត្រូវដាក់កាលបរិច្ឆេទ៖
  - ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី... ខែ... ឆ្នាំ...(ក្នុងករណីដែលព្រះមហាក្សត្រគង់នៅព្រះបរមរាជវាំង)ឬ
  - ធ្វើនៅថ្ងៃទី... ខែ... ឆ្នាំ... (ក្នុងករណីដែលព្រះមហាក្សត្រមិនគង់នៅព្រះបរមរាជវាំង)។

- នៅក្រោមកាលបរិច្ឆេទ ត្រូវទុកចន្លោះប្រហែល៤បន្ទាត់ សម្រាប់ព្រះហស្តលេខារបស់ព្រះមហាក្សត្រ នៅខាងស្តាំ និងសម្រាប់ប្រថាប់ព្រះរាជលញ្ឆកររបស់ព្រះមហាក្សត្រនៅខាងឆ្វេង។

ក្នុងករណីដែលត្រូវជូនប្រមុខរដ្ឋស្តីទី ត្រូវបន្ថែមកន្សោមពាក្យ **ឆ្លងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់** នៅលើពាក្យ **ប្រមុខរដ្ឋស្តីទី** ហើយទុកចន្លោះសម្រាប់ជូនប្រមុខរដ្ឋស្តីទីចុះហត្ថលេខា។

- នៅក្រោមព្រះហស្តលេខារបស់ព្រះមហាក្សត្រឬហត្ថលេខារបស់ប្រមុខរដ្ឋស្តីទី ត្រូវដាក់ព្រះបរមនាម ឬគោរមងារនិងឈ្មោះរបស់ប្រមុខរដ្ឋស្តីទី។

- នៅប៉ែកខាងឆ្វេងនៃទំព័រ ក្រោមព្រះបរមនាមរបស់ព្រះមហាក្សត្រឬគោរមងារនិងឈ្មោះរបស់ប្រមុខរដ្ឋស្តីទី ត្រូវមានហត្ថលេខាអមរបស់នាយករដ្ឋមន្ត្រី ដោយដាក់ថា "បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា "។

- ក្រោមហត្ថលេខា គោរមងារ និងឈ្មោះរបស់នាយករដ្ឋមន្ត្រី ខាងស្តាំទំព័រត្រូវមានហត្ថលេខាអមរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី ដោយដាក់ថា " បានយកសេចក្តីគោរពជម្រាបជូន (គោរមងារ) នាយករដ្ឋមន្ត្រី " ។

ក្រសួងព្រះបរមរាជវាំងចុះលេខព្រះរាជក្រម ដោយដាក់សញ្ញាសម្គាល់អក្សរកាត់តាមរូបមន្ត **នស/រកម**/ ...(លេខខែឆ្នាំ)/...(លេខព្រះរាជក្រម) ចុះកាលបរិច្ឆេទ ប្រថាប់ព្រះរាជលញ្ឆករ និងចុះលេខព្រះរាជលញ្ឆករ ព្រមទាំងបោះត្រារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំងលើគ្រប់សន្លឹកទំព័រនៃព្រះរាជក្រម លើកលែងតែទំព័រចុងក្រោយដែលមានព្រះរាជលញ្ឆកររួចហើយ។

សូមមើលគំរូទម្រង់នៃព្រះរាជក្រម នៅទំព័រទី២៦និង២៧។

**ង- ព្រះរាជក្រមជាសំណៅនិងសំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**

ចំពោះព្រះរាជក្រមដែលព្រះមហាក្សត្រឡាយព្រះហស្តលេខារួច អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាលមានភារកិច្ចរៀបចំសំណៅដែលមានតម្លៃជាការចែកផ្សាយ សម្រាប់ចែកជូនក្រសួង ស្ថាប័ន រាជធានី ខេត្តដើម្បីចាត់ចែងអនុវត្ត។ ក្នុងករណីនេះ ត្រូវដាក់នៅប៉ែកខាងស្តាំនៃទំព័រ ក្រោមព្រះបរមនាមរបស់ព្រះមហាក្សត្រឬគោរមងារនិងឈ្មោះរបស់ប្រមុខរដ្ឋស្តីទី នូវរូបមន្តខាងក្រោមនេះ៖

លេខ : ...

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

(ហត្ថលេខានិងត្រា)

(**ឈ្មោះ**)

ក្រសួង ស្ថាប័ន រាជធានី ខេត្តមានភារកិច្ចបន្តចម្លងសំណៅដែលមានតម្លៃជាការចែកផ្សាយ ជូនអង្គភាពក្រោមឱវាទដើម្បីចាត់ចែងអនុវត្ត។ ក្នុងករណីនេះ ត្រូវអនុវត្តដូចតទៅ៖

- នៅប៉ែកខាងស្តាំនៃទំព័រ ក្រោមរូបមន្ត "សំណៅដែលមានតម្លៃជាការចែកផ្សាយ" ត្រូវដាក់រូបមន្តខាងក្រោមនេះ៖

លេខ : ...

**បានចម្លងត្រឹមត្រូវតាមសំណៅ**

**ដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**ត.ម. រដ្ឋមន្ត្រី**

**អគ្គលេខាធិការឬអគ្គនាយក...**

(ហត្ថលេខានិងត្រា)

(**ឈ្មោះ**)

- នៅប៉ែកខាងឆ្វេងនៃទំព័រ ក្រោមរូបមន្តបានចម្លងត្រឹមត្រូវតាមសំណៅដែលមានតម្លៃជាការចែកផ្សាយ ត្រូវដាក់ **កន្លែងទទួល** ដែលរួមមានអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន នាយកដ្ឋាន មន្ទីរជំនាញរាជធានី ខេត្ត និងឯកសារ កាលប្បវត្តិ។

សូមមើលគំរូទម្រង់នៃព្រះរាជក្រមជាសំណៅនិងសំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ នៅទំព័រទី២៨ដល់៣០។

គំរូទម្រង់នៃព្រះរាជក្រម

(រូបសញ្ញាព្រះរាជសង្ហាររបស់ព្រះមហាក្សត្រ)

**ព្រះរាជក្រម**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ស្តីពីការកែសម្រួលសមាសភាពសមាជិករាជរដ្ឋាភិបាល(ដែលទាក់ទងនឹងរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីដែលរៀបចំសេចក្តីព្រាងច្បាប់)
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត... (ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី... (ដែលពាក់ព័ន្ធ)
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពី(ចំណងជើងនៃច្បាប់) ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំរដ្ឋសភា លើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី... ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំពេញអង្គលើកទី...(ឬជាវិសាមញ្ញ) នីតិកាលទី... (ក្នុងករណីដែលច្បាប់ណាត្រូវបានឆ្លងការពិនិត្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវថែងបន្ថែមថា "ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ") ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

(ត្រូវបញ្ចូលអត្ថបទច្បាប់ទាំងស្រុងដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យ)

# ច្បាប់
## ស្តីពី
(ចំណងជើងជាអក្សរមូល)

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

.................................................................................................................................។

## ជំពូកទី២ និង ជំពូកបន្តបន្ទាប់
(ចំណងជើង)

**មាត្រា... .-**

.................................................................................................................................។

## ជំពូកទី...
## ទោសប្បញ្ញត្តិ

**មាត្រា... .-**

.................................................................................................................................។

## ជំពូកទី...
## អន្តរប្បញ្ញត្តិ (ប្រសិនបើមាន)

**មាត្រា... .-**

.................................................................................................................................។

## ជំពូកទី...
## អវសានប្បញ្ញត្តិ

**មាត្រា... .-**

.................................................................................................................................។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី... ខែ... ឆ្នាំ... ឬ

ធ្វើនៅ ថ្ងៃទី... ខែ... ឆ្នាំ...(ក្នុងករណីដែលព្រះមហាក្សត្រមិនគង់នៅព្រះបរមរាជវាំង)

(ព្រះហស្តលេខានិងព្រះរាជលញ្ឆករ)

(**ព្រះបរមនាម**) ឬ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

(ហត្ថលេខានិងព្រះរាជលញ្ឆករ)

(**គោរមងារនិងឈ្មោះ**)

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

(ហត្ថលេខា)

(**គោរមងារនិងឈ្មោះ**)

បានយកសេចក្តីគោរពជម្រាបជូន(គោរមងារ)នាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួង...** ឬ **រដ្ឋមន្ត្រីក្រសួង...** ឬប្រធានស្ថាប័នសាមី

(ហត្ថលេខា)

(**ឈ្មោះ**)

២៧/១៣០

គំរូទម្រង់នៃព្រះរាជក្រមជាសំណៅនិងសំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ

△

(រូបសញ្ញាព្រះរាជសង្ហាររបស់ព្រះមហាក្សត្រ)

**ព្រះរាជក្រម**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ស្តីពីការកែសម្រួលសមាសភាពសមាជិករាជរដ្ឋាភិបាល(ដែលទាក់ទងនឹងរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីដែលរៀបចំសេចក្តីព្រាងច្បាប់)
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត...(ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី...(ដែលពាក់ព័ន្ធ)
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពី(ចំណងជើងនៃច្បាប់) ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំរដ្ឋសភា លើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី... ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំពេញអង្គលើកទី...(ឬជាវិសាមញ្ញ) នីតិកាលទី... (ក្នុងករណីដែលច្បាប់ណាត្រូវបានឆ្លងការពិនិត្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវថែងបន្ថែមថា "ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ") ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

(ត្រូវបញ្ចូលអត្ថបទច្បាប់ទាំងស្រុងដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យ)

**ច្បាប់**

**ស្តីពី**

(ចំណងជើងជាអក្សរមូល)

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១ .-**

.................................................................................................................................។

**ជំពូកទី២** និង **ជំពូកបន្តបន្ទាប់**

(ចំណងជើង)

**មាត្រា... .-**

.................................................................................................................................។

**ជំពូកទី...**

**ទោសប្បញ្ញត្តិ**

**មាត្រា... .-**

.................................................................................................................................។

**ជំពូកទី...**

**អន្តរប្បញ្ញត្តិ** (ប្រសិនបើមាន)

**មាត្រា... .-**

.................................................................................................................................។

**ជំពូកទី...**

**អវសានប្បញ្ញត្តិ**

**មាត្រា... .-**

.................................................................................................................................។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី... ខែ... ឆ្នាំ... ឬ

ធ្វើនៅ ថ្ងៃទី... ខែ... ឆ្នាំ...(ក្នុងករណីដែលព្រះមហាក្សត្រមិនគង់នៅព្រះបរមរាជវាំង)

(ព្រះហស្តលេខានិងព្រះរាជលញ្ឆករ)

(**ព្រះបរមនាម**) ឬ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាប់**

**ប្រមុខរដ្ឋស្តីទី**

(ហត្ថលេខានិងព្រះរាជលញ្ឆករ)

(**គោរមងារនិងឈ្មោះ**)

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

(ហត្ថលេខា)

(**គោរមងារនិងឈ្មោះ**)

បានយកសេចក្តីគោរពជម្រាបជូន(គោរមងារ)នាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**...ឬ **ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួង**...ឬ **រដ្ឋមន្ត្រីក្រសួង**...(ឬប្រធានស្ថាប័នសាមី)

(ហត្ថលេខា)

(**ឈ្មោះ**)

**២៥/១៣០**

លេខ : ...

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

(ហត្ថលេខានិងត្រា)

(**ឈ្មោះ**)

លេខ : ...

**បានចម្លងត្រឹមត្រូវតាមសំណៅ**
**ដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**ត.ប. រដ្ឋមន្ត្រី**

**អគ្គលេខាធិការឬអគ្គនាយក...**

(ហត្ថលេខានិងត្រា)

(**ឈ្មោះ**)

**កន្លែងទទួល** :

- អគ្គលេខាធិការដ្ឋាន
- អគ្គនាយកដ្ឋាន
- អគ្គាធិការដ្ឋាន
- នាយកដ្ឋាន
- មន្ទីរជំនាញរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

### ៣.២.៥- ទម្រង់នៃព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យជាសេចក្តីត្រាស់បង្គាប់ចេញដោយព្រះមហាក្សត្រ។ ព្រះរាជក្រឹត្យមានពីរប្រភេទគឺ ព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅនិងព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តភូត។

ព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ជាសេចក្តីត្រាស់បង្គាប់ណែនាំការអនុវត្តច្បាប់ឬជាសេចក្តីត្រាស់បង្គាប់ស្តីពីខ្លឹមសារពាក់ព័ន្ធនឹងបញ្ហាទាំងឡាយដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល មានលក្ខណៈជាបទបញ្ញា មានអានុភាពទូទៅ និងមិនសំដៅចំឈ្មោះបុគ្គលណាម្នាក់ឡើយ។ ព្រះរាជក្រឹត្យប្រភេទនេះមានដូចជា ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ព្រះរាជក្រឹត្យស្តីពីឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋជាដើម។

ព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តភូត ជាសេចក្តីត្រាស់បង្គាប់ដែលសំដៅចំឈ្មោះបុគ្គលតែម្តង។ អនុលោមតាមមាត្រា១៩ថ្មី មាត្រា២១ មាត្រា២៧ និងមាត្រា២៩នៃរដ្ឋធម្មនុញ្ញ និងយោងតាមមាត្រា១៤នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តភូតមានដូចជាព្រះរាជក្រឹត្យស្តីពីការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ការតែងតាំង ការប្រគល់ភារកិច្ច ការផ្ទេរភារកិច្ច ការដំឡើងឋានន្តរសក្តិ ការបន្ថយឋានន្តរសក្តិ ការដំឡើងថ្នាក់ ការបន្ថយថ្នាក់ ការដកពីមុខតំណែង ការអនុញ្ញាតឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ការអនុញ្ញាតឬការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ការអនុញ្ញាតឱ្យចូលបម្រើការងារឡើងវិញ ការបញ្ចប់ភារកិច្ច ការលុបឈ្មោះឬការបញ្ឈប់ពីការងារ ការដាក់ឱ្យចូលនិវត្តន៍ ការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌប្រភេទ ក ការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ការបន្ធូរបន្ថយនិងការលើកលែងទោស ការតែងតាំងចៅក្រម ការតែងតាំងព្រះគោរមងារឬព្រះឋានានុក្រមមន្ត្រីសង្ឃ ការប្រទានគ្រឿងឥស្សរិយយសចំពោះបុគ្គលឬជាក្រុម ការតែងតាំង(ឬប្រទានងារ)អ្នកឧកញ៉ាឬឧកញ៉ាជាដើម។

ទម្រង់នៃព្រះរាជក្រឹត្យចែកចេញជា៤ផ្នែក មានក្បាលលិខិត មូលបទ ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- ក្បាលលិខិត នៅផ្នែកនេះមានព្រះរាជសង្ហាររបស់ព្រះមហាក្សត្រ នៅចំកណ្តាលទំព័រក្រោមព្រះរាជសង្ហាររបស់ព្រះមហាក្សត្ររំលង១បន្ទាត់ ត្រូវដាក់ពាក្យ **ព្រះរាជក្រឹត្យ** ក្រោមពាក្យព្រះរាជក្រឹត្យដាក់ពាក្យ **ស្តីពី** ក្រោមពាក្យស្តីពី ដាក់ចំណងជើងនៃព្រះរាជក្រឹត្យ។ នៅក្រោមចំកណ្តាលពាក្យព្រះរាជក្រឹត្យដាក់ពាក្យ **យើង** ហើយនៅពីក្រោមនេះ សរសេរព្រះគោរមងាររបស់ព្រះមហាក្សត្រ។

ខ- មូលបទ ត្រូវយោងជាចាំបាច់នូវរដ្ឋធម្មនុញ្ញ ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ព្រះរាជក្រម និងព្រះរាជក្រឹត្យទាំងឡាយដែលពាក់ព័ន្ធមានជាអាទិ៍ ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងស្ថាប័ន ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការនៃក្រសួង ស្ថាប័នសាមី(បើជាព្រះរាជក្រឹត្យតែងតាំង) និងចុងក្រោយនៃមូលបទមានដាក់សេចក្តីដូចខាងក្រោម៖

- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី... ខែ... ឆ្នាំ... (ចំពោះព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី) ឬ

- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា (ចំពោះព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ដែលមិនបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តភូត ដែលស្នើឡើងដោយរាជរដ្ឋាភិបាល)។

ដោយឡែកចំពោះការតែងតាំងរាជរដ្ឋាភិបាលថ្មី ត្រូវចែងបន្ថែមក្នុងមូលបទដូចខាងក្រោម៖

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នាថ្ងៃទី... ខែ... ឆ្នាំ...

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្ដីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី... នីតិកាលទី... នៃរដ្ឋសភា នាថ្ងៃទី... ខែ... ឆ្នាំ... ស្ដីពីការជ្រើសតាំងរចនាសម្ព័ន្ធនិងថ្នាក់ដឹកនាំនៃរដ្ឋសភា និងការសំដែងការទុកចិត្តទៅលើសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

បន្ទាប់ពីនេះ នៅខាងក្រោមចំកណ្ដាលទំព័រ ត្រូវសរសេរពាក្យ៖

**ត្រាស់បង្គាប់**

**គ- ខ្លឹមសារនៃអត្ថបទ**

គ.១- ព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ជាទូទៅ ត្រូវចែកជាជំពូក ដែលមានបទប្បញ្ញត្តិទូទៅ បទប្បញ្ញត្តិផ្សេងៗ និងអវសានប្បញ្ញត្តិ ហើយបទប្បញ្ញត្តិនៃជំពូកនីមួយៗ មានចែកជាផ្នែក អនុផ្នែក មាត្រា កថាខណ្ឌ វាក្យខណ្ឌ អាស្រ័យទៅតាមខ្លឹមសារនៃបទប្បញ្ញត្តិវែងឬខ្លី។

ការតែងសេចក្ដី ត្រូវអនុវត្តដូចក្នុងចំណុច ខ នៃការសរសេរសេចក្ដីព្រាងច្បាប់ដែរ។

សូមមើលគំរូទម្រង់នៃព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ជាទូទៅ ដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទំព័រទី៣៥និង៣៦ និងគំរូទម្រង់នៃព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ជាទូទៅ ដែលមិនបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី តែមានសំណើពីក្រសួង ស្ថាប័នសាមី នៅទំព័រទី៣៧និង៣៨។

គ.២- ចំពោះព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តភូត មិនត្រូវចែកជាជំពូកទេ គឺចែកត្រឹមតែជាមាត្រា។

ជាទូទៅ ព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តភូតមានតែ២ទៅ៤មាត្រាប៉ុណ្ណោះ។

ដោយឡែក ព្រះរាជក្រឹត្យស្ដីពីការប្រទានគ្រឿងឥស្សរិយយសចំពោះបុគ្គលឬជាក្រុម និងព្រះរាជក្រឹត្យស្ដីពីការតែងតាំង(ឬប្រទានងារ)ជាអ្នកឧកញ៉ាឬឧកញ៉ា ពុំមានចែងពីមូលបទនិងមាត្រាដូចព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ជាទូទៅនិងព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តភូតឯទៀតទេ។ ជាគោលការណ៍ ងារជាអ្នកឧកញ៉ាគឺប្រទានចំពោះតែរដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំងប៉ុណ្ណោះ ក្រៅពីនោះត្រូវទទួលបានងារជាឧកញ៉ាដោយមិនត្រូវសរសេរពាក្យ លោកអ្នកឬលោក ពីមុខពាក្យងារឡើយ។

គ.២.១- ខ្លឹមសារដែលត្រូវចែងក្នុងមាត្រា១ ត្រូវចែងដោយប្រែប្រួលទៅតាមកម្មវត្ថុនិងគោលបំណងជាក់ស្ដែងនីមួយៗ។

សូមមើលគំរូទម្រង់នៃព្រះរាជក្រឹត្យ៖

- ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលថ្មី នៅទំព័រទី៣៩ដល់៤១
- ស្ដីពីការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ការតែងតាំង ការដំឡើងឋានន្តរសក្តិឬថ្នាក់ ការដាក់ឱ្យចូលនិវត្តន៍មន្ត្រីរាជការ... នៅទំព័រទី៤២ដល់៤៨
- ស្ដីពីការផ្ដល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម នៅទំព័រទី៤៩និង៥០
- ស្ដីពីការបន្ធូរបន្ថយទោសនិងលើកលែងទោស នៅទំព័រទី៥១និង៥២
- ស្ដីពីការតែងតាំងចៅក្រម នៅទំព័រទី៥៣និង៥៤

- ស្តីពីការតែងតាំងព្រះគោរមងារឬព្រះឋានានុក្រមមន្ត្រីសង្ឃ នៅទំព័រទី៥៥និង៥៦
- ស្តីពីការប្រទានគ្រឿងឥស្សរិយយសចំពោះបុគ្គល នៅទំព័រទី៥៧
- ស្តីពីការប្រទានគ្រឿងឥស្សរិយយសជាក្រុម នៅទំព័រទី៥៨
- ស្តីពីការតែងតាំង (ឬប្រទានងារ) អ្នកឧកញ៉ាឬឧកញ៉ា នៅទំព័រទី៥៩។

គ.២.២- ខ្លឹមសារដែលត្រូវចែងក្នុងមាត្រាបន្ទាប់និងមាត្រាបញ្ចប់

មាត្រាដែលត្រូវចែងពីការនិរាករ ត្រូវចែងតែចំពោះករណីចាំបាច់ ដែលត្រូវនិរាករជាស្ថាពរនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលផ្ទុយនឹងព្រះរាជក្រឹត្យតែប៉ុណ្ណោះ។

ចំពោះមាត្រាបញ្ចប់ ត្រូវចែងពីបទប្បញ្ញត្តិស្តីពីការត្រាស់បង្គាប់ឱ្យនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អនុវត្តព្រះរាជក្រឹត្យចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ហើយមិនត្រូវចែងបន្ថែមមាត្រាមួយទៀតថា "ព្រះរាជក្រឹត្យនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ "ឡើយ។

មាត្រាដែលត្រូវចែងពីការនិរាករនិងមាត្រាបញ្ចប់ត្រូវចែងដូចមានខ្លឹមសារក្នុងគំរូទម្រង់នៃព្រះរាជក្រឹត្យ។

ឃ- រូបមន្តបញ្ចប់ ព្រះរាជក្រឹត្យត្រូវបានឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រឬចុះហត្ថលេខាដោយប្រមុខរដ្ឋស្តីទី។ ចំពោះព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ជាទូទៅ ដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី មានតែហត្ថលេខាអមរបស់នាយករដ្ឋមន្ត្រីប៉ុណ្ណោះ។ ចំពោះព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ជាទូទៅ ដែលមិនបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី តែមានសំណើពីក្រសួង ស្ថាប័នសាមី ត្រូវមានហត្ថលេខាអមរបស់រដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នសាមីដែលជាអ្នកស្នើឡើងថែមទៀត។ ប្រសិនបើជាព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តភូត មិនមានហត្ថលេខាអមរបស់នាយករដ្ឋមន្ត្រីទេ។

អគ្គលេខាធិការរាជរដ្ឋាភិបាល ឧទ្ទកាល័យនាយករដ្ឋមន្ត្រី ត្រូវពិនិត្យមើលរាល់សេចក្តីព្រាងព្រះរាជក្រឹត្យឱ្យបានត្រឹមត្រូវតាមទម្រង់ខាងលើ មុននឹងដាក់ជូននាយករដ្ឋមន្ត្រីចុះហត្ថលេខាលើលិខិតថ្វាយព្រះមហាក្សត្រដើម្បីសូមឡាយព្រះហស្តលេខា។

ក្រសួងព្រះបរមរាជវាំងចុះលេខព្រះរាជក្រឹត្យ ដោយដាក់សញ្ញាសម្គាល់អក្សរកាត់តាមរូបមន្ត **នស/រកត**/ ...(លេខខែឆ្នាំ)/...(លេខព្រះរាជក្រឹត្យ) ចុះកាលបរិច្ឆេទ ប្រថាប់ព្រះរាជលញ្ចករ និងចុះលេខព្រះរាជលញ្ចករ ព្រមទាំងបោះត្រារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំងលើគ្រប់សន្លឹកទំព័រនៃព្រះរាជក្រឹត្យ លើកលែងតែទំព័រចុងក្រោយដែលមានព្រះរាជលញ្ចកររួចហើយ។

**ង- ព្រះរាជក្រឹត្យជាសំណៅនិងសំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**

ចំពោះព្រះរាជក្រឹត្យដែលព្រះមហាក្សត្រឡាយព្រះហស្តលេខារួច អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាលមានភារកិច្ចរៀបចំសំណៅដែលមានតម្លៃជាការចែកផ្សាយ សម្រាប់ចែកជូនក្រសួង ស្ថាប័ន រាជធានី ខេត្តដើម្បីចាត់ចែងអនុវត្ត។ ក្នុងករណីនេះ ត្រូវដាក់នៅប៉ែកខាងស្តាំនៃទំព័រ ក្រោមព្រះបរមនាមរបស់ព្រះមហាក្សត្រឬគោរមងារនិងឈ្មោះរបស់ប្រមុខរដ្ឋស្តីទី នូវរូបមន្តខាងក្រោមនេះ៖

លេខ : ...

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

(ហត្ថលេខានិងត្រា)

(ឈ្មោះ)

ក្រសួង ស្ថាប័ន រាជធានី ខេត្តមានភារកិច្ចបន្តចម្លងសំណៅដែលមានតម្លៃជាការចែកផ្សាយ ជូនអង្គភាពក្រោមឱវាទដើម្បីចាត់ចែងអនុវត្ត។ ក្នុងករណីនេះ ត្រូវអនុវត្តដូចតទៅ៖

- នៅប៉ែកខាងស្តាំនៃទំព័រ ក្រោមរូបមន្ត "សំណៅដែលមានតម្លៃជាការចែកផ្សាយ" ត្រូវដាក់រូបមន្តខាងក្រោមនេះ៖

លេខ : ...

**បានចម្លងត្រឹមត្រូវតាមសំណៅ**

**ដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**ត.ប. រដ្ឋមន្ត្រី**

**អគ្គលេខាធិការឬអគ្គនាយក...**

(ហត្ថលេខានិងត្រា)

(ឈ្មោះ)

- នៅប៉ែកខាងឆ្វេងនៃទំព័រ ក្រោមរូបមន្តបានចម្លងត្រឹមត្រូវតាមសំណៅដែលមានតម្លៃជាការចែកផ្សាយ ត្រូវដាក់ **កន្លែងទទួល** ដែលរួមមានអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន នាយកដ្ឋាន មន្ទីរជំនាញរាជធានី ខេត្ត និងឯកសារ កាលប្បវត្តិ។

សូមមើលគំរូទម្រង់នៃព្រះរាជក្រឹត្យជាសំណៅនិងសំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ នៅទំព័រទី៦០ដល់៦២។

**ច- ព្រះរាជក្រឹត្យដែលស្នើឡើងដោយស្ថាប័នផ្សេងទៀត**

ព្រះរាជក្រឹត្យដែលព្រះមហាក្សត្រសព្វព្រះរាជហឫទ័យប្រទានតាមព្រះរាជតម្រិះ ក្រសួងព្រះបរមរាជវាំងបញ្ជូនច្បាប់ចម្លងនៃព្រះរាជក្រឹត្យទាំងនោះ ដោយមានការបញ្ជាក់ថា "បានចម្លងត្រឹមត្រូវតាមច្បាប់ដើម" ពីរដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីផ្សព្វផ្សាយក្នុងរាជកិច្ច។ ក្រសួងព្រះបរមរាជវាំងមានចេញច្បាប់ "បានចម្លងត្រឹមត្រូវតាមច្បាប់តម្កល់" ជូនក្រសួង ស្ថាប័នឬសាមីជនដែលត្រូវការ។

ព្រះរាជក្រឹត្យដែលព្រះមហាក្សត្រប្រោសព្រះរាជទានតាមសំណើរបស់ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬតាមសំណើរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្ថាប័នសាមី ត្រូវបញ្ជូនច្បាប់ដើមមកអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល ដើម្បីចេញសំណៅដែលមានតម្លៃជាការចែកផ្សាយ ជូនក្រសួង ស្ថាប័ន និងផ្សព្វផ្សាយក្នុងរាជកិច្ច។

គំរូទម្រង់នៃព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ដែលបានឆ្លង
អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

(រូបសញ្ញាព្រះរាជសង្ហារព្រះមហាក្សត្រ)

# ព្រះរាជក្រឹត្យ

## ស្តីពី

(ចំណងជើងជាអក្សរមូល)

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការកែសម្រួលសមាសភាពសមាជិករាជរដ្ឋាភិបាល(ដែលទាក់ទងនឹងរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីដែលរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ)
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត... (ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី...(ដែលពាក់ព័ន្ធ)
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី... ខែ... ឆ្នាំ...

**គ្រាស់បង្គាប់**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១ .-**

.............................................................................................................................។

**ជំពូកទី២** និង **ជំពូក**បន្តបន្ទាប់

(ចំណងជើង)

**មាត្រា... .-**

.............................................................................................................................។

**ជំពូកទី...**

**អន្តរប្បញ្ញត្តិ** (ប្រសិនបើមាន)

**មាត្រា... .-**

.............................................................................................................................។

**ជំពូកទី...**

**អវសានប្បញ្ញត្តិ**

**មាត្រា... .-**

ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី... និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។ (ក្នុងករណីនិរាករព្រះរាជក្រឹត្យចាស់ទាំងស្រុង)ឬ

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។ (ក្នុងករណីព្រះរាជក្រឹត្យថ្មីឬក្នុងករណីនិរាករចំណុចឬផ្នែកមួយចំនួនរបស់ព្រះរាជក្រឹត្យចាស់)

**មាត្រា... .-**

(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី... ខែ... ឆ្នាំ... ឬ
ធ្វើនៅ ថ្ងៃទី... ខែ... ឆ្នាំ... ( ក្នុងករណីព្រះមហាក្សត្រមិនគង់នៅព្រះបរមរាជវាំង)

(ព្រះហស្តលេខានិងព្រះរាជលញ្ឆករ)

(**ព្រះបរមនាម**)

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

(ហត្ថលេខា)

(**គោរមងារនិងឈ្មោះ**)

គំរូទម្រង់នៃព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ដែលមិនបានឆ្លង
អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី តែមានសំណើពីក្រសួង ស្ថាប័នសាមី

△

(រូបសញ្ញាព្រះរាជសង្ហារព្រះមហាក្សត្រ)

**ព្រះរាជក្រឹត្យ**

**ស្តីពី**

(ចំណងជើងជាអក្សរមូល)

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការកែសម្រួលសមាសភាពសមាជិករាជរដ្ឋាភិបាល(ដែលទាក់ទងនឹងរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីដែលរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ)
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត...(ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី...(ដែលពាក់ព័ន្ធ)
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**គ្រោងបទបញ្ជាប់**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១ .-**

.............................................................................................................................................។

**ជំពូកទី២** និង **ជំពូក**បន្តបន្ទាប់

(ចំណងជើង)

**មាត្រា... .-**

.............................................................................................................................................។

**ជំពូកទី...**

**អន្តរប្បញ្ញត្តិ** (ប្រសិនបើមាន)

**មាត្រា... .-**

.............................................................................................................................................។

**ជំពូកទី...**

**អវសានប្បញ្ញត្តិ**

**មាត្រា... .-**

ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី... និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។ (ក្នុងករណីនិរាករព្រះរាជក្រឹត្យចាស់ទាំងស្រុង) ឬ

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។ (ក្នុងករណីព្រះរាជក្រឹត្យថ្មីឬក្នុងករណីនិរាករចំណុចឬផ្នែកមួយចំនួនរបស់ព្រះរាជក្រឹត្យចាស់)

**មាត្រា... .-**

(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី... ខែ... ឆ្នាំ... ឬ
ធ្វើនៅ ថ្ងៃទី... ខែ... ឆ្នាំ... ( ក្នុងករណីព្រះមហាក្សត្រមិនគង់នៅព្រះបរមរាជវាំង)

(ព្រះហស្តលេខានិងព្រះរាជលញ្ជករ)

**( ព្រះបរមនាម )**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
(ហត្ថលេខា)
**( គោរមងារនិងឈ្មោះ )**

បានយកសេចក្តីគោរពជម្រាបជូន(គោរមងារ)នាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**...ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**...ឬ **រដ្ឋមន្ត្រីក្រសួង**...(ឬប្រធានស្ថាប័នសាម៉ី)
(ហត្ថលេខា)
( **ឈ្មោះ** )

៣៨/១៣០

**តទៅរាជកិច្ចលេខ ៤៨**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១០ .សរណន**

# សារាចរណែនាំ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជួយសម្របសម្រួលការគ្រប់គ្រងរោងចក្រ សហគ្រាសដែលស្ថិតក្នុងភូមិសាស្ត្ររាជធានី ខេត្ត

រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ការអភិវឌ្ឍសេដ្ឋកិច្ចជាតិមានការរីកចម្រើនយ៉ាងឆាប់រហ័ស ក្នុងនោះវិស័យកម្មន្តសាលមានការអភិវឌ្ឍយ៉ាងលឿន ហើយមានគ្រឹះស្ថានផលិតកម្ម សេវាកម្មជាច្រើនត្រូវបានបង្កើតឡើង ផ្តល់ការងារធ្វើរាប់លានដល់ប្រជាពលរដ្ឋ។ រោងចក្រសហគ្រាស ជាច្រើនត្រូវបានបង្កើតឡើងនៅតាមរាជធានី ខេត្ត ដែលមានទីតាំងពីទីក្រុង ទីប្រជុំជន រហូតដល់តំបន់ជនបទ។

រដ្ឋបាលថ្នាក់ក្រោមជាតិ បានយកចិត្តទុកដាក់បង្កលក្ខណៈងាយស្រួលដល់រោងចក្រសហគ្រាស ក្នុងដំណើរការផលិតកម្មអាជីវកម្មរបស់ខ្លួន បានល្អស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

និយោជកតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន បានគោរព និងអនុវត្តច្បាប់ លិខិតបទដ្ឋានជាធរមាន និងមានទំនាក់ទំនងល្អជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដើម្បីបន្តពង្រឹងការអភិវឌ្ឍវិស័យកម្មន្តសាល ឲ្យមានការរីកចម្រើនលូតលាស់ទៅគ្រប់រាជធានី ខេត្ត សំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងដោះស្រាយការងារជូនប្រជាពលរដ្ឋនៅជិតលំនៅឋានបានល្អប្រសើរ រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជួយសម្របសម្រួលការគ្រប់គ្រងរោងចក្រ សហគ្រាស ដែលស្ថិតក្នុងភូមិសាស្ត្ររាជធានី ខេត្ត ដូចតទៅៈ

១-អភិបាលរាជធានី ខេត្ត ត្រូវបន្តបង្កលក្ខណៈងាយស្រួល និងជួយឧបត្ថម្ភគាំទ្រដល់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងដំណើរការផលិតកម្ម អាជីវកម្ម ដែលស្ថិតនៅភូមិសាស្ត្ររបស់ខ្លួនឲ្យបានល្អ។

២-អភិបាលរាជធានី ខេត្ត មានសិទ្ធិអញ្ជើញនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ផលិតកម្ម អាជីវកម្ម ដែលស្ថិតនៅភូមិសាស្ត្ររបស់ខ្លួន ដើម្បីពិភាក្សាការងារដែលពាក់ព័ន្ធនឹងសមត្ថកិច្ច។ /.

៣-អភិបាលរាជធានី ខេត្ត ដោយមានមន្ទីរជំនាញជាសេនាធិការ អាចធ្វើអធិការកិច្ច តាមការចាំបាច់ចំពោះរោងចក្រ សហគ្រាស គ្រឹះស្ថាន ផលិតកម្ម អាជីវកម្ម និងចាត់វិធានការតាមច្បាប់ជាធរមាន។

៤-នាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ផលិតកម្ម អាជីវកម្ម ត្រូវមានទំនាក់ទំនងសហការឲ្យបានល្អជាមួយអភិបាលរាជធានី ខេត្ត និងអាជ្ញាធរដែនដីដែលរោងចក្រ សហគ្រាស គ្រឹះស្ថាន ផលិតកម្ម អាជីវកម្ម បោះទីតាំង។

៥-ក្នុងករណីមានវិវាទការងារកូដកម្ម បាតុកម្ម អភិបាលរាជធានី ខេត្ត និងជាប្រធានគ.ក.ប. រាជធានី ខេត្ត ត្រូវចាត់វិធានការដោះស្រាយតាមបទប្បញ្ញត្តិជាធរមាន ជាពិសេសតាមបទបញ្ជាលេខ ០៣ បប ស្តីពីការរក្សាការពារ សន្តិសុខ សណ្តាប់ធ្នាប់ សាធារណៈ នៅតាមតំបន់រោងចក្រ សហគ្រាស និងតំបន់ឧស្សាហកម្ម។

គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវអនុវត្តសារាចរណែនាំនេះឲ្យមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ១ ប្រការ ២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ : ៤៣៦ ឧរ៉ថ.អឧ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០១៣

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ៥៩០/១៣ គ.វ.ក ចុះថ្ងៃទី២០.០៣.២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន វ៉ានសេន ក្លូសស៊ីង (ខេមបូឌា) ចុះថ្ងៃទី១២.០៣.២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុនវ៉ានសេន ក្លូសស៊ីង (ខេមបូឌា) (WANSHEN CLOTHING(CAMBODIA) CO., LTD.) តំណាងដោយ លោក XU YAOTANG សញ្ជាតិចិន អាយុ៥៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G37723850 ចុះថ្ងៃទី០៨.០៩.២០០៩ មានអាសយដ្ឋានបច្ចុប្បន្ន៖ No.377 Yayuan Nan Road. Ningbo Zhejiang , China. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

- **ផ្លាកឈ្មោះរោងចក្រ៖** *"រោងចក្រកាត់ដេរសម្លៀកបំពាក់ វ៉ានសេន ភ្លួសស៊ីង (ខេមបូឌា) "*

- **ទីតាំងរោងចក្រ៖** *"ភូមិកន្ទោកជើង សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចែរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤,, "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ: ៤៣៧ ឧរថ.ស.ក្ស.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៣

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ២៩១៩ /១២ គ.វ.ក ចុះថ្ងៃទី១៨.១២.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ខេមបូឌាន លី ហួ តាង ហ្វើនីឈ័រ គ្រុប ចុះថ្ងៃទី១៩.០៤.២០១២

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ខេមបូឌាន លី ហួ តាង ហ្វើនីឈ័រ គ្រុប (CAMBODIAN LI HUA TANG FURNITURE GROUP CO., LTD.) តំណាងដោយ លោក CHEN AIMING សញ្ជាតិចិន អាយុ៤៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G32551675 ចុះថ្ងៃទី១១.១២.២០០៨ មានអាសយដ្ឋានបច្ចុប្បន្ន៖ No. 2, Street Beyai, QingDian City, Zhejian Province, China. ជាម្ចាស់រោងចក្រធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

| -ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| គ្រឿងសង្ហារឹម | ៣១០០[illegible] |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

- **ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រផលិតសាឡុង ខេមបូឌាន លី ហួ តាង ហ្វើនីឈ័រ គ្រុប "*
- **ទីតាំងរោងចក្រ ៖** *" ដីឡូត៍លេខ២៤៤ ភូមិប្រេស សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤,, "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ